ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ប្រសិទ្ធភាពនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀនក្នុងខេត្តឧត្តរមានជ័យ

# “EFFECTIVENESS OF IMPLEMENTING REGULAR SCHOOL INSPECTION REPORTS”IN ODDAR MEANCHEY PROVINCE

អ៊ឹម សានី

IM SANY

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

ជំនាន់ទី៨

ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៩-២០២១

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ប្រសិទ្ធភាពនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀនក្នុងខេត្តឧត្តរមានជ័យ

# “EFFECTIVENESS OF IMPLEMENTING REGULAR SCHOOL INSPECTION REPORTS”IN ODDAR MEANCHEY PROVINCE

**អ៊ឹម សានី**

IM SANY

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

ជំនាន់ទី៨

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៩-២០២១

គ្រូដឹកនាំបន្ទោល៖ លោក ឌី បុណ្ណា

គ្រូដឹកនាំរង៖ ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទឈ្មោះ **អ៊ឹម សានី** សូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ប្រសិទ្ធភាព នៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់ របស់សាលារៀនក្នុងខេត្តឧត្តរមានជ័យ**» សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ នៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះឬនៅសាកលវិទ្យាល័យណាឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយណាត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះ ពិតជាត្រូវបានស្រាវជ្រាវនិងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃ ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ,ថ្ងៃទី..........ខែវិច្ឆិកា ឆ្នាំ២០២១

**ហត្ថលេខា**

**អ៊ឹម សានី**

# លិខិតបញ្ជាក់

លោក **ឌី ប៊ុណ្ណា** ជាសាស្ត្រាចារ្យដឹកនាំ

ឯកឧត្តមបណ្ឌិត **សៀង សុខណ្ណា** ជាសាស្ត្រាចារ្យដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **អ៊ឹម សានី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ « **ប្រសិទ្ធភាពនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀន ក្នុងខេត្តឧត្តរមានជ័យ** » ពិតប្រាកដមែន។

ថ្ងៃ ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ,ថ្ងៃទី..........ខែវិច្ឆិកា ឆ្នាំ២០២១

............................................ ..................................................................

លោក **ឌី ប៊ុណ្ណា** ឯកឧត្តមបណ្ឌិត **សៀង សុខណ្ណា**

នាយករងវិទ្យាស្ថានជាតិអប់រំ នាយកវិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៣២០៥ អយក. ឌទន

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ១៤៣៤ អយក.ឌទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។
-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៤-លោកបណ្ឌិត | ឈូក ច័ន្ទធាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | សំអោ អង្គារតន៍ | អគ្គ.គផក | សមាជិក |
| ១១-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | សមាជិក |
| ១២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | កាង ស៊ុងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោក | ប៉ូ ប៊ុន្នន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | | |
|---|---|---|---|
| ២២-លោកស្រី | ខែក សំណាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោកស្រី | នូ ចន្នី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥-លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៦-លោក | លន លីណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៧-លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៩-ល.ស | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៨-លោក | ជាង ចាន់ណាក់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣០-លោក | អ៊ុច ផលរដ្ឋ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ពុធ ៦កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ វជអ

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **អ៊ឹម សានី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ នៃវិទ្យាស្ថានជាតិអប់រំ។

**<u>សូមថ្លែងអំណរគុណជាអនេកប្បការជូនចំពោះ៖</u>**

-លោកឪពុក **អ៊ឹម ឆុន**និងអ្នកម្ដាយ **ឆាច ម៉ុច** ដែលបានផ្ដល់កំណើតចិញ្ចឹមបីបាច់ថែរក្សារូបកូនដោយផ្ដល់ដំបូន្មានល្អៗ ព្រមទាំងបានបញ្ជូនកូនឱ្យចូលសិក្សារៀនសូត្រតាំងពីថ្នាក់បឋមសិក្សារហូតមកដោយមិនគិតពីការនឿយហត់ និងតស៊ូដើម្បីកូនទទួលបានជោគជ័យមានអនាគតរុងរឿងជាបន្តបន្ទាប់។

-លោកឪពុកក្មេក **ស៊ឹម ស៊ន់** និងអ្នកម្ដាយក្មេក **រឹម យ៉ាម** ដែលបានផ្ដល់ការគាំទ្រលើកទឹកចិត្តដល់រូបខ្ញុំក្នុងការសិក្សានេះរហូតទទួលបានជោគជ័យ។

-ឧត្តមភរិយា **ស៊ឹម ណារ៉ាំយ៉ា** កូនប្រុស**ឆុន សានីយ៉ាឆដា** និងកូនស្រី**ឆុន សានីយ៉ាសោមា** ដែលបានគាំទ្រលើកទឹកចិត្តខ្ញុំ ក្នុងការសិក្សានេះ និងតស៊ូជំនះឧបសគ្គនានាជាមួយខ្ញុំដោយមិនគិតពីការនឿយហត់ ដើម្បីឱ្យការសិក្សារបស់ខ្ញុំបញ្ចប់ និងទទួលបានជោគជ័យ។

**-ឯកឧត្តមថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា** ដែលបានរៀបចំបង្កើតឱ្យមានថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំសម្រាប់បុគ្គលិកអប់រំនេះឡើង ក៏ដូចជាលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងវិស័យអប់រំប្រកបដោយប្រសិទ្ធភាព និងគុណភាពស្របតាមបរិបទរីកចម្រើននៅកម្ពុជា។

-លោក **ឌី បុណ្ណា** នាយករងវិទ្យាស្ថានជាតិអប់រំ ជាសាស្ត្រាចារ្យដឹកនាំ ដែលបានឆ្លៀតពេលដ៏មានតម្លៃក្នុងការផ្ដល់គំនិតណែនាំ និងផ្ដល់ទាំងកម្លាំងកាយ កម្លាំងចិត្ត បញ្ញាស្មារតី សម្ភារៈ បច្ចេកទេស វិធីសាស្ត្រផ្សេងៗ ឯកសារ ព្រមទាំងជួយបង្ហាញទិសដៅនៃការស្រាវជ្រាវប្រកបដោយគតិបណ្ឌិតដល់រូបខ្ញុំរហូតដល់ការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យជាភស្តុតាងស្រាប់ ។

-ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ ជាសាស្ត្រាចារ្យដឹកនាំរង ដែលបានឆ្លៀតពេលដ៏មានតម្លៃរបស់ឯកឧត្តមក្នុងការផ្ដល់គំនិតណែនាំ និងផ្ដល់ទាំងកម្លាំងកាយ កម្លាំងចិត្ត

បញ្ញាស្មារតី សម្ភារៈ បច្ចេកទេស វិធីសាស្ត្រផ្សេងៗ។ មិនតែប៉ុណ្ណោះឯកឧត្តមបណ្ឌិត បានជួយបង្ហាញទិសដៅនៃការស្រាវជ្រាវប្រកបដោយគតិបណ្ឌិតដល់រូបខ្ញុំ ហេតុដល់ការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យជាកស្តុតាងស្រាប់ ។

-ឯកឧត្តម បណ្ឌិត លោក លោកស្រី ដែលជាថ្នាក់ដឹកនាំ ជាសាស្ត្រាចារ្យទាំងអស់នៃវិទ្យាស្ថានជាតិអប់រំ ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត សម្ភារៈ ក្នុងការផ្តល់ពុទ្ធិ ចំណេះធ្វើ ឥរិយាបថ ពិសេសផ្តល់ជាទ្រឹស្តី បទពិសោធន៍ល្អៗ ដែលទាំងនេះជាចំណេះដឹងមួយដ៏សំខាន់ និងចាំបាច់បំផុតសម្រាប់អនុវត្ត ព្រមទាំងឆ្លុះបញ្ចាំងពីការអនុវត្តការងារបច្ចុប្បន្ន និងបានសម្របសម្រួលដល់ដំណើរការនៃការបណ្តុះបណ្តាលក្នុងវគ្គនេះប្រកបដោយជោគជ័យ។

-លោកនាយក នាយិកា នាយករង លោកគ្រូ អ្នកគ្រូ ដែលបានសហការ ចំពោះការចុះក្នុងស្រាវជ្រាវសម្ភាសប្រមូលទិន្នន័យរបស់ខ្ញុំ ដើម្បីយកមកសរសេរនិក្ខេបបទនេះរហូតទទួលបានជោគជ័យ។

-លោកស្រី **អ៊ុំ សាខ** អនុប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងប្រឡង ដែលបានឧបត្ថម្ភថវិកាចំនួន **២០០$ (ពីររយដុល្លារអាមេរិកគត់)** ទុកជាការលើកទឹកចិត្តដល់រូបខ្ញុំ ដើម្បីយកមកប្រើប្រាស់ ក្នុងកិច្ចដំណើរការសិក្សានេះ។ ឥរិយាបថចែករំលែកនេះ ចាត់ទុកជាគំរូសប្បុរសធម៌មួយដែលមនុស្សគ្រប់ៗរូបគួរមានចំពោះគ្នា មិនអាចកាត់ថ្លៃបានឡើយ។

-លោក **ម៉ិច រតនា** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ និងភរិយា ដែលបានឧបត្ថម្ភថវិកាចំនួន **១,000,000៛ (មួយលានរៀនគត់)** ទុកជាការលើកទឹកចិត្តដល់រូបខ្ញុំ ដើម្បីយកមកប្រើប្រាស់ ក្នុងកិច្ចដំណើរការសិក្សានេះ។ ឥរិយាបថចែករំលែកនេះ ចាត់ទុកជាគំរូសប្បុរសធម៌មួយដែលមនុស្សគ្រប់ៗរូបគួរមានចំពោះគ្នា មិនអាចកាត់ថ្លៃបានឡើយ។

ជាទីបញ្ចប់ខ្ញុំបាទ សូមគោរពបួងសួងដល់វត្ថុស័ក្តិសិទ្ធក្នុងលោកប្រសិទ្ធិពរជ័យបវរមហាប្រសើរជូនចំពោះ អ្នកមានគុណទាំងអស់ខាងលើ ជួបប្រទះតែពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា


**សេចក្តីប្រកាសអះអាងរបស់បេក្ខជន** .......... ii

**លិខិតបញ្ជាក់** .......... iii

**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការពារនិក្ខេបបទ** .......... iv

**សេចក្តីថ្លែងអំណរគុណ** .......... vi

**មាតិកា** .......... viii

**បញ្ជីរូបភាព** .......... xi

**បញ្ជីតារាង** .......... xiii

**បញ្ជីអក្សរកាត់** .......... xiv

**មូលន័យសង្ខេប** .......... xv

Abstract .......... xviii

**ជំពូកទី១** .......... 1

**សេចក្តីផ្តើម** .......... 1

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ .......... 1

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ .......... 3

១.៣ គោលបំណងនៃការស្រាវជ្រាវ .......... 4

១.៤ សំណួរស្រាវជ្រាវ .......... 4

១.៥. សារៈសំខាន់នៃការស្រាវជ្រាវ .......... 4

១.៦. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ .......... 5

១.៧ រចនាសម្ព័ន្ធស្រាវជ្រាវ .......... 6

**ជំពូកទី២** .......... 7

**រំលឹកទ្រឹស្តី** .......... 7

២.១. ការសិក្សាពាក្យគន្លឹះ .......... 7

២.២.ក្របខណ្ឌជានាគុណភាព .......... 7

២.២.១.សកម្មភាពសំខាន់ៗក្នុងដំណើរការជានាគុណភាព .......... 8

២.២.២.មូលដ្ឋានគតិយុត្តិសម្រាប់ជានាគុណភាពនិងការធ្វើអធិការកិច្ច ....................................9
២.៣.ប្រព័ន្ធអធិការកិច្ចអប់រំ ....................................................................................................9
២.៣.១.តួនាទីអធិការ ......................................................................................................9
២.៣.២.វិធីសាស្ត្រអធិការកិច្ច ......................................................................................10
២.៣.៣.ការផ្តល់យោបល់និងការណែនាំ .........................................................................12
២.៣.៤.ការអភិវឌ្ឍសមត្ថភាពអធិការ ...........................................................................12
២.៣.៥.អធិការកិច្ចផ្ទៃក្នុង ...........................................................................................13
២.៣.៦.អធិការកិច្ចផ្ទៃក្រៅ ...........................................................................................15
២.៤.អធិការកិច្ចតាមកាលកំណត់ ..................................................................................15
២.៤.១.ភាពញឹកញាប់នៃការធ្វើអធិការកិច្ចតាមកាលកំណត់ ...........................................16
២.៤.២.ប្រព័ន្ធរបាយការណ៍អធិការកិច្ចតាមកាលកំណត់...................................................17
២.៤.៣.លទ្ធផលនៃដំណើរការវាយតម្លៃ...........................................................................18
**ជំពូកទី៣**...................................................................................................................20
**វិធីសាស្ត្រស្រាវជ្រាវ**.....................................................................................................20
៣.១ គម្រោងវិភាគ ..........................................................................................................20
៣.២ ការប្រមូលទិន្នន័យ...................................................................................................22
៣.៣ ឧបករណ៍ស្រាវជ្រាវ...................................................................................................23
៣.៤.ការជ្រើសរើសភាគសំណាក..........................................................................................24
៣.៥.ការវិភាគទិន្នន័យ.......................................................................................................25
**ជំពូកទី៤** ..................................................................................................................26
**លទ្ធផល និងការពិភាក្សា**..............................................................................................26
៤.១.ឧបករណ៍វិភាគទិន្នន័យ ...........................................................................................26
៤.២.ដំណាក់កាលនៃការវិភាគទិន្នន័យ .............................................................................26
៤.៣.ការវិភាគទិន្នន័យ......................................................................................................26
៤.៣.១.ការវិភាគទិន្នន័យលើកម្រងសំណួរគ្រូបង្រៀន ......................................................27

៤.៣.១.១.ផ្នែកទី១ ព័ត៌មានទូទៅ ........................................................................................27
៤.៣.១.២.ផ្នែកទី២ការគ្រប់គ្រងនិងដឹកនាំ.......................................................................................41
៤.៣.១.៣.ផ្នែកទី៣ បញ្ហាប្រឈមក្នុងការអនុវត្តរបាយការណ៍អធិការកិច្ច ...........................................53
៤.៣.១.៤.ផ្នែកទី៤.ការយល់ឃើញរបស់គ្រូបង្រៀន .........................................................................56
៤.៣.២.ការវិភាគទិន្នន័យលើកកម្រងសំណួរនាយកសាលា.........................................................59
៤.៣.២.១.ផ្នែកទី១ ព័ត៌មានទូទៅ ........................................................................................59
៤.៣.២.២.ផ្នែកទី២ការគ្រប់គ្រងនិងដឹកនាំ.......................................................................................70
៤.៣.២.៣.ផ្នែកទី៣ បញ្ហាប្រឈមក្នុងការអនុវត្តរបាយការណ៍អធិការកិច្ច ...........................................82
៤.៣.២.៤.ផ្នែកទី៤.ការយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន ...............................................85
៤.៤.ការសំយោគទិន្នន័យកម្រងសំណួរ ..................................................................................88
៤.៤.១.កម្រិតវាយតម្លៃលើចំណុចគោលនៃអនុសាសន៍អធិការកិច្ច ...........................................88
៤.៤.២.លទ្ធផលនៃការពិភាក្សាលើសំណួរស្រាវជ្រាវទី១...............................................................102
៤.៤.៣.ស្ថានភាពនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់ .........................................103
៤.៤.៤.លទ្ធផលនៃការពិភាក្សាសំណួរស្រាវជ្រាវទី២ ..................................................................104
៤.៤.៥.ការយល់ឃើញចំពោះការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់...........................105
**ជំពូកទី៥** ..........................................................................................................106
**សេចក្តីសន្និដ្ឋាន និងសំណូមពរ**............................................................................................106
៥.១. សេចក្តីសន្និដ្ឋាន .........................................................................................106
៥.២. សំណូមពរ ......................................................................................................108
ឯកសារយោង .......................................................................................................111
ឧបសម្ព័ន្ធ .......................................................................................................113
ឧបសម្ព័ន្ធ « ក » កម្រងសំណួរស្រាវជ្រាវនាយក ..................................................................113
ឧបសម្ព័ន្ធ « ខ » កម្រងសំណួរស្រាវជ្រាវគ្រូបង្រៀន ...........................................................122
ឧបសម្ព័ន្ធ « គ » លិខិតឧទ្ទេសនាម និងឯកសារពាក់ព័ន្ធ .........................................................131

# បញ្ជីរូបភាព


រូបភាព 1 បង្ហាញពីភេទរបស់គ្រូបង្រៀន....27
រូបភាព 2 បង្ហាញពីមុខវិជ្ជាឯកទេសរបស់គ្រូបង្រៀនដែលបានបំពេញកម្រងសំណួរ....28
រូបភាព 3 ក្រាបបង្ហាញពីអាយុរបស់លោកគ្រូ អ្នកគ្រូដែលបានចូលបំពេញកម្រងសំណួរ....29
រូបភាព 4 បទពិសោធន៍របស់គ្រូបង្រៀនក្នុងការបង្រៀន....30
រូបភាព 5 ក្រាបបង្ហាញពីកម្រិតជំនាញវិជ្ជាជីវៈរបស់គ្រូបង្រៀន....33
រូបភាព 6 ក្រាបបង្ហាញពីការរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍របស់នាយក....42
រូបភាព 7 ក្រាបបង្ហាញពីការទទួលការចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនពីនាយក....43
រូបភាព 8 ក្រាបបង្ហាញពីកម្រិតចូលរួមកែលម្អបរិស្ថានសាលារៀនរបស់គ្រូបង្រៀន....44
រូបភាព 9 ក្រាបបង្ហាញពីកម្រិតនៃការធ្វើកិច្ចតែងការបង្រៀនរបស់គ្រូបង្រៀន....45
រូបភាព 10 កម្រិតបានតុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់របស់គ្រូបង្រៀន....46
រូបភាព 11 ក្រាបបង្ហាញពីកម្រិតបានរៀបចំសៀវភៅនានាតាមបែបបទរដ្ឋបាលគ្រូ....47
រូបភាព 12 ក្រាបបង្ហាញពីគុណភាព និងលទ្ធផលសិក្សារបស់សិស្សកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ....48
រូបភាព 13 កម្រិតការចូលរួមពីសហគមន៍ជាមួយសាលារៀន....50
រូបភាព 14 ក្រាបបង្ហាញពីកម្រិតរីកចម្រើនរបស់សាលារៀនបន្ទាប់ពីចុះអធិការកិច្ច....51
រូបភាព 15 កម្រិតវាយតម្លៃចុងក្រោយប្រចាំខែនៃដំណើរការសិក្សារបស់សាលារៀនក្នុងពេលបច្ចុប្បន្ន....52
រូបភាព 16 ក្រាបបង្ហាញពីការធ្វើរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់ក្រុមអធិការកិច្ច....53
រូបភាព 17 ក្រាបបង្ហាញពីការអភិវឌ្ឍ ការងាររដ្ឋបាលគ្រូ តាមរយៈរបាយការណ៍អធិការកិច្ច....56
រូបភាព 18 ភាគរយការអនុវត្តការងារគ្រូបង្រៀននិងការងាររបស់សាលារៀន....57
រូបភាព 19 ក្រាបបង្ហាញពីកម្រិតការអភិវឌ្ឍរបស់សាលារៀន....58
រូបភាព 20 បង្ហាញពីភេទរបស់នាយក នាយិកា និងនាយករង....59
រូបភាព 21 ក្រាបបង្ហាញពីឋានៈតួនាទីរបស់គណៈគ្រប់គ្រង....60
រូបភាព 22 ក្រាបបង្ហាញពីវ័យរបស់គណៈគ្រប់គ្រងសាលារៀន....61
រូបភាព 23 ក្រាបបង្ហាញពីបទពិសោធន៍ ដឹកនាំនិងគ្រប់គ្រង....61
រូបភាព 24 ក្រាបបង្ហាញពីកម្រិតជំនាញវិជ្ជាជីវៈរបស់គណៈគ្រប់គ្រង....64
រូបភាព 25 ក្រាបបង្ហាញពីការរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍របស់នាយក....71
រូបភាព 26 ក្រាបបង្ហាញពីការការចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនរបស់នាយក....72
រូបភាព 27 ក្រាបបង្ហាញពីកម្រិតកែលម្អបរិស្ថានសាលារៀនរបស់នាយក....73
រូបភាព 28 ក្រាបបង្ហាញពីកម្រិតនៃការធ្វើកិច្ចតែងការរបស់គ្រូបង្រៀន....74
រូបភាព 29 កម្រិតបានតុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់របស់គ្រូបង្រៀន....75

រូបភាព 30 ក្រាបបង្ហាញពីកម្រិតបានរៀបចំសៀវភៅនានាតាមបែបបទរដ្ឋបាលគ្រូ....................................76
រូបភាព 31 ក្រាបបង្ហាញពីគុណភាព និងលទ្ធផលសិក្សារបស់សិស្សកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ......77
រូបភាព 32 កម្រិតការចូលរួមពីសហគមន៍ជាមួយសាលារៀន........................................................78
រូបភាព 33 ក្រាបបង្ហាញពីកម្រិតរីកចម្រើនរបស់សាលារៀនបន្ទាប់ពីក្រុមការងារអធិការកិច្ចចុះ...........79
រូបភាព 34 កម្រិតនៃការវាយតម្លៃចុងក្រោយប្រចាំខែនៃដំណើរការសិក្សារបស់សាលារៀន.................80
រូបភាព 35 ក្រាបបង្ហាញពីការទទួលចំណាត់ថ្នាក់ សាលារៀនល្អ នាយកល្អ និងប័ណ្ណសរសើរ............81
រូបភាព 36 ក្រាបបង្ហាញពីការផ្ញើរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់ក្រុមអធិការកិច្ច.........82
រូបភាព 37 ក្រាបបង្ហាញពីការអភិវឌ្ឍ ការងាររដ្ឋបាលគ្រូ តាមរយៈរបាយការណ៍អធិការកិច្ច...............85
រូបភាព 38 ក្រាបបង្ហាញពីភាគរយការអនុវត្តការងាររបស់នាយកនៅសាលារៀន.............................86
រូបភាព 39 ក្រាបបង្ហាញពីកម្រិតការអភិវឌ្ឍរបស់សាលារៀន........................................................87
រូបភាព 40 ក្រាបបង្ហាញពីការរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍របស់នាយក ...........................90
រូបភាព 41 ខ្សែបន្ទាត់បង្ហាញពីការចុះអធិការកិច្ច និងទទួលការចុះអធិការកិច្ចអចិន្ត្រៃយ៍របស់នាយក ... 91
រូបភាព 42 ក្រាបបង្ហាញពីកម្រិតកែលម្អបរិស្ថានសាលារៀន.........................................................93
រូបភាព 43 ក្រាបបង្ហាញពីកម្រិតនៃការធ្វើកិច្ចតែងការរបស់គ្រូបង្រៀន .........................................94
រូបភាព 44កម្រិតបានតុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់របស់គ្រូបង្រៀន..................................96
រូបភាព 45 ក្រាបបង្ហាញពីកម្រិតបានរៀបចំសៀវភៅនានាតាមបែបបទរដ្ឋបាលគ្រូ...........................98
រូបភាព 46 ក្រាបបង្ហាញពីគុណភាព និងលទ្ធផលសិក្សារបស់សិស្សកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ....100
រូបភាព 47 ក្រាបបង្ហាញការចូលរួមគាំទ្រពីសហគមន៍នៃសាលាគោលដៅ .................................... 101

# បញ្ជីតារាង

តារាងទី 1 ចំនួនគ្រូតាមសាលារៀនគោលដៅទាំងអស់ដែលបានចូលបំពេញកម្រងសំណួរ.................31
តារាងទី 2 បង្ហាញពីចម្ងាយធ្វើដំណើររបស់លោកគ្រូ អ្នកគ្រូពីផ្ទះឬកន្លែងស្នាក់នៅ ទៅសាលារៀន.......32
តារាងទី 3 ការចូលរួមក្នុងវគ្គបំប៉ន ឬសិក្ខាសាលានានារបស់គ្រូបង្រៀន ......................................35
តារាងទី 4 បង្ហាញពីចំនួនបុគ្គលិកតាមសាលាគោលដៅនីមួយៗ ...............................................36
តារាងទី 5 បង្ហាញពីចំនួនអគារ និងចំនួនបន្ទប់តាមសាលារៀន ................................................38
តារាងទី 6 បង្ហាញពីចំនួនបង្គន់ និងចំនួនបន្ទប់តាមសាលារៀន ................................................40
តារាងទី 7 ក្រាបបង្ហាញពីកម្រិតរៀបចំទីចាត់ការសាលារៀន ...................................................... 41
តារាងទី 8 បញ្ហាប្រឈមខ្លាំងក្នុងការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់.......................55
តារាងទី 9 ចំនួនគណៈគ្រប់គ្រងតាមសាលារៀនគោលដៅដែលបានចូលបំពេញកម្រងសំណួរ ...........62
តារាងទី 10 បង្ហាញពីចម្ងាយធ្វើដំណើររបស់នាយកពីផ្ទះឬកន្លែងស្នាក់នៅ ទៅសាលារៀន ...............63
តារាងទី 11 ការចូលរួមក្នុងវគ្គបំប៉ន ឬសិក្ខាសាលានានារបស់គណៈគ្រប់គ្រង.................................66
តារាងទី 12 បង្ហាញពីចំនួនបុគ្គលិកតាមសាលាគោលដៅនីមួយៗ................................................67
តារាងទី 13 បង្ហាញពីចំនួនអគារ និងចំនួនបន្ទប់តាមសាលារៀន.................................................68
តារាងទី 14 បង្ហាញពីចំនួនបង្គន់ និងចំនួនបន្ទប់តាមសាលារៀន.................................................69
តារាងទី 15 ក្រាបបង្ហាញពីកម្រិតរៀបចំទីចាត់ការសាលារៀន....................................................70
តារាងទី 16 បញ្ហាប្រឈមខ្លាំងរាំងស្ទះដល់ការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់ ..........84
តារាងទី 17 ក្រាបបង្ហាញពីកម្រិតរៀបចំទីចាត់ការសាលារៀន....................................................88
តារាងទី 18 ទិន្នន័យលទ្ធផលសរុបនៃ ចំណុចគោលអនុសាសន៍អធិការកិច្ច.................................102

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ខ្លឹមសារពេញ |
|---|---|
| ក្រសួងអយក | ក្រសួងអប់រំ យុវជន និងកីឡា |
| មន្ទីរអេយកខ | មន្ទីរអប់រំ យុវជន និងកីឡា |
| អនុវិ. | អនុវិទ្យាល័យ |
| CFS | Child Friendly School |
| DTMT | District Training and Monitoring Team |
| ICT | Information and Communication Technology |
| Ms.Word | Microsoft Word |

# មូលន័យសង្ខេប

ការអនុវត្តអនុសាសន៍ ក្នុងរបាយការណ៍អធិការកិច្ចតាមកាលកំណត់ របស់សាលារៀន គឺជាសកម្មភាព អាទិភាពមួយរបស់សាលារៀនដែលត្រូវយកចិត្តទុកដាក់ ក្នុងការចូលរួមសម្រេចឱ្យបានតាមការដាច់ចេញរបស់ក្រុមការងារអធិការកិច្ច ដើម្បីអភិវឌ្ឍសាលារៀនឱ្យមានការរីកចម្រើនស្របតាមការធ្វើកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា។ ជាមួយគ្នានេះ យើងបានកំណត់យកចំណុចគោលចំនួន០៧នៃអនុសាសន៍ក្នុងរបាយការណ៍អធិការកិច្ចតាមកាលកំណត់រួមមាន៖ (១).ការរៀបចំទីចាត់ការ (២).ផែនការនិងការចុះអធិការកិច្ចថ្នាក់រៀន (៣).ការកែលម្អបរិស្ថានសាលារៀន (៤).ការធ្វើកិច្ចតែការបង្រៀន (៥).រដ្ឋបាលថ្នាក់និងរដ្ឋបាលគ្រូ (៦).គុណភាពនិងលទ្ធផលសិក្សារបស់សិស្ស និង(៧).ការចូលរួមគាំទ្ររបស់សហគមន៍។ ដោយមើលឃើញពីគុណប្រយោជន៍ ក្នុងការលើកកម្ពស់ការអភិវឌ្ឍរបស់សាលារៀន និងរួមចំណែកអនុវត្តកំណែទម្រង់ជាមួយក្រសួងអប់រំ យុវជន និងកីឡា ទើបយើងកំណត់ជ្រើសរើសយកប្រធានបទ « **ប្រសិទ្ធភាពនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀនក្នុងខេត្តឧត្តរមានជ័យ** » មកធ្វើការសិក្សាស្រាវជ្រាវដើម្បីរកឱ្យឃើញពីប្រសិទ្ធភាព និងបញ្ហាប្រឈមនានាក្នុងការអនុវត្តជាក់ស្តែងរបស់សាលារៀន។

ការស្រាវជ្រាវប្រធានបទខាងលើក្នុងគោលបំណងសំខាន់ៗចំនួនពីរគឺ ១.វាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តអនុសាសន៍ របាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀន ដោយសាលារៀន ២.កំណត់បញ្ហាប្រឈមក្នុងការអនុវត្តរបាយការណ៍អធិការកិច្ច និងដាក់ចេញនូវអនុសាសន៍ ដើម្បីកែលម្អការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់ ដល់សាលារៀន។

ការសិក្សាស្រាវជ្រាវនេះ ផ្តោតទៅលើការអនុវត្តរបស់នាយក និងគ្រូបង្រៀនស្របតាមអនុសាសន៍ក្នុងរបាយការណ៍អធិការកិច្ចតាមកាលកំណត់ នៅតាមសាលាអនុវិទ្យាល័យក្នុងខេត្តឧត្តរមានជ័យដែលបានចុះអធិការកិច្ចតាមកាលកំណត់កន្លងមកចាប់ពីឆ្នាំ២០១៥ដល់ឆ្នាំ២០២០។ យើងបានជ្រើសរើសអនុវិទ្យាល័យចំនួន១១ ក្នុងចំណោមអនុវិទ្យាល័យចំនួន១៦នៃក្រុង/ស្រុកចំនួន០៤ គឺ៖ ១.ក្រុងសំរោងចំនួន០៥សាលា (អនុវិទ្យាល័យ ហ៊ុន សែន រួតចំប៉ី ,អនុវិទ្យាល័យ ស៊ូវ៉ែកគុណពោធិវង្ស , អនុវិទ្យាល័យ

បន្ទាយរាក់ អនុវិទ្យាល័យកូនក្រៀល, និងអនុវិទ្យាល័យ បុស្សរ )។ ២.ស្រុកចុងកាល់ចំនួន០២សាលា (អនុវិទ្យាល័យ សម្តេចតេជោ ហ៊ុនសែន ចុងកាល់ និងអនុវិទ្យាល័យ ដើងទៀន)។ ៣.ស្រុកបន្ទាយអំពិល ចំនួន០២សាលា (អនុវិទ្យាល័យគោកឪឡោកនិងអនុវិទ្យាល័យបេង)។ និង៤.ស្រុកអន្លង់វែងចំនួន០២ សាលា(អនុវិទ្យាល័យ តេជោអូរស្រមរ និងអនុវិទ្យាល័យ ថ្លាត)។ ជាមួយគ្នានេះយើងបានទទួលទិន្នន័យ តាមរយៈការបំពេញកម្រងសំណួរ និងការសម្ភាសន៍ នាយក នាយិកា នាយករង ១២នាក់ស្រី០១នាក់ និងគ្រូបង្រៀន៦៦នាក់ស្រី២៨នាក់ សរុបចំនួន៧៨នាក់ ស្រី២៩នាក់។ ចំណែកកម្រងសំណួរចែកចែង ជាបួនផ្នែកគឺ ផ្នែកទី១៖ ព័ត៌មានទូទៅ គណៈគ្រប់គ្រង និងគ្រូបង្រៀន ផ្នែកទី២៖ ការដឹកនាំ និងគ្រប់គ្រង របស់នាយក និងគ្រូបង្រៀន ផ្នែកទី៣៖ បញ្ហាប្រឈម ក្នុងការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាល កំណត់ និងផ្នែកទី៤៖ ការយល់ឃើញរបស់គណៈគ្រប់គ្រង និងគ្រូបង្រៀនជុំវិញការងារអធិការកិច្ច។ បន្ទាប់មកយើងបានប្រើប្រាស់កម្មវិធី Microsoft Excel ដើម្បីធ្វើការវិភាគរៀបចំទិន្នន័យជា តារាង ក្រាប ភាគរយ និងអត្ថន័យខ្លឹមសារ។

ផ្អែកលើកលទ្ធផលនៃការវិភាគលើចំណុចអនុសាសន៍អធិការកិច្ច បានបង្ហាញថា (១).ការរៀបចំ ទីចាត់ការស្ថិតក្នុងកម្រិត ល្អបង្គួរ (២).ផែនការនិងការចុះអធិការកិច្ចថ្នាក់រៀន ស្ថិតក្នុងកម្រិត ខ្សោយ (៣).ការកែលម្អបរិស្ថានសាលារៀន ស្ថិតក្នុងកម្រិត ល្អបង្គួរ (៤).ការធ្វើកិច្ចតែការបង្រៀន ស្ថិតក្នុង កម្រិត ល្អបង្គួរ (៥).រដ្ឋបាលថ្នាក់និងរដ្ឋបាលគ្រូ ស្ថិតក្នុងកម្រិត ល្អបង្គួរ (៦).គុណភាពនិងលទ្ធផល សិក្សារបស់សិស្សមានការកើនឡើងជាបន្តបន្ទាប់ ស្ថិតក្នុងកម្រិត មធ្យម និង(៧).ការចូលរួមគាំទ្ររបស់ សហគមន៍ ស្ថិតក្នុងកម្រិតមធ្យម ។ ជារួមការអនុវត្តអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់ ស្ថិតក្នុងកម្រិត ល្អបង្គួរ(៦០-៧០%)។ ដោយឡែកចំណុចអនុសាសន៍ចំនួន០៣ ស្ថិតក្នុងកម្រិត ខ្សោយ និងមធ្យម គឺ ចំណុចទី២ ផែនការនិងចុះអធិការកិច្ចថ្នាក់រៀន (១៩.៨១%មិនបានអនុវត្ត) ចំណុចទី៦ គុណភាពលទ្ធផលសិក្សារបស់សិស្ស(១៤.៩៧%មិនកើនឡើង) និងចំណុចទី៧ ការចូលរួមគាំទ្ររបស់ សហគមន៍ ទិន្នន័យ ៣៤.៩០%។ វាជាបញ្ហាប្រឈមមួយដល់សាលារៀន មានន័យថាបើនាយកមិនបាន ចុះត្រួតពិនិត្យគ្រូបង្រៀន ដូច្នេះការបង្រៀនរបស់គ្រូក៏មិនបានល្អ។ បើខ្សោយទំនាក់ទំនងល្អជាមួយសហ

គមន៍ក៏ជាហេតុធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សមិនកើនឡើង ហើយការអភិវឌ្ឍសាលារៀនក៏នៅមានកម្រិតដែរ។ ករណីនេះទាមទារឱ្យនាយកសាលាខិតខំប្រឹងប្រែង អនុវត្តអនុសាសន៍អធិការកិច្ចឱ្យបានខ្ជាប់ខ្ជួនខានមិនបាន។ ទន្ទឹមនឹងនេះគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ ក៏មានបញ្ហាប្រឈមមួយចំនួនដែរ ដូចជា៖ នាយកសាលារៀន ៣៦.៣៦% មិនបានរក្សារបាយការណ៍អធិការកិច្ចឱ្យបានគត់មុត ហើយមិនបានស្វែងរកសម្រាប់ទុកជាឯកសារត្រួតពិនិត្យដើម្បីកែលម្អសាលារៀនឡើងវិញ។ គ្រូបង្រៀនជាង៥០% មិនបានបំប៉នចំណេះបន្ថែមលើមុខវិជ្ជាជីវៈរបស់ខ្លួន និងវិធីសាស្ត្រថ្មីៗសម្រាប់ដំណើរការបង្រៀនឱ្យស្របនឹងការរីកចម្រើននៃសង្គម។ គណៈគ្រប់គ្រង២៦.២៧%មិនធ្លាប់បានឆ្លងកាត់វគ្គបំប៉ន ឬសិក្ខាសាលាទាក់ទងនឹងការងារគ្រប់គ្រងរបស់ខ្លួនឡើយ។ ចំណុចនេះធ្វើឱ្យនាយកសាលាទាំងនោះខ្វះបទពិសោធន៍ និងចំណេះដឹងផ្នែកគ្រប់គ្រងសាលារៀនដូចគ្នាដែរ។

ដើម្បីឱ្យគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ មានការអនុវត្តអនុសាសន៍របាយការណ៍អធិការកិច្ចប្រកបដោយប្រសិទ្ធភាព ថ្នាក់ដឹកនាំមន្ទីរ ការិយាល័យអធិការកិច្ច ការិយាល័យពាក់ព័ន្ធ ក្រុមDTMTs និងអ្នកពាក់ព័ន្ធនានាគួរយកចិត្តទុកដាក់ពិនិត្យតាមដានសាលារៀនដែលបានចុះអធិការកិច្ចតាមកាលកំណត់រួច ដោយធានាថា ពួកគាត់បានទទួលរបាយការណ៍ និងរក្សាទុកបានត្រឹមត្រូវ ងាយរកយកមកប្រើប្រាស់បានទាន់ពេលវេលា។ ហើយសាលារៀនខ្លួនឯងគួរធ្វើផែនការនិងចុះអធិការកិច្ចថ្នាក់រៀន បង្កើនលទ្ធផលសិក្សារបស់សិស្ស និងទំនាក់ទំនងជាមួយសហគមន៍ឱ្យបានល្អ។ម្យ៉ាងទៀត មន្ទីរគួរបង្កើតឱ្យមានកម្មវិធីមួយឆ្នាំម្តងក្នុងការប្រជុំ ឬសិក្ខាសាលាពាក់ព័ន្ធនឹងការបង្កើនសមត្ថភាពគ្រូលើមុខវិជ្ជាឯកទេសវិធីសាស្ត្របង្រៀន និងជំនាញគ្រប់គ្រងដល់ គណៈគ្រប់គ្រងសាលារៀនផងដែរ។ ពិសេសគួរធ្វើផែនការចុះអធិការកិច្ចតាមកាលកំណត់ប្រចាំឆ្នាំដោយបន្ថែម៣០%នៃសាលារៀនដែលបានចុះអធិការកិច្ចតាមកាលកំណត់រួច ដើម្បីត្រួតពិនិត្យការអនុវត្តតាមអនុសាសន៍អធិការកិច្ច ក៏ដូចជាជួយដល់សាលារៀនដែលមានបញ្ហាប្រឈមបានទាន់ពេលវេលា។ ដោយឡែកចំពោះអ្នកស្រាវជ្រាវជំនាន់ក្រោយៗអាចធ្វើការសិក្សាបន្តដោយពង្រីកសំណាក និងវិសាលភាពសំណាក ព្រមទាំងរកវិធីសាស្ត្រល្អៗទាក់ទាញដល់ការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់ពីអ្នកពាក់ព័ន្ធ និងសាលារៀនឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត។

# Abstract

Implementing the recommendations in the school periodic inspection report is one of the priority activities of the school, which must pay attention to the participation of the inspection team in order to develop the school in accordance with Reform of the Ministry of Education, Youth and Sports. In addition, we have identified seven key points of recommendation in the Periodic Inspection Report, including: (1) Office Management, (2) Planning and Classroom Inspections, (3) Improving the School Environment, 4) Lesson Plan (5) Class administration and teacher administration (6) Quality and student achievement and (7) Community support. Seeing the benefits of promoting the development of schools and contributing to the implementation of reforms with the Ministry of Education, Youth and Sports, we decided to select the topic "Effectiveness of the implementation of periodic inspection reports of schools in Oddar Meanchey Province". For research to find out the effectiveness and challenges in the practical implementation of the school.

The research on the above topics has two main objectives: 1. Evaluate the effectiveness of the implementation of school periodic inspection report recommendations by the school. 2. Identify challenges in implementing the inspection report and make recommendations to improve Implement periodic inspection reports to schools.

This study focuses on the performance of principals and teachers in accordance with the recommendations in the periodic inspection report of secondary schools in Oddar Meanchey province, which conducted regular inspections from 2015 to 2020. We selected 11 secondary schools out of 16 secondary schools in 4 cities / districts: 1.Samrong City: 5 schools (Hun Sen Ruot Champey Secondary School, Surek Kun Por TiVong Secondary School, Bansay Reak Secondary School, Kon Kreal Secondary School, and Bosbov Secondary School). 2. Chongkal district, 2 schools (Samdech Techo Hun Sen Chongkal secondary school and Cheung Tien secondary school). 3.Banteay Ampil district, 2 schools (Kork Ov Lok Secondary School and Beng Secondary School). And 4. Anlong Veng district, 2 schools (Techo O Sramor Secondary School and Thlat Secondary School). In addition, we obtained data by completing questionnaires and interviews with 12 directors, deputy , 1 female and 66 teachers, 28

females, total 78, and 29 females. The questionnaire is divided into four sections: Part 1: General Information, Management and Teachers. Section 2: Leadership and Management of Principals and Teachers. Section 3: Challenges in the implementation of periodic inspection reports and Section 4: Opinions of management and teachers on inspection work. We then used Microsoft Excel to analyze and organize the data into tables, graphs, percentages, and content.

Based on the results of the analysis of the inspection recommendations, it is shown that (1) the organization of the management is in a Fairly good, (2) the planning and inspection of the classrooms are weak (3) Improving the school environment is in a Fairly good (4). Teaching work is at a Fairly good (5). Class administration and teacher administration are at a fairly good (6) The quality and outcomes of students have been steadily increasing at a Medium level; and (7) Community support has been at a Medium level. Overall, the implementation of the recommendations of the periodic inspection report is fairly good (60-70%).Separately; three recommendations are in the weak and medium level: the second point is the plan and inspection of classrooms (19.81% did not implement), the sixth point is the quality of students' academic results (14.97% did not increase) and point 7. Community support data 34.90%. It is a challenge for the school, meaning that if the principal does not inspect the teachers, then the teachers' teaching is not good. Weak communication with the community also results in a drop in student achievement and limited school development. This case requires the principal to work hard to implement the inspection recommendations consistently. At the same time, the management of teachers also has some challenges, such as: 36.36% of school principals did not keep accurate inspection reports and did not search for inspection documents to improve schools. More than 50% of teachers do not supplement their professional knowledge and new methods for teaching process in line with the progress of society. 26.27% of the management never went through any training or seminars related to their management work. This makes the principals lack the same experience and knowledge of school management.

In order for the management and teachers to implement the recommendations of the inspection report effectively, the management of the inspection department, the relevant office, the DTMTs and other stakeholders should pay attention to monitor the schools that have been inspected on a regular basis,

Ensuring that they receive reports and keep them accurate, easy to find and use in a timely manner. And the school itself should plan and inspect classrooms, improve student achievement and better communicate with the community. In addition, the department should establish a program once a year in meetings or workshops related to capacity building of teachers in specialized subjects, teaching methods and management skills to the school management. In particular, regular annual inspections should be planned, with an additional 30% of schools already inspected on a regular basis to monitor compliance with inspection recommendations, as well as assist schools in a timely manner. In particular, the next generation of researchers can continue to study by expanding the sample and the scope of the sample, as well as find better ways to attract the implementation of periodic inspection reports from stakeholders and schools to further improve.

# ជំពូកទី១

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ក្នុងបរិបទថ្មីនៃការវិវឌ្ឍរបស់ពិភពលោកបានទាមទារឱ្យមនុស្សបង្កើនការយកចិត្តទុកដាក់ខ្ពស់ទៅលើការងារអប់រំ។ ទន្ទឹមនឹងនោះសាលារៀន គឺជាថ្នាលបណ្តុះធនធានអប់រំមួយដែលចាំបាច់ត្រូវយកចិត្តទុកដាក់ និងធ្វើការកែលម្អមុនគេដើម្បីឱ្យជះឥទ្ធិពលទៅដល់ផ្នែកពាក់ព័ន្ធដទៃទៀត។ស្របគ្នានេះខ្លឹមសារ «ការអប់រំប្រកបដោយចីរភាព និងធានាការអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា»ត្រូវបានកំណត់ជាគោលនយោបាយរួមគ្នាមួយក្នុងឱកាសសន្និសិទ្ធនៅក្រុងអ៊ីនឈុន(Incheon)សាធារណរដ្ឋកូរ៉េក្នុងខែឧសភា ឆ្នាំ២០១៥ (ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០១៨)

ឈរលើគោលនយោបាយនេះរាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី៥ បានដាក់ចេញនូវយុត្តិសាស្ត្រចតុកោណដំណាក់កាលទី៣ ដែលនោះវិស័យអប់រំស្ថិតនៅមុំទី៤ គឺការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្សផ្អែកលើអភិបាលកិច្ចល្អជាស្នូល។ រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់លើ « វិស័យអាទិភាព៤ » ដូចជា ការពង្រឹងគុណភាពវិស័យអប់រំ ការលើកកម្ពស់សេវាសុខាភិបាល ការអនុវត្តគោលនយោបាយសមភាពយេនឌ័រនិងការអនុវត្តគោលនយោបាយប្រជាជន។ ទន្ទឹមនឹងនោះការអភិវឌ្ឍធនធានមនុស្សដែលជានាបាននូវការប្រកួតប្រជែងក្នុងទីផ្សារពលកម្ម ក្នុងតំបន់ដែលកាន់តែបើកចំហតាមរយៈ ១.ការបណ្តុះបណ្តាលពលករឱ្យមានជំនាញ និងផលិតភាពខ្ពស់ តាមសេចក្តីត្រូវការនៃទីផ្សារ និងអាចបង្កើតតម្លៃខ្ពស់ ២.ការរៀបចំក្របខណ្ឌគតិយុត្ត និងកសាងស្ថាប័ន អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលឆ្លើយតបទៅនឹងចំណុចទី១ខាងលើ ៣.ការលើកទឹកចិត្តវិស័យឯកជនឱ្យចូលរួមក្នុងកិច្ចការនេះ និង៤.ការពង្រឹងគុណភាពនៃការអប់រំ និងការលើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ។

ស្របគ្នានឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣នៃរាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា បានឈានដល់ដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍវិស័យអប់រំ ឆ្លើយតបនឹងបរិបទតំបន់

សកលលោក ដែលមានមហិច្ឆតា និងវិសាលភាពធំទូលាយជាងមុន សំដៅលើកកម្ពស់គុណភាពអប់រំប្រកបដោយសមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិត ក្នុងក្របខណ្ឌទូលំទូលាយ គ្របដណ្ដប់លើគ្រប់ប្រភេទ និងកម្រិតនៃការអប់រំ ជាពិសេស ស្របនឹងទស្សនវិស័យអប់រំអភិវឌ្ឍន៍កម្ពុជាជាប្រទេស មានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ (ក្រសួងអប់រំ យុវជន និងកីឡា,២០១៩) ម្យ៉ាងទៀតក្រសួងបានបង្កើតនូវ គោលនយោបាយអប់រំចំនួនបីសំខាន់ៗដូចជា៖ **គោលនយោបាយទី១៖** ធានាលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌។ **គោលនយោបាយទី២៖** លើកកម្ពស់គុណភាព និងភាពឆ្លើយតប។ **គោលនយោបាយទី៣៖** ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ដើម្បីធានាដល់វិស័យអប់រំកាន់តែមានការអភិវឌ្ឍ និងដើរឱ្យទាន់ការរីកចម្រើនរបស់ប្រទេសជាតិ ក្រសួងបានដាក់ចេញសសរស្តម្ភចំនួន៥ដែលក្នុងនោះមានសសរស្តម្ភទី៣៖ ការដាក់ឱ្យអនុវត្តអធិការកិច្ច ជាសសរស្តម្ភមួយអាទិភាពសម្រាប់ដំណើរការត្រួតពិនិត្យសាលារៀននូវការដឹកនាំនិងគ្រប់គ្រង ការបង្រៀននិងរៀន លទ្ធផលសិក្សារបស់សិស្ស និងទំនាក់ទំនងជាមួយសហគមន៍ មាតាបិតាសិស្ស។ លើសពីនេះដើម្បីប្រែក្លាយវិស័យអប់រំនៅកម្ពុជាឱ្យកាន់តែមានល្បឿនខ្លាំងបន្ថែមទៀត ក្រសួងក៏បានផ្តើមធ្វើកំណែទម្រង់១៥ចំណុច ដែលក្នុងនោះមានចំណុចកំណែទម្រង់ទី៥ ការងារអធិការកិច្ច រឹតតែផ្តល់អាទិភាពច្បាស់ឡើងក្នុងការអនុវត្ត។ ឆ្លើយតបនឹងការដាក់ចេញនូវកំណែទម្រង់នេះ នាយកដ្ឋានធានាគុណភាពអប់រំមានភារកិច្ចចម្បងក្នុងការអនុវត្តលើសសរស្តម្ភទី៣៖ ការដាក់ឱ្យអនុវត្តអធិការកិច្ច និងកំណែទម្រង់ទី៥៖ ការងារអធិការកិច្ច ដោយខានពុំបានផ្តោតលើអធិការកិច្ចតាមប្រធានបទ និងអធិការកិច្ចតាមកាលកំណត់។ ក្នុងន័យនេះអធិការកិច្ចតាមកាលកំណត់ ត្រូវបានអនុវត្តឡើងដោយមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ដែលមានការិយាល័យអធិការកិច្ចជាអ្នកប្រតិបត្តិផ្ទាល់។ ភារកិច្ចនេះបានធ្វើឱ្យក្រុមការងារអធិការកិច្ចថ្នាក់រាជធានីខេត្តបំពេញកិច្ចការរបស់ខ្លួន ទៅតាមសមត្ថកិច្ចនៃវិសាលភាពការងារដែលត្រូវទទួលខុសត្រូវចំពោះមុខ។ ជាក់ស្តែងការិយាល័យអធិការកិច្ចនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ បានអនុវត្តការងារអធិការកិច្ចតាមកាលកំណត់តាំងពីឆ្នាំ២០១៥មកម្លេះ។ ក្នុងរយៈពេលប្រមាណជា៥ឆ្នាំមកនេះក្រុមការងារអធិការ

កិច្ចបានចុះចំនួន១៣៨សាលា ក្នុងនោះផ្នែបឋមសិក្សា ១១៧សាលា ផ្នែកមធ្យមសិក្សាបឋមភូមិ១៨សាលា និងផ្នែកមធ្យមសិក្សាទុតិយភូមិ០៣សាលា។ ក្រុមការងារបានរកឃើញចំណុចល្អ ចំណុចដែលត្រូវកែលម្អ បញ្ហាប្រឈម និងបានដាក់ជាអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់ដល់សាលារៀន ដើម្បីធ្វើការកែលម្អចំណុចខ្វះខាតរបស់ខ្លួន ក្នុងអំឡុងវដ្តរយៈ ៥ឆ្នាំ។ ម្យ៉ាងទៀងក្រុមការងារអធិការកិច្ចបានផ្តល់របាយការណ៍អធិការកិច្ចតាមកាលកំណត់ចំនួន០១ច្បាប់ ដល់សាលារៀនតាមរយៈការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកដើម្បីតម្កល់ទុកអនុវត្ត។ ក្នុងចំណោមសាលាមធ្យមសិក្សាបឋមភូមិចំនួន១៨ យើងបានធ្វើការជ្រើសរើសយកជាសាលាសំណាកដោយប្រើប្រាស់កម្មវិធី Random សម្រេចបានត្រឹមចំនួន១១សាលា ជាសាលាគោលដៅសម្រាប់ចុះសិក្សាស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ ទៅតាមផែនការនៃការសិក្សានិងផែនការស្រាវជ្រាវ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្នុងរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់ការិយាល័យអធិការកិច្ច នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ បានបង្ហាញឱ្យឃើញថា សាលារៀនពិតជាបានអនុវត្ត តាមរយៈការផ្តល់អនុសាសន៍ក្នុងរបាយការណ៍អធិការកិច្ចតាមកាលកំណត់ប្រាកដមែន ប៉ុន្តែក្នុងការអនុវត្តនេះក៏នៅមានសាលារៀនមួយចំនួនមិនយករបាយការណ៍អធិការកិច្ចតាមកាលកំណត់ ទៅប្រើប្រាស់ក្នុងការអភិវឌ្ឍអង្គភាពរបស់ខ្លួនបានត្រឹមត្រូវឡើយ។ ករណីនេះបណ្តាលមកពី សាលារៀនមួយចំនួននោះ ទុកដាក់របាយការណ៍អធិការកិច្ចតាមកាលកំណត់មិនបានល្អ ជាហេតុធ្វើឱ្យបាត់បង់រកមិនឃើញក្នុងពេលត្រូវការប្រើប្រាស់ ហើយសាលាមួយចំនួនទៀតមិនទាន់បានទទួលរបាយការណ៍ទាំងដែលក្រុមការងារអធិការកិច្ចបានបញ្ជូនរួចរាល់ហើយក៏ដោយ។ ចំណែកសាលារៀនដែលបានទទួលរបាយការណ៍រួចហើយនោះក្តីក៏ការអនុវត្តមិនបានគ្រប់ជ្រុងជ្រោយ ហាក់បីដូចជាមិនចាប់អារម្មណ៍ក្នុងការយកអនុសាសន៍របស់ក្រុមការងារអធិការកិច្ច មកធ្វើជាចំណុចអាទិភាពដាក់ក្នុងផែនការអភិវឌ្ឍសាលារៀនរបស់ខ្លួនឡើយ។ (ការិយាល័យអធិការកិច្ច នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ, ឆ្នាំ២០២០)។ ចំណុចទាំងអស់នេះហើយទើបបណ្តាលឱ្យយើងសម្រេចជ្រើសរើសយកប្រធានបទថា « **ប្រសិទ្ធភាពនៃការអនុវត្តរបាយការណ៍**

**អធិការកិច្ចតាមកាលកំណត់របស់សាលារៀនក្នុងខេត្តឧត្តរមានជ័យ»** មកធ្វើការសិក្សាស្រាវជ្រាវទុកជាជំនួយស្មារតី ដល់នាយកសាលា ឱ្យមានការទទួលខុសត្រូវ ចំពោះអង្គភាពរបស់ខ្លួនក្នុងការអនុវត្តអនុសាសន៍របាយកាណ៍អធិការកិច្ចតាមកាលកំណត់ និងស្វែងរកដើមចងដែលបណ្តាលឱ្យមានបញ្ហាប្រឈមទាំងឡាយក្នុងការអនុវត្តប្រែក្លាយជាដំណោះស្រាយដ៏មានប្រសិទ្ធភាព។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការលើកយកប្រធានបទនេះមកធ្វើការសិក្សាស្រាវជ្រាវមានគោលបំណងចំនួនពីរគឺៈ

១.វាយតម្លៃប្រសិទ្ធភាព នៃការអនុវត្តអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀនដោយសាលារៀន។

២.កំណត់បញ្ហាប្រឈមក្នុងការអនុវត្តអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់និងដាក់ចេញនូវអនុសាសន៍ កែលម្អការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់ដល់សាលារៀន។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបនឹងគោលបំណងនៃការស្រាវជ្រាវខាងលើ យើងមានសំណួរស្រាវជ្រាវចំនួនពីរដូចខាងក្រោមគឺៈ

១.តើប្រសិទ្ធភាព នៃការអនុវត្តអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀនដោយសាលារៀនមាន លក្ខណៈយ៉ាងដូចម្តេចខ្លះ?

២.តើមានបញ្ហាប្រឈមអ្វីខ្លះក្នុងការអនុវត្តអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់នៅសាលារៀន?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះផ្តល់សារៈសំខាន់ ជាច្រើនដល់វិស័យអប់រំ ពិសេសគាំទ្រដល់ការធ្វើកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ផ្តល់នូវចំណេះដឹង និងបទពិសោធន៍ដល់អ្នកសិក្សាស្រាវជ្រាវនានាដែលមានបំណងចង់សិក្សា ជាបន្តបន្ទាប់ពាក់ព័ន្ធនឹងប្រធានបទខាងលើ។ ម្យ៉ាងទៀតវាបានផ្តល់

ឱកាស ដល់នាយកសាលា លោកគ្រូ អ្នកគ្រូ ក្នុងការចូលរួមកែលម្អការងារ របស់ខ្លួនពាក់ព័ន្ធនឹងការដឹកនាំ និងគ្រប់គ្រង ការបង្រៀននិងរៀន រដ្ឋបាលថ្នាក់ រដ្ឋបាលគ្រូ បរិស្ថាន និងការតុបតែងលម្អនានា ព្រមទាំងបង្កើនទំនាក់ទំនងល្អរវាងគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀន គ្រូបង្រៀននិងគ្រូបង្រៀន គ្រូបង្រៀននិងសិស្សានុសិស្ស សាលារៀន និងសហគមន៍ជាដើម។ តាមរយៈប្រធានបទនេះក៏ជាសូចនាករមួយក្នុងការជំរុញឱ្យ នាយកសាលា គ្រូបង្រៀន អាចមានឱកាសទទួលបានស្នាដៃ ជាសាលាស្អាត នាយកល្អ គ្រូល្អ គ្រូឆ្នើមជាដើម។ម្យ៉ាងទៀតដើម្បីធានា ថាសាលារៀនមានប្រសិទ្ធភាពក្នុងការអនុវត្តបាយការណ៍អធិការកិច្ចតាមកាលកំណត់ យើងបានកំណត់គោលសំខាន់ៗចំនួន០៧ចេញពីអនុសាសន៍នៃរបាយការណ៍អធិការកិច្ចតាមកាលកំណត់ដែលបានដាក់ឱ្យសាលាអនុវត្តដូចជា ១.ការរៀបចំទីចាត់ការ ២.ការធ្វើផែនការ និងការចុះអធិការកិច្ចថ្នាក់រៀន ៣.ការកែលម្អបរិស្ថានសាលារៀន ៤.ការធ្វើកិច្ចតែងការបង្រៀន ៥.ការងាររដ្ឋបាលថ្នាក់ និងរដ្ឋបាលគ្រូ ៦.ការលើកម្ពស់គុណភាព និងលទ្ធផលសិក្សារបស់សិស្សឱ្យមានការកើនឡើងជាបន្តបន្ទាប់ និង៧.ការចូលរួមគាំទ្ររបស់សហគមន៍។ ផ្អែកលើកចំណុលគោលទាំង០៧នេះ បើករណីសាលារៀនអនុវត្តបានចាប់ពីលើ៣.៥ចំណុចឡើងទៅមានន័យថា សាលារៀនអនុវត្តរបាយការណ៍អធិការកិច្ចមានប្រសិទ្ធភាព ហើយបើសាលារៀនអនុវត្តបានក្រោម ៣.៥ មានន័យថា សាលាអនុវត្តអនុសាសន៍អធិការកិច្ចពុំទាន់មានប្រសិទ្ធភាពឡើយ។ ម្យ៉ាងទៀតបើសាលារៀនទាំង១១អាចអនុវត្តបានចាប់ពី៥.៥សាលាឡើងលើមានន័យថា សាលាភាគច្រើនបានអនុវត្តការងាររបស់ខ្លួនដោយយករបាយការណ៍អធិការកិច្ចជាមូលដ្ឋានក្នុងការអភិវឌ្ឍសាលារៀនប្រកបដោយប្រសិទ្ធភាពដែរ។ ប៉ុន្តែបើចំនួនសាលារៀនអនុវត្តតិចជាង ៥.៥ ហើយមិនបានអនុវត្តបានល្អច្រើនជាងចំនួននេះមានន័យថា សាលារៀនមិនទាន់បានចូលរួមអនុវត្តរបាយការណ៍ប្រកបដោយប្រសិទ្ធភាពឡើយ។

## ១.៦. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវលើប្រធានបទ « **ប្រសិទ្ធភាពនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀនក្នុងខេត្តឧត្តរមានជ័យ** » ធ្វើឡើងដោយផ្តោតទៅលើអនុវិទ្យាល័យចំនួន១១ដែលបានចុះអធិការកិច្ចតាមកាលកំណត់រួចចាប់ពីឆ្នាំ២០១៥រហូតដល់ឆ្នាំ២០២០ នៅក្នុងក្រុង/ស្រុកចំនួន

០៤នៃខេត្តឧត្តរមានជ័យគឺ ១.ក្រុងសំរោងមាន០៥សាលាគឺ ១.អនុវិទ្យាល័យ ហ៊ុន សែនរួតចំប៉ី ២.អនុវិទ្យាល័យ ស៊ូវ៉ែកគុណពោធិវង្ស ៣.អនុវិទ្យាល័យបន្សាយរាក់ ៤.អនុវិទ្យាល័យកូនក្រៀល ៥.អនុវិទ្យាល័យបុស្សូវ។ ២.ស្រុកចុងកាល់មាន០២សាលាគឺ ១.អនុវិ.សម្ដេចតេជោ ហ៊ុន សែន ចុងកាល់ ២.អនុវិទ្យាល័យជើងទៀន។៣.ស្រុកបន្ទាយអំពិលមាន០២សាលាគឺ១.អនុវិទ្យាល័យគោកឪឡោក ២.អនុវិទ្យាល័យបេង។ ៤.ស្រុកអន្លង់វែងមាន០២សាលាគឺ ១.អនុវិទ្យាល័យ តេជោ អូរស្រមរ និង ២.អនុវិទ្យាល័យ ថ្លាត។ ការសម្រេច និងកំណត់យកសាលារៀនបែបនេះគឺផ្អែកទៅលើបរិបទបច្ចុប្បន្នភាពនៃកិច្ចដំណើរការសាលារៀន ពេលវេលា ថវិកា និងសង្គមជាតិផងដែរ។

## ១.៧ រចនាសម្ព័ន្ធស្រាវជ្រាវ

ក្នុងអត្ថបទស្រាវជ្រាវនេះ មានប្រាំជំពូក ហើយក្នុងជំពូកនីមួយៗមានដូចជា៖

**ជំពូកទី១** លើកឡើងពី សេចក្ដីផ្ដើមនៃការស្រាវជ្រាវ រួមមាន៖ លំនាំបញ្ហា ចំណោទបញ្ហា គោលបំណង សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធ ។

**ជំពូកទី២** លើកឡើងពី ការរំឭកទ្រឹស្ដី ដែលក្នុងនោះរួមមាន៖ ការសិក្សាពាក្យគន្លឹះ ក្របខណ្ឌជានាគុណភាពអប់រំ ប្រព័ន្ធអធិការកិច្ចអប់រំ និងអធិការកិច្ចតាមកាលកំណត់ ។

**ជំពូកទី៣** លើកឡើងពី វិធីសាស្ត្រនៃការស្រាវជ្រាវ ដែលក្នុងនោះរួមមាន៖ គម្រោងវិភាគ ការប្រមូលទិន្នន័យ ឧបករណ៍ស្រាវជ្រាវ ការជ្រើសរើសភាគសំណាក និងការវិភាគទិន្នន័យ។

**ជំពូកទី៤** លើកឡើងពី លទ្ធផលនៃការស្រាវជ្រាវ រួមមាន៖ ឧបករណ៍វិភាគទិន្នន័យ ដំណាក់កាលនៃការវិភាគទិន្នន័យ ការវិភាគទិន្នន័យតាមកម្រងសំណួរជាបន្តបន្ទាប់។

**ជំពូកទី៥** លើកឡើងពី សេចក្ដីសន្និដ្ឋាន និងសំណូមពរ ដែលក្នុងជំពូកចុងក្រោយនេះ យើងនឹងបង្ហាញពីអ្វីដែលបានរកឃើញទាក់ទងនឹងការអនុវត្តអនុសាសន៍របាយការណ៍អធិការកិច្ច បញ្ហាប្រឈម និងការលើកឡើងជាទស្សនទានដល់ ភាគីពាក់ព័ន្ធ ក្នុងការអនុវត្តអនុសាសន៍អធិការកិច្ច ព្រមទាំងសំណូមពរមួយចំនួន ដើម្បីធ្វើឱ្យការអនុវត្តអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់ប្រកបដោយប្រសិទ្ធភាព។

# ជំពូកទី២

# ជំពូកទី២
# រំលឹកទ្រឹស្តី

## ២.១. ការសិក្សាពាក្យគន្លឹះ

ដើម្បីឱ្យកាន់តែមានភាពច្បាស់លាស់ក្នុងការសិក្សាស្រាវជ្រាវទាក់ទងនឹងប្រធានបទនិក្ខេបបទនេះ យើងគួរគប្បីស្គាល់ពីពាក្យគន្លឹះមួយចំនួនដូចជា៖

**ប្រសិទ្ធភាព** បានន័យថា៖ ភាពដែលផ្តល់ផលល្អ ផ្តល់ប្រយោជន៍សមបំណង។ ឧទាហរណ៍៖ការគ្រប់គ្រងមានប្រសិទ្ធភាព ថ្នាំមានប្រសិទ្ធភាព។ (Wiktionary, 2021) (វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ ២០០៨)

**ការអនុវត្ត** បានន័យថា៖ ការប្រព្រឹត្តតាម, ការធ្វើតាម, ការបណ្តោយតាម; អនុរោធ ។ (វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ ២០០៨)

**របាយការណ៍អធិការកិច្ចតាមកាលកំណត់**បានន័យថា៖ ជាលទ្ធផលរួមមួយក្រោយចុះអធិការកិច្ចតាមកាលកំណត់និងសរសេរដោយក្រុមអធិការកិច្ចទៅតាមគោលការណ៍អធិការកិច្ច សូចនាករ ចំណុចល្អ ចំណុចគួរកែលម្អ បញ្ហាប្រឈម និងដាក់ចេញជាអនុសាសន៍ដល់សាលារៀន និងអ្នកពាក់ព័ន្ធអនុវត្ត។

**អធិការកិច្ចតាមកាលកំណត់គឺ** ជាការពិនិត្យ និងវាយតម្លៃសាលារៀនទាំងអស់ជាប្រព័ន្ធដើម្បីធានាថា ពួកគេបានគោរពតាមច្បាប់ និងបទប្បញ្ញត្តិរបស់ជាតិ ដែលទាក់ទងនឹងភារកិច្ចរបស់ខ្លួន។ ការវាយតម្លៃគឺផ្អែកលើការបកស្រាយបទប្បញ្ញត្តិរបស់ជាតិ។ លទ្ធផលដែលបានមកនឹងបង្ហាញអំពីកិច្ចការណាខ្លះដែលមានដំណើរការ និងកិច្ចការណាខ្លះទៀតដែលត្រូវការកែលម្អ។ (ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ), ២០១៦)

## ២.២.ក្របខណ្ឌធានាគុណភាព

ការធានាគុណភាពគឺសំដៅលើសកម្មភាពទាំងឡាយណាបានគ្រោង និងមានលក្ខណៈជាប្រព័ន្ធ ហើយត្រូវបានអនុវត្តក្នុងប្រព័ន្ធមួយ ឬអង្គភាពមួយ ដើម្បីធ្វើឱ្យតម្រូវការផ្នែកគុណភាពត្រូវបានបំពេញ ហើយអង្គភាពនោះត្រូវផ្តល់នូវផលិតផលល្អបំផុត។ សកម្មភាពធានាគុណភាពអប់រំនឹងផ្តោតលើការពង្រឹង

និងកែលម្អដំណើរការដែលត្រូវប្រើប្រាស់ ដើម្បីបង្កើតលទ្ធផលចុងក្រោយ។ ចំពោះប្រព័ន្ធអប់រំកម្ពុជា សកម្មភាពធានាគុណភាពមានន័យថាធ្វើឱ្យកុមារ ឬសិស្សទាំងអស់ទទួលបាននូវចំណេះដឹង ជំនាញ សមត្ថភាព សេចក្ដីថ្លៃថ្នូរ អាកប្បកិរិយាប្រកបដោយសីលធម៌សំដៅជំរុញឱ្យអ្នកសិក្សាស្គាល់ ស្រឡាញ់ និងការពារអត្តសញ្ញាណ វប្បធម៌ និងភាសាជាតិ។ ការធានាគុណភាពមានភាពសាំញ៉ាំណាស់។ ក្របខណ្ឌធានាគុណភាពអប់រំ រួមផ្សំដោយសមាសភាគ និងសកម្មភាពមួយចំនួនដែលត្រូវបានផ្សារភ្ជាប់គ្នាតាំងពីថ្នាក់ក្រោមរហូតដល់ថ្នាក់លើបំផុត។ ការធានាគុណភាពមានន័យថាត្រូវធ្វើការជាមួយគ្រប់សកម្មភាពទាំងអស់។ វត្ថុបំណងរបស់គោលការណ៍ទាំងនេះ គឺសម្រាប់បង្ហាញផ្លូវដល់អ្នកអនុវត្ត នាយកសាលារៀន និងគ្រូបង្រៀនដែលជាអ្នកដឹកនាំ និងអនុវត្តភារកិច្ចទាំងនេះ។(ក្រសួងអប់រំយុវជន និងកីឡា(នាយកដ្ឋានបណ្ដុះបណ្ដាលនិងវិក្រឹតការ),២០១៦)

## ២.២.១.សកម្មភាពសំខាន់ៗក្នុងដំណើរការធានាគុណភាព

**-ការពិនិត្យតាមដាន និងការត្រួតពិនិត្យ** ជារឿយៗសកម្មភាពនេះត្រូវផ្អែកលើលទ្ធផលស្ថិតិ ។ សកម្មភាពនេះត្រូវបានអនុវត្ត ដើម្បីពិនិត្យមើលឱ្យបានស៊ីជម្រៅទៅលើដំណើរការជាប្រព័ន្ធដែលបានគ្រោង ដើម្បីបំពេញតម្រូវការ។

**-ការវិភាគ** ប្រើប្រាស់ទិន្នន័យដែលប្រមូលបានទាំងអស់ ដើម្បីធ្វើការសន្និដ្ឋានលើដំណើរការពិនិត្យតាមដាន់និងការត្រួតពិនិត្យ។

**-សេចក្ដីសន្និដ្ឋាន** ធ្វើការសម្រេចចិត្តចំណុចណាខ្លះ ដែលមិនទាន់បានល្អហើយត្រូវបង្កើតវិធានការដើម្បីកែលម្អ។

**-ការផ្ដល់ព័ត៌មានត្រឡប់** អនុវត្តសកម្មភាពដើម្បីកែប្រែ ឥរិយាបថ និងកែលម្អលទ្ធផល។

**-វិធានការថ្មី** សកម្មភាពទាំងនេះមានតួនាទីសំខាន់ៗបួនគឺ៖ ១.ការអនុវត្ត ផ្ដល់គណនេយ្យភាពដោយផ្អែកលើការវាយតម្លៃ ២.ការផ្ដល់ព័ត៌មាន ផ្ដល់លទ្ធផលជូនរដ្ឋាភិបាលផ្អែកលើចំណេះដឹង និងបទពិសោធន៍ទូទាំងប្រទេស។ ផ្ដល់ព័ត៌មានត្រឡប់ទៅសាលារៀន និងសាធារណជន ដោយផ្អែកលើចំណេះដឹង និងបទពិសោធន៍ទូទាំងប្រទេស។ ៣.ការផ្ដល់មូលដ្ឋានសម្រាប់វាយតម្លៃដំណើរការ ៤.និងកំណត់

ផ្នែកដែលត្រូវធ្វើការកែលម្អ។

ក្រៅពីការវាស់វែងប្រព័ន្ធតាមស្តង់ដា **ការពិនិត្យតាមដាន** និង**ការត្រួតពិនិត្យ** ត្រូវតែផ្សារភ្ជាប់ទៅនឹងដំណើរការផ្តល់ព័ត៌មានត្រឡប់ដើម្បីបង្ការកំហុស និងលទ្ធផលមិនល្អ។ ដំណើរការផ្តល់ព័ត៌មានត្រឡប់ក៏ត្រូវរួមបញ្ចូលផងដែរ នូវការណែនាំសាលារៀន ដើម្បីឈានទៅសម្រេចវត្ថុបំណងរបស់ខ្លួន។ ពាក្យ**អធិការកិច្ច**ជារឿយៗគឺសំដៅទៅលើការត្រួតពិនិត្យ ដែលជាពាក្យមានន័យអវិជ្ជមាន ប៉ុន្តែអធិការកិច្ចក៏ជាឧបករណ៍មួយសម្រាប់អនុវត្ត និងកែលម្អផងដែរ។ ការត្រួតពិនិត្យតាមដាន និងវាយតម្លៃបានផ្តល់ព័ត៌មានសំខាន់ដែលអាចប្រើប្រាស់សម្រាប់ណែនាំ និងផ្តល់យោបល់ផងដែរ។ ដូចនេះការងារ ការងារអធិការកិច្ច ត្រូវតែចូលរួមផ្តល់វិភាគទានដល់ការអភិវឌ្ឍ និងអនុវត្តជាប្រចាំ ដើម្បីឱ្យប្រព័ន្ធស្វ័យវាយតម្លៃមានប្រសិទ្ធភាពនៅគ្រប់សាលារៀនទាំងអស់។ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៥)

### ២.២.២.មូលដ្ឋានគតិយុត្តិសម្រាប់ធានាគុណភាពនិងការធ្វើអធិការកិច្ច

ច្បាប់ លិខិត បទដ្ឋាន គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងបទប្បញ្ញត្តិនានាគឺជាការសម្រេចចិត្តផ្នែកនយោបាយក្នុងគោលដៅកែលម្អ និងធានាគុណភាពអប់រំ នៅក្នុងប្រព័ន្ធសាលារៀនក្នុងប្រទេសកម្ពុជា។ កម្រងឯកសារគតិយុត្តទាំងនោះគឺជាមូលដ្ឋានសម្រាប់ធានាគុណភាព និងការធ្វើអធិការកិច្ច។ ភាគច្រើននៃកម្រងឯកសារត្រូវបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ការប្រើប្រាស់កម្រងឯកសារគតិយុត្តដែលបានអនុម័តហើយត្រូវបានយកមកធ្វើជាមូលដ្ឋានសម្រាប់ធានាគុណភាព និងការធ្វើអធិការកិច្ចហើយគឺជំហានមួយនៃការអនុវត្តបទប្បញ្ញត្តិក្នុងការងារប្រចាំថ្ងៃនៅតាមសាលារៀនក្នុងប្រទេសកម្ពុជា។ ផ្នែកនេះនឹងពិពណ៌នាអំពីមូលដ្ឋានគតិយុត្តសម្រាប់ធានាគុណភាពនិងការធ្វើអធិការកិច្ចនៅសាលារៀនក្នុងប្រទេសកម្ពុជា។

## ២.៣.ប្រព័ន្ធអធិការកិច្ចអប់រំ

### ២.៣.១.តួនាទីអធិការ

អធិការមានតួនាទីជាមន្ត្រីគ្រប់គ្រងអប់រំនិងជាសេនាធិការរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលត្រូវបានតែងតាំងឱ្យបំពេញភារកិច្ចនៅថ្នាក់ក្រសួង (នាយកដ្ឋានធានាគុណភាពអប់រំ) និងការិយាល័យ

អធិការនៅថ្នាក់រាជធានី-ខេត្តតាមការចាំបាច់ និងតាមតម្រូវការ។ ក្នុងតួនាទីនេះអធិការត្រូវមានមនសិការ និងស្មារតីទទួលខុសត្រូវខ្ពស់ចំពោះមុខក្រសួង ចំពោះមុខរាជធានី-ខេត្ត ដោយខិតខំធ្វើឱ្យឃើញច្បាស់ពីការរួមចំណែករបស់ខ្លួនក្នុងការលើកកម្ពស់គុណភាពអប់រំ តាមរយៈការងារអធិការកិច្ច។ ទន្ទឹមនឹងតួនាទីនេះអធិការ ត្រូវដើរតួសំខាន់៤ដូចខាងក្រោម៖

-តំណាងអាជ្ញាធរមានសមត្ថកិច្ចតំណាងឱ្យក្រសួងអប់រំ យុវជន និងកីឡា។

-ជាអ្នកបច្ចេកទេសត្រួតពិនិត្យលើគ្រប់មុខវិជ្ជាទាំងផ្នែកភាសា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម។

-ជាគ្រូឧទ្ទេសពេលជួបបញ្ហានីមួយៗមានការប្រជុំគរុកោសល្យត្រង់ៗ និងជាសម្ងាត់។

-ធ្វើអធិការកិច្ចលើប្រព័ន្ធសាលារៀនទាំងមូល។

ក្រៅពីតួនាទីខាងលើអធិការនៅមានភារកិច្ច៥ជាមូលដ្ឋានទៀតគឺ៖ ១.ការណែនាំ ការអនុវត្តគោលនយោបាយអប់រំ ២.ជាអ្នកវាយតម្លៃ ៣.ជាអ្នកធ្វើអធិការកិច្ច ៤.ជាទីប្រឹក្សាគុកោសល្យ និង ៥.ជាអ្នកផ្តល់ការវិនិច្ឆ័យផ្សេងៗតាមផ្លូវច្បាប់។ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៥)

### ២.៣.២.វិធីសាស្ត្រអធិការកិច្ច

អធិការកិច្ចអាចអនុវត្តបានតាមវិធីសាស្ត្រផ្សេងៗគ្នា។ ក្នុងការស្រាវជ្រាវនេះនឹងលើកយកតែអធិការកិច្ចផ្ទៃក្នុង និងអធិការកិច្ចផ្ទៃក្រៅប៉ុណ្ណោះ។

**អធិការកិច្ចផ្ទៃក្នុង** គឺផ្អែកលើការធ្វើស្វ័យវាយតម្លៃសាលារៀន ដែលអនុវត្តដោយនាយកសាលារៀន គ្រូបង្រៀន និងសិស្សានុសិស្ស។ កិច្ចការនេះក៏ត្រូវផ្តោតផងដែរលើការងារទាក់ទងនឹងគុណភាពផ្ទៃក្នុងសាលានៅកម្រិតសាលារៀន ដោយប្រើប្រាស់ធនធានៀផ្ទៃក្នុង ឬធនធានមូលដ្ឋាន។ ការធ្វើអធិការកិច្ចផ្ទៃក្នុងត្រូវរៀបចំ និងអនុវត្តជាប្រចាំ ប៉ុន្តែពុំសូវមានលក្ខណៈផ្លូវការដូចអធិការកិច្ចពីខាងក្រៅទេ ហើយចំពោះការធ្វើការកែលម្អអ្វីមួយវិញក៏ត្រូវធ្វើឡើងជាប្រចាំផងដែរក្នុងអំឡុងឆ្នាំសិក្សា។

**អធិការកិច្ចផ្ទៃក្រៅ** គឺជាការធ្វើអធិការកិច្ចរយៈពេលខ្លីណាមួយដោយអ្នក ដែលមកពីខាងក្រៅសាលារៀន។ ការធ្វើអធិការកិច្ចនេះគឺជាការសាកសួរ ដើម្បីរកឱ្យឃើញនូវផ្នែកទាំងឡាយណា ដែលសាលារៀនបំពេញបានល្អ ឬមិនទាន់បានល្អ រួមរិះរកវិធានការ ឬផ្តល់អនុសាសន៍ ដើម្បីស្វែងរកតម្រូវការ

នានាសម្រាប់កែលម្អចំណុចមិនទាន់បានល្អទាំងនោះ។

អធិការកិច្ចផ្ទៃក្នុង និងផ្ទៃក្រៅអាចអនុវត្តបានតាមពីររបៀប អាស្រ័យលើអ្វី ដែលយើងចង់ផ្តោតលើ និងវត្ថុបំណងនៃសកម្មភាព។ យើងអាចផ្តោតលើផ្នែកខ្លះនៃដំណើរការដោយពិនិត្យលើទិដ្ឋភាពលម្អិត ឬ ផ្តោតលើប្រព័ន្ធទាំងមូលដោយផ្តោតលើទិដ្ឋភាពគ្រប់ជ្រុងជ្រោយ។ វិធីទាំងពីរនោះគឺ៖ ១.ការវាយតម្លៃគ្រូបង្រៀន ២.ការវាយតម្លៃសាលារៀន។

**១.ការវាយតម្លៃគ្រូបង្រៀន** គឺសំដៅទៅលើការជួយគ្រូតាមរយៈ ការសង្កេតថ្នាក់ និងសម្ភាសន៍ផ្ទាល់ជាមួយគ្រូបង្រៀនក្នុងគោលបំណងពិនិត្យមើលលើវិធីសាស្ត្របង្រៀនដែលគ្រូបង្រៀនប្រើ។ ចំណុចដែលត្រូវធ្វើអធិការកិច្ចមានដូចជា ការផ្តោតលើមុខវិជ្ជាមានន័យថា អធិការម្នាក់ពិនិត្យមើកគ្រូបង្រៀន មុខវិជ្ជាគីមីវិទ្យា ហើយអធិការកិច្ចម្នាក់ទៀតពិនិត្យមើលគ្រូបង្រៀនមុខវិជ្ជា គណិតវិទ្យាជាដើមការផ្តោតលើឥរិយាបថគ្រូបង្រៀនចំពោះសិស្ស ការផ្តោតលើវិធីសាស្ត្របង្រៀនដែលគ្រូបង្រៀនប្រើដើម្បីបង្ហាញខ្លឹមសារការផ្តោតលើវិធីសាស្ត្រគ្រូបង្រៀនប្រើដើម្បីបង្ហាញខ្លឹមសារការផ្តោតលើវិធីដែលគ្រូប្រើប្រាស់សៀវភៅសិក្សា និងសម្ភារឧបទេសការផ្តោតលើសមត្ថភាពរបស់គ្រូបង្រៀនក្នុងការបង្កើតការលើកទឹកចិត្តគឺជាឧទាហរណ៍នៃសកម្មភាព ដែលត្រូវប្រើក្នុងការងារអធិការកិច្ចប្រភេទនេះ។បន្ទាប់ពីការធ្វើអធិការកិច្ច គ្រូបង្រៀនម្នាក់ៗ និងទទួលបាននូវព័ត៌មានត្រឡប់មកវិញ ទាក់ទងនឹងការបំពេញការងាររបស់ខ្លួនព្រមទាំងអនុសាសន៍សម្រាប់កែលម្អផងដែរ។

**២.ការវាយតម្លៃសាលារៀន** គឺសំដៅទៅលើការ ការធ្វើអធិការកិច្ចជាប្រព័ន្ធ ពីព្រោះថា អធិការត្រូវពិនិត្យមើលប្រព័ន្ធសាលារៀនក្នុងទិដ្ឋភាពគ្រប់ជ្រុងជ្រោយតែម្តង។ ភារកិច្ចរបស់អធិការគឺ ធ្វើឱ្យប្រាកដថា សាលារៀនមានប្រព័ន្ធរបស់ខ្លួនច្បាស់លាស់ និងសមត្ថភាពធ្វើឱ្យសម្រេចតម្រូវការដែលមានចែងក្នុងគោលការណ៍ណែនាំ។ នេះមានន័យថា អធិការមិនត្រូវផ្តោតលើមុខវិជ្ជាជាក់លាក់ណាមួយទេ ប៉ុន្តែអធិការត្រូវផ្តោតជាចម្បងលើគ្រូបង្រៀនទាំងអស់ព្រមទាំងនាយកសាលាផងដែរ។ឧទាហរណ៍ អធិការអាចពិនិត្យមើលវិធីសាស្ត្រដែលនាយកសាលារៀនដឹកនាំការងារគរុកោសល្យ ការពិនិត្យតាមដានសាលារៀន និងស្វ័យវាយតម្លៃសកម្មភាពរបស់គ្រូបង្រៀន ទាក់ទងនឹងកម្មវិធីសិក្សា និងកម្រិតយល់ដឹងរបស់ពួកគាត់

ទាក់ទងនឹងបេសកកម្មជាគ្រូបង្រៀន សម្ភារផ្សេងៗរបស់សាលារៀន និងការប្រើប្រាស់សម្ភារទាំងនោះថាតើសមស្របតាមគរុកោសល្យត្រឹមណា។ ការសម្ភាសជាមួយនាយកសាលា គ្រូបង្រៀន និងសិស្សានុសិស្ស និងការធ្វើសង្កេតគឺជាសកម្មភាពចម្បងសម្រាប់អធិការកិច្ចប្រភេទនេះ។ ការផ្តល់ព័ត៌មានត្រឡប់ត្រូវបានធ្វើចំពោះសាលារៀនទាំងមូល មានន័យថា ត្រូវផ្តល់ជូនអ្នកដែលមានការទទួលខុសត្រូវដើម្បីជានាឱ្យសាលារៀនអនុវត្តតាមគោលការណ៍ណែនាំ។ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៥)

នៅពេលអនាគតអធិការកិច្ចផ្ទៃក្នុង និងផ្ទៃក្រៅ គួរផ្តោតលើការធ្វើអធិការកិច្ចប្រភេទទីពីរ គឺការពិនិត្យមើលសាលារៀនក្នុងទិដ្ឋភាពគ្រប់ជ្រុងជ្រោយ។ ប៉ុន្តែមិនមែនមានន័យថា អធិការកិច្ចគ្រូបង្រៀននឹងមិនត្រូវយកមកអនុវត្តនោះទេ។ យើងនៅតែមានគំនិតអធិការកិច្ចគ្រូបង្រៀន និងវិធីសាស្រ្តបង្រៀនរបស់ពួកគាត់ តាមរយៈការធ្វើអធិការកិច្ចផ្ទៃក្នុងរបស់នាយកសាលារៀន និងការធ្វើអធិការកិច្ចតាមប្រធានបទពីនាយកដ្ឋានធានាគុណភាពអប់រំ។ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៥)

### ២.៣.៣.ការផ្តល់យោបល់និងការណែនាំ

ក្រោយពេលបញ្ចប់ការធ្វើអធិការកិច្ច អធិការត្រូវផ្តល់អនុសាសន៍ ឬដំបូន្មានទៅដល់អង្គភាព (សាលារៀន) ដែលរងអធិការកិច្ចនូវចំណុចខ្វះខាតមួយចំនួនដោយផ្អែកលើលទ្ធផលស្វ័យវាយតម្លៃសាលារៀន ផែនការអភិវឌ្ឍន៍សាលារៀន ផែនការប្រតិបត្តិប្រចាំឆ្នាំ កម្មវិធីសិក្សា ច្បាប់ស្តីពីការអប់រំ ផែនការយុទ្ធសាស្រ្តវិស័យអប់រំ ។ ចំពោះបញ្ហាមួយចំនួនដែលសាលាមិនអាចដោះស្រាយបាន(កង្វះគ្រូ អគារសិក្សាទ្រុឌទ្រោម សៀវភៅសិក្សាគោល...) ក្រុមអធិការកិច្ចតាមប្រធានបទត្រូវលើកសំណើជូនថ្នាក់ដឹកនាំក្រសួង ដើម្បីពិនិត្យ និងសម្រេច។

### ២.៣.៤.ការអភិវឌ្ឍសមត្ថភាពអធិការ

ដើម្បីឆ្លើយតបទៅនឹងអធិការកិច្ចថ្មី នាយកដ្ឋានធានាគុណភាពអប់រំ និងវិទ្យាស្ថានជាតិអប់រំ ត្រូវរៀបចំផែនការអភិវឌ្ឍសមត្ថភាព តាមរយៈវគ្គបំប៉ន វគ្គបណ្តុះបណ្តាលទាំងអធិការកិច្ចផ្ទៃក្នុង និងអធិការកិច្ចផ្ទៃក្រៅ។ ចំពោះអធិការកិច្ចមានស្រាប់ត្រូវបំប៉ននូវនីតិវិធីប្រព័ន្ធអធិការកិច្ចបែបថ្មី និងជ្រើសរើសអធិការថ្មី ដើម្បីបំពេញតាមតម្រូវការចាំបាច់របស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ នៅក្នុងការបំប៉ននាយក

សាលាចាំបាច់ត្រូវឱ្យសាលានីមួយៗចេះកសាងផែនការអភិវឌ្ឍសាលារៀន ផែនការប្រតិបត្តិប្រចាំឆ្នាំ និងយល់ដឹងពីឧបករណ៍ស្វ័យវាយតម្លៃសាលារៀន ព្រមទាំងស្វែងយល់ពីប្រព័ន្ធអធិការកិច្ចបែបថ្មី។

### ២.៣.៥.អធិការកិច្ចផ្ទៃក្នុង

អធិការកិច្ចផ្ទៃក្នុងមានពីរកម្រិតគឺៈ កម្រិតស្រុកមានក្រុមDTMT (កម្មវិធីសាលាកុមារមេត្រី CFS) និងកម្រិតសាលារៀន (ស្វ័យវាយតម្លៃសាលារៀន)




### ២.៣.៥.១.ស្វ័យវាយតម្លៃសាលារៀន

ប្រព័ន្ធស្វ័យវាយតម្លៃសាលារៀនដ៏មានប្រសិទ្ធភាព និងជាប្រចាំអាចផ្តល់ឱកាសក្នុងការសិក្សាសង្កេតទៅលើជីវភាពខាងក្នុង និងមហិច្ឆិតារបស់សាលារៀន ថាតើផ្តល់ផលប៉ះពាល់ដល់លទ្ធផលសិក្សារបស់សិស្សត្រឹមកម្រិតណាច្រើនជាងអធិការដែលមកមើលសាលារៀនម្តងម្កាល។ ប្រព័ន្ធស្វ័យវាយតម្លៃ គឺជាមូលដ្ឋានគ្រឹះសម្រាប់កែលម្អរយៈពេលវែង។

នាយកសាលារៀនមានតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំធ្វើស្វ័យវាយតម្លៃសាលារៀន។ ប្រព័ន្ធត្រូវតែអភិវឌ្ឍដោយរួមបញ្ចូលនូវសកម្មភាពចាំបាច់ដូចជាៈ ១.ការរៀបចំឯកសារ ២.ការបន្តពិនិត្យតាមដាន ៣.ការវិភាគ និងវាយតម្លៃតម្រូវការអភិវឌ្ឍន៍ ៤.ការកសាងផែនការ និងការអនុវត្ត។ ការងារប្រកបដោយគុណភាពជាប្រព័ន្ធមានន័យថា សាលារៀនធ្វើការពិនិត្យការតាមដានសកម្មភាពជាប្រព័ន្ធ និងជាប្រចាំ ធ្វើការវិភាគលទ្ធផលដែលទាក់ទងនឹងគោលដៅរបស់ជាតិ និងផ្អែកលើផែនការ និងការអភិវឌ្ឍវិស័យអប់រំ។ បន្ថែមលើលទ្ធផល ដែលបានមកតម្រូវឱ្យមានការតាមដានវិភាគ និងវាយតម្លៃ ដើម្បីបង្ហាញអំពីបទពិសោធន៍ ដែលមានលក្ខណៈវិទ្យាសាស្ត្រ និងលេខជ្លោ ដែលជាការអនុវត្តល្អៗរបស់ពួកគេ។ ជាមួយគ្នានេះការកសាងផែនការ និងការកំណត់ផ្នែកអាទិភាពដែលត្រូវធ្វើការអភិវឌ្ឍត្រូវយកចិត្តទុកដាក់សំខាន់លើ

ការស្រាវជ្រាវបច្ចុប្បន្ន។ នាយកសាលារៀនត្រូវវិភាគរកមើលមូលហេតុនៃប្រសិទ្ធភាពខុសៗគ្នា រវាងក្រុម និងថ្នាក់ផ្សេងៗគ្នា ឬរវាងមុខវិជ្ជា និងផ្នែកដែលត្រូវផ្តោតនៃកម្មវិធីសិក្សា។ បន្ថែមលើនេះនាយកសាលារៀនរួមជាមួយបុគ្គលិកសាលារៀនត្រូវរួមគ្នាពិភាក្សា និងវិភាគលើលទ្ធផល និងការពន្យល់ទាំងឡាយដោយផ្អែកលើវត្ថុបំណងថ្នាក់ជាតិជាគោល។ ការងារជាប្រព័ន្ធ និងជាចរន្តមានន័យថា កិច្ចការទាំងនោះត្រូវរៀបចំ និងបន្តដោយផ្តោតលើការអភិវឌ្ឍយូរអង្វែង។ សាលារៀននីមួយៗត្រូវស្វែងរកបែបបទ និងនីតិវិធីរបស់ខ្លួនសម្រាប់ការងារជាប្រព័ន្ធដោយផ្អែកលើស្តង់ដារបស់ជាតិ។ ចំណុចចាប់ផ្តើមជានិច្ចកាលត្រូវធ្វើដូចៗគ្នា គឺត្រូវកំណត់ផ្នែកដែលត្រូវធ្វើការអភិវឌ្ឍន៍ ដើម្បីសម្រេចឱ្យបានប្រសិទ្ធភាពខ្ពស់បំផុតទាក់ទងនឹងវត្ថុបំណងរបស់ជាតិ។ ដើម្បីអាចធ្វើការតាមដានលើលក្ខខណ្ឌ និងការអនុវត្តលើការងារអប់រំថាទទួលបានប្រសិទ្ធភាពខ្ពស់ប៉ុណ្ណានោះជាការសំខាន់ គឺត្រូវរៀបចំការវិភាគតាមដានកិច្ចការទាំងនោះដោយខ្លួនឯងផ្ទាល់។ ក្នុងពេលអនាគតនាយកសាលារៀន នឹងមានលទ្ធភាពប្រើប្រាស់មូលដ្ឋានទិន្នន័យ ពីប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ(QEMIS) សម្រាប់បម្រើឱ្យសកម្មភាពតាមដានទាំងនោះ។ ការរៀបចំឯកសារ គឺជាការចាំបាច់ដើម្បីចងក្រងជាប្រចាំនូវកិច្ចការគុណភាពដែលនាំទៅដល់ការសម្រេចបានវត្ថុបំណង។សម្រាប់ទស្សនៈវិស័យយូរអង្វែង ការរៀបចំឯកសារ គឺជាលក្ខខណ្ឌចាំបាច់ដំបូង ដើម្បីអាចកំណត់សកម្មភាពនិងផ្នែកដែលត្រូវយកចិត្តទុកដាក់ជាសំខាន់សម្រាប់ការអភិវឌ្ឍដើម្បីសម្រេចវត្ថុបំណង។ ភស្តុតាងបានបង្ហាញថា នាយកសាលារៀនដែលក្លាយជាអ្នកដឹកនាំដ៏ជោគជ័យតែងតែផ្តោតកិច្ចខិតខំប្រឹងប្រែងរបស់គាត់លើវត្ថុបំណងទូទៅចំនួនបួនគឺ៖ ១.លើកកម្ពស់យ៉ាងខ្លាំងក្លាលើដំណើរការរៀន និងបង្រៀនដើម្បីសម្របសម្រួលសមិទ្ធផលសិក្សាសម្រាប់កុមារទាំងអស់។២.បណ្តុះគំនិតសហគមន៍ឱ្យចូលរួមយ៉ាងខ្លាំងក្លាព្រោះថាពួកគាត់ទាំងអស់គឺជាផ្នែកមួយរបស់សារៀន ៣.ផ្តល់តម្លៃនិងពង្រីកសមាមាត្រស្ថានភាពសង្គមសេដ្ឋកិច្ចរបស់កុមារ។ ៤.លើកទឹកចិត្ត និងជំរុញការអភិវឌ្ឍវប្បធម៌របស់គ្រួសារ។ គ្រូបង្រៀនគឺជាចំណុចស្នូលចំពោះកំណែទម្រង់សាលារៀន។ ដូចនេះជោគជ័យនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រីក្នុងបរិបទកំណែទម្រង់គឺ អាស្រ័យលើសមត្ថភាពរបស់គ្រូបង្រៀនដែលកំពុងស្ថិតនៅក្នុងប្រព័ន្ធនោះ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍគ្រូបង្រៀនក្នុងកម្រិតមួយដ៏ខ្ពស់ កំពុងត្រូវការកម្រិតអប់រំ និងបំប៉នចាំបាច់ដើម្បីដោះ

ស្រាយបញ្ហាដែលកើតមានឡើងក្នុងដំណើរការកំណែទម្រង់សាលារៀន។ បន្ថែមលើនេះដោយសារមូលហេតុជាច្រើនបានធ្វើឱ្យសីលធម៌ និងការលើកទឹកចិត្តគ្រូក្នុងប្រទេសទាំងនោះនៅមានកម្រិតទាបនៅឡើយ។ ដើម្បីឱ្យកំណែទម្រង់សាលារៀនប្រព្រឹត្តទៅបានជោគជ័យ ប្រការសំខាន់គឺ ត្រូវរៀបចំកម្មវិធីបំប៉នបណ្តុះបណ្តាល និងផ្តល់យោបល់ឱ្យបានល្អដើម្បីកសាងភាពប៉ិនប្រសប់ ពង្រឹងសមត្ថភាព និងកែលម្អសីលធម៌របស់គ្រូបង្រៀន។ ការងារនេះក៏ត្រូវចូលរួមផងដែរនូវការបណ្តុះបណ្តាល និងវិក្រឹតការដែលមានគុណភាពខ្ពស់សម្រាប់គ្រូបង្រៀន ដើម្បីពួកគាត់អាចមានលទ្ធភាពបំពេញការងារប្រកបដោយប្រសិទ្ធភាពដែលផ្អែកលើគោលការណ៍សិស្សមជ្ឈមណ្ឌលនិងគរុកោសល្យទាក់ទាញដែលជាបេះដូងនៃកម្មវិធីសាលាកុមារមេត្រី។ (ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ), ២០១៦)

ការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ គឺជាមូលដ្ឋានគ្រឹះសម្រាប់ការងារគុណភាព។ តាមរយៈស្វ័យវាយតម្លៃជាប្រព័ន្ធ បុគ្គលិកទាំងអស់នឹងបានយល់ច្បាស់អំពីអ្វី ដែលជាអាទិភាព និងត្រូវអភិវឌ្ឍ ត្រូវធ្វើនៅពេលណា ត្រូវធ្វើតាមវិធីអ្វីខ្លះ ហើយអ្នកណាខ្លះជាអ្នកទទួលខុសត្រូវលើកិច្ចការទាំងនោះ។ នាយកសាលារៀន បុគ្គលិក កុមារ និងសិស្សក៏ដូចជាមាតាបិតាសិស្សផងដែរ ត្រូវការជាចាំបាច់នូវជំនួយតាមរយៈការផ្តល់ព័ត៌មានត្រឡប់និងទិន្នន័យដើម្បីបង្ហាញគុណភាព។ក្នុងសាលារៀនមួយដែលចង់ឱ្យមានការប្រែប្រួលស្វ័យវាយតម្លៃត្រូវបានអនុវត្តនៅគ្រប់កម្រិតទាំងអស់រួមទាំងបុគ្គលិកម្នាក់ៗ ក្រុម និងស្ថាប័នទាំងមូល។

### ២.៣.៦.អធិការកិច្ចផ្ទៃក្រៅ

អធិការកិច្ចផ្ទៃក្រៅមានពីរប្រភេទគឺ១.អធិការកិច្ចតាមប្រធានបទ ដែលមាននាយកដ្ឋានជានាគុណភាពអប់រំជាអ្នកអនុវត្ត ២.អធិការកិច្ចតាមកាលកំណត់ ដែលមានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តជាអ្នកអនុវត្ត។ (ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ), ២០១៦)

## ២.៤.អធិការកិច្ចតាមកាលកំណត់

អធិការកិច្ចតាមកាលកំណត់ គឺជាការពិនិត្យនិងវាយតម្លៃសាលារៀនទាំងអស់ជាប្រព័ន្ធដើម្បីធានាថាពួកគេបានគោរពច្បាប់ និងបទប្បញ្ញត្តិដែលទាក់ទងនឹងភារកិច្ចរបស់ខ្លួន។ ការវាយតម្លៃគឺត្រូវផ្អែកលើការបកស្រាយបទប្បញ្ញត្តិរបស់ជាតិ។ លទ្ធផលដែលបានមកនឹងបង្ហាញអំពីកិច្ចការណាខ្លះដែលមាន

ដំណើរការល្អ និងកិច្ចការណាខ្លះទៀតដែលត្រូវធ្វើការកែលម្អ។ អធិការកិច្ចតាមកាលកំណត់នឹងត្រូវអនុវត្ត ដោយមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត និងក្រុមអធិការកិច្ចរបស់ពួកគេ។ អធិការកិច្ចតាមកាលកំណត់នឹងត្រូវប្រមូលព័ត៌មានទូទៅនៃប្រព័ន្ធសាលារៀន និងសមត្ថភាពរបស់សាលារៀនក្នុងការសម្រេចបេសកកម្មថ្នាក់ជាតិ។ ឧបករណ៍ទាំងអស់សម្រាប់ការធ្វើអធិការកិច្ចត្រូវផ្អែកលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការអប់រំ កម្មវិធីសិក្សា អនុសញ្ញាស្តីពីសិទ្ធិកុមារ និងគោលនយោបាយជាតិ នៃវិស័យអប់រំនៅកម្ពុជា។ អធិការកិច្ចតាមកាលកំណត់ត្រូវផ្តោតលើផ្នែកទាំងឡាយដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍ និងការកែលម្អសាលារៀន។ គោលបំណងនៃការធ្វើអធិការកិច្ចនេះ គឺដើម្បីទទួលបាននូវការអនុវត្ត ដែលកាន់តែប្រសើរឡើង នៅក្នុងសាលារៀន ដែលបានពិនិត្យជាមួយនឹងការផ្តោតលើលទ្ធផលសិក្សារបស់សិស្ស និងសុខុមាលភាពសង្គមហើយយកចំណេះដឹងទាំងនោះទៅផ្សព្វផ្សាយដល់សាលារៀនដទៃទៀតនៅក្នុងប្រទេស និងជូនក្រសួងអប់រំ យុវជន និងកីឡាផងដែរ។ (ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ),២០១៦) បន្ថែមពីនេះគោលនយោបាយកម្មវិធីសាលាកុមារមេត្រីការគ្រប់គ្រងសាលារៀនឯកសារស្តង់ដាសាលារៀនមានប្រសិទ្ធភាព ឯកសារសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកនិងឯកសារគោលនយោបាយអប់រំផ្សេងៗនៅកម្ពុជា គឺជាមូលដ្ឋានសម្រាប់សមាសភាគនៃការវាយតម្លៃ សំណួរសម្ភាសន៍ និងចំណុចដែលត្រូវផ្តោតការយកចិត្តទុកដាក់សម្រាប់ការសង្កេតថ្នាក់រៀន។ (នាយកដ្ឋានជានាគុណភាពអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា, មករា ២០២១) អធិការកិច្ចតាមកាលកំណត់អាចអនុវត្តទៅលើផ្នែកសំខាន់ៗចំនួន៤ ដូចជា៖ ១.ការដឹកនាំ និងគ្រប់គ្រង ២.ការបង្រៀននិងរៀន៣.លទ្ធផលសិក្សារបស់សិស្ស ៤.ទំនាក់ទំនងជាមួយសហគមន៍មាតាបិតាសិស្ស ។

### ២.៤.១.ភាពញឹកញាប់នៃការធ្វើអធិការកិច្ចតាមកាលកំណត់

ភាពញឹកញាប់ និងខ្លឹមសារនៃការធ្វើអធិការកិច្ចទៀងទាត់ គឺអាស្រ័យលើកត្តាពីរគឺ ១.តើសាលារៀនដែលត្រូវធ្វើអធិការកិច្ចទាំងអស់ ត្រូវការធ្វើអធិការកិច្ចលក្នុងវិធីដូចគ្នាឬទេ? ២.ចំនួនអធិការកិច្ច ។

អធិការកិច្ចតាមកាលកំណត់ គឺជាការធ្វើអធិការកិច្ចផ្តោតលើហានិភ័យ ហើយថ្នាក់ខេត្តជាអ្នករៀបចំផែនការអធិការកិច្ច និងជ្រើសរើសសាលារៀន ដោយសហការជាមួយនាយកដ្ឋានធានាគុណភាព

អប់រំ។ ជាទូទៅការធ្វើអធិការកិច្ចសាលារៀនមួយគប្បីចំណាយពេល ១ឬ២ថ្ងៃ ជាមួយអធិការកិច្ចពីររូប។ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៥)

### ២.៤.២.ប្រព័ន្ធរបាយការណ៍អធិការកិច្ចតាមកាលកំណត់

ប្រព័ន្ធរបាយការណ៍អធិការកិច្ចមានបីប្រភេទ នឹងត្រូវរៀបចំដោយអធិការថ្នាក់ខេត្តៈ ១.របាយការណ៍សាលារៀន ២.របាយការណ៍សង្ខេប ៣.របាយកាណ៍វិភាគប្រចាំឆ្នាំ។ រាល់សាលារៀនទាំងអស់ដែលបានធ្វើអធិការកិច្ច នឹងទទួលបានរបាយការណ៍ លទ្ធផលនៅពេលធ្វើអធិការកិច្ចត្រូវបានបញ្ចប់។ សាលារៀននឹងទទួលបានការវាយតម្លៃលើផ្នែក ដែលអធិការកិច្ចបានផ្តោត។ អនុសាសន៍ដែលមានចែងក្នុងរបាយការណ៍ នឹងត្រូវបានប្រើប្រាស់ជាចំណុចចាប់ផ្តើមសម្រាប់កែលម្អគុណភាពប្រតិបត្តិការ។ (ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ), ២០១៦)

ជាមួយគ្នានេះសៀវភៅជំនួយស្មារតី អធិការកិច្ចតាមកាលកំណត់ ខែមករា ឆ្នាំ២០២១ បានបង្ហាញពីទម្រង់អធិការកិច្ចបែបថ្មីស្របនឹងស្ថានភាព នៃការអប់រំនាពេលបច្ចុប្បន្នដោយបានបន្ថែមសូចនាកររង និងកែសម្រួលពាក្យបច្ចេកទេសក្នុងសូចនាករគោល[1]ទី៤ពីស្វ័យវាយតម្លៃសាលារៀនទៅជាការចូលរួមរបស់សហគមន៍ មាតាបិតា និងអាណាព្យាបាល វិញ។ ក្នុងនោះ **ការគ្រប់គ្រងនិងដឹកនាំ** មាន៩សូចនាករដូចជា៖ ១.រចនាសម្ព័ន្ធដឹកនាំនិងគ្រប់គ្រង ២.ការគ្រប់គ្រងនិងការអភិវឌ្ឍបុគ្គលិក ៣.ប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិក្នុងការបែងចែកការងារ ៤.ការគ្រប់គ្រងថវិកា ៥.ការគ្រប់គ្រងនិងការប្រើប្រាស់ធនធានសម្ភារៈសម្រាប់ការបង្រៀននិងរៀនប្រកបដោយគុណភាព ៦.ការចូលរៀនប្រកបដោយសមធម៌ និងបរិយាបន្ន ៧.ការចូលរៀនប្រកបដោយសមធម៌ និងបរិយាបន្ន ៨.ការបំពេញការងាររបស់សាលារៀនឆ្លើយតបទៅនឹងយេនឌ័រ និង៩.ការអនុវត្តស្វ័យវាយតម្លៃ។ **ការបង្រៀននិងរៀន**មាន០៧សូចនាកររងដូចជា៖ ១.ការបង្រៀននិងការរៀនឆ្លើយតបនឹងលទ្ធផលរំពឹងទុក ២.ការប្រើប្រាស់វិធីសាស្ត្របង្រៀនតាមបរិបទថ្មី ៣.ការប្រើប្រាស់សម្ភារឧបទេសក្នុងម៉ោងសិក្សា ៤.ការបង្រៀនសម្របតាមតម្រូវការរបស់សិស្ស ៥.ការបង្កើតបរិយាកាសលើកទឹកចិត្តសិស្សឱ្យខិតខំរៀនសូត្រ ៦.ការប្រើបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន(ICT)ក្នុង

[1] សូចនាករគោលមានបួនធំៗគឺ ១.ការគ្រប់គ្រងនិងដឹកនាំ ២.ការបង្រៀននិងរៀន ៣.លទ្ធផលសិក្សារបស់សិស្ស ៤.ការចូលរួមរបស់សហគមន៍ មាតាបិតា និងអាណាព្យាបាល

ការបង្រៀននិងរៀន និង៧.ការអភិវឌ្ឍសមត្ថភាពតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។ **លទ្ធផលសិក្សា** មានចំនួន០៥សូចនាកររងដូចជា៖ ១.សាលារៀនមានកម្មវិធីទាក់ទាញ ដើម្បីធានាឱ្យសិស្សមានវត្តមានក្នុងសាលារៀន ២.ការរៀបចំតេស្តស្តង់ដាស្របតាមកម្មវិធីសិក្សា ៣.ការវាយតម្លៃ និងការដាក់ពិន្ទុ ធ្វើឡើងប្រកបដោយសមធម៌ ៤.លទ្ធផលសិក្សាសិស្ស និង៥.ការផ្សព្វផ្សាយលទ្ធផលសិក្សា។ **ការចូលរួមរបស់សហគមន៍មាតាបិតា និងអាជ្ញាធរ**មាន០៤សូចនាកររងដូចជា៖១.ការចូលរួមរបស់ក្រុមប្រឹក្សាកុមា/យុវជនក្នុងសកម្មភាពការងារសាលារៀន និងសង្គម ២.ការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាលក្នុងការពិនិត្យតាមដាន និងជំរុញការសិក្សារបស់សិស្ស ៣.ការចូលរួមរបស់គណៈគ្រប់គ្រងសាលារៀន និង៤.ការគាំទ្រនានារបស់សហគមន៍ និងសប្បុរសជនក្នុងការអភិវឌ្ឍសាលារៀន។ ចំណែករបាយការណ៍អធិការកិច្ចតាមកាលកំណត់ដែលរៀបចំដោយអធិការកិច្ចថ្នាក់ខេត្តមានដូចជា៖ ១.របាយការណ៍សាលារៀន ២.របាយការណ៍ថ្នាក់ស្រុក និង៣.របាយការណ៍ថ្នាក់ខេត្ត ។ បន្ថែមពីនេះមានតារាងបញ្ចូលទិន្នន័យជា Microsoft Excel កំណត់បង្ហាញរឿង និងរបាយការណ៍សង្ខេបទៀតផង។ (នាយកដ្ឋានធានាគុណភាពអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា, មករា ២០២១)

### ២.៤.៣.លទ្ធផលនៃដំណើរការវាយតម្លៃ

សាលារៀននឹងត្រូវបានវាយតម្លៃលើផ្នែកសំខាន់ៗចំនួន៤គឺ៖១.ការដឹកនាំនិងការគ្រប់គ្រង ២.ការបង្រៀននិងរៀន ៣.លទ្ធផលសិក្សារបស់សិស្ស ៤.គុណភាពការងារស្វ័យវាយតម្លៃសាលារៀន[2] ។

កម្រិតវិនិច្ឆ័យនៃកាវាយតម្លៃមាន៤កម្រិតគឺ **១.ល្អឥតខ្ចោះ ២.ល្អ ៣.ពេញចិត្ត ៤.មិនពេញចិត្ត** ។

- **១.ល្អឥតខ្ចោះ៖** វិនិច្ឆ័យលើចំណុចខ្លាំងចម្បងៗ ផលសម្រេចល្អណាស់ និងភាពលេចធ្លោនៃការបំពេញការងាររបស់សាលារៀនលើផ្នែក ដែលបានវាយតម្លៃ (ឧទាហរណ៍៖ ការបោះបង់ការសិក្សាទាប កុមារទាំងអស់បានបញ្ចប់ការអប់រំបំណោះទូទៅ...)

---

[2] គុណភាពការងារស្វ័យវាយតម្លៃសាលារៀន ត្រូវបានកែសម្រួលទៅជា **ការចូលរួមរបស់សហគមន៍ មាតាបិតា និងអាជ្ញាធរ** (ឯកសារជំនួយស្មារតី២០២១)

- **២.ល្អ ៖** មានចំណុចខ្លាំងច្រើនជាងចំណុចខ្សោយ។ សាលារៀនធ្វើដំណើរឆ្ពោះទៅរកគោលដៅកំណត់របស់ខ្លួនក្នុងលក្ខណៈស្ថេរភាព និងមានផលសម្រេចល្អកើតពីការខិតខំដើម្បីកែលម្អសាលារៀន។
- **៣.ពេញចិត្ត ៖** មានទាំងចំណុចខ្លាំងនិងចំណុចខ្សោយព្រមគ្នា។ នៅមានការងារមួយចំនួនត្រូវបំពេញបន្ថែមប៉ុន្តែ ផ្នែកមួយចំនួនកំពុងឈានឆ្ពោះទៅរកគោលដៅដែលបានកំណត់ជាមួយនឹងផលសម្រេចដំបូងបានកើតជារូបរាង។
- **៤.មិនពេញចិត្ត៖** មានចំណុចអវិជ្ជមានច្រើន និងផលសម្រេចទាប។ សាលារៀនបរាជ័យក្នុងការឈានទៅដល់គោលដៅជាច្រើនដែលបានកំណត់។ ត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីជួយដោះស្រាយបញ្ហាទាំងនោះ។ (ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ), ២០១៦)

# ជំពូកទី៣

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ គម្រោងវិភាគ

ដើម្បីទទួលបានទិន្នន័យគ្រប់គ្រាន់សម្រាប់យកមកវិភាគក្នុងការស្រាវជ្រាវនេះ យើងបានរៀបចំគម្រោងវិភាគយ៉ាងច្បាស់ទៅតាមដំណាក់កាលនីមួយ នៃដំណើរការស្រាវជ្រាវទាំងមូល ដោយបានធ្វើការកំណត់ថា បន្ទាប់ពីចុះប្រមូលទិន្នន័យបានគ្រប់គ្រាន់ យើងគ្រោងនឹងវិភាគតាមកម្រងសំណួរនីមួយៗ ទៅតាមផ្នែកដែលបានកំណត់ជាលំដាប់លំដោយចាប់ពីកម្រងសំណួរសម្រាប់គ្រូបង្រៀន រហូតដល់គណៈគ្រប់គ្រងដែលមានតាមចំណុចដូចជា៖

### ក.កម្រងសំណួរសម្រាប់សម្ភាសន៍គ្រៅបង្រៀន

**ផ្នែកទី១៖ ព័ត៌មានទូទៅ** មាន១១សំណួរ ទាក់ទងនឹងព័ត៌មានផ្ទាល់ខ្លួន និងកន្លែងបម្រើការងារ ។ ក្នុងផ្នែកនេះយើងចង់ដឹងអំពី ភេទ អាយុ ឯកទេស បទពិសោធន៍បម្រើការងារ ឈ្មោះសាលារៀន ចម្ងាយពីផ្ទះទៅកន្លែងធ្វើការងារ កម្រិតសិក្សា ចំនួនបុគ្គលិក និងចំនួនសិស្ស ដែលពួកគាត់បម្រើការងារបច្ចុប្បន្ន។

**ផ្នែកទី២៖ ការដឹកនាំនិងគ្រប់គ្រង** មាន១១សំណួរ ទាក់ទងការកែលម្អទីចាត់ការ ការចុះអធិការកិច្ចអចិន្ត្រៃយ៍ ការធ្វើកិច្ចតែងការបង្រៀន រដ្ឋបាលថ្នាក់ រដ្ឋបាលគ្រូ គុណភាពនិងលទ្ធផលសិក្សារបស់សិស្ស ការចូលរួមរបស់សហគមន៍ កម្រិតលទ្ធផលនៃការវាយតម្លៃដំណើរការសិក្សាក្នុងសាលារៀន។ ការចូលរួមរបស់គ្រូបង្រៀនក្នុងការងារបង្រៀនរបស់ខ្លួន និងការអភិវឌ្ឍរបស់សាលារៀនបន្ទាប់ពីក្រុមការងារអធិការកិច្ចថ្នាក់មន្ទីរបានចុះធ្វើអធិការកិច្ចរួចមក។

### ផ្នែកទី៣៖បញ្ហាប្រឈមក្នុងការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់

មាន០២សំណួរ ទាក់ទងនឹងពេលវេលាទទួលរបាយការណ៍ និងបញ្ហាប្រឈមនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់។ ក្នុងផ្នែកនេះយើងចង់ដឹងពីការលំបាកខ្លាំងរបស់គ្រូបង្រៀនទាក់ទងនឹងការអនុវត្តផ្ទាល់នៃអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់ដែលបានដាក់ជូន។

**ផ្នែកទី៤៖ការយល់ឃើញរបស់គ្រូបង្រៀនចំពោះការងារអធិការកិច្ច** មាន០៣សំណួរ ទាក់ទងនឹងអត្ថប្រយោជន៍នៃរបាយការណ៍អធិការកិច្ចក្នុងការអភិវឌ្ឍសាលារៀន ភាគរយនៃការអនុវត្ត អនុសាសន៍ដែលក្រុមអធិការកិច្ចដាក់ជូន និងកម្រិតអភិវឌ្ឍសាលារៀន។ ក្នុងផ្នែកនេះយើងចង់ដឹងអំពីការយល់ឃើញរបស់គ្រូបង្រៀនចំពោះរបាយការណ៍អធិការកិច្ចតាមកាលកំណត់នៅសាលារៀន ព្រមទាំងការកម្រិតលទ្ធផលអភិវឌ្ឍសាលារៀនផងដែរ។

## ខ.កម្រងសំណួរសម្រាប់សម្ភាសន៍គណៈគ្រប់គ្រងសាលារៀន

**ផ្នែកទី១៖ ព័ត៌មានទូទៅ** មាន១៣សំណួរ ទាក់ទងនឹងព័ត៌មានផ្ទាល់ខ្លួន កម្រិតវិជ្ជាជីវៈ និងកន្លែងបម្រើការងារ។ ក្នុងផ្នែកនេះយើងចង់ដឹងអំពី ភេទ អាយុ ឯកទេស បទពិសោធន៍បម្រើការងារ ឈ្មោះសាលារៀន ចម្ងាយពីផ្ទះទៅកន្លែងធ្វើការងារ កម្រិតសិក្សា ចំនួនបុគ្គលិក និងចំនួនសិស្ស ក្នុងសាលារៀនដែលពួកគាត់បម្រើការងារបច្ចុប្បន្ន។

**ផ្នែកទី២៖ ការដឹកនាំនិងគ្រប់គ្រង** មាន១២សំណួរ ទាក់ទងការកែលម្អទីចាត់ការ ការរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍ ការកែលម្អបរិស្ថាន ការត្រួតពិនិត្យកិច្ចតែងការបង្រៀន រដ្ឋបាលថ្នាក់ រដ្ឋបាលគ្រូ គុណភាពនិងលទ្ធផលសិក្សារបស់សិស្ស កម្រិតចូលរួមរបស់សហគមន៍ កម្រិតអភិវឌ្ឍសាលារៀន កម្រិតលទ្ធផលនៃការវាយតម្លៃការសិក្សាសាលារៀន ចំណាត់ថ្នាក់សាលារៀននិងគ្រូបង្រៀន ។ ក្នុងផ្នែកនេះយើងចង់ដឹងអំពីការដឹកនាំនិងគ្រប់គ្រង និងការអភិវឌ្ឍរបស់សាលារៀនបន្ទាប់ពីក្រុមការងារអធិការកិច្ចថ្នាក់មន្ទីរបានចុះធ្វើអធិការកិច្ចរួចមក។

## ផ្នែកទី៣៖បញ្ហាប្រឈមក្នុងការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់

មាន០២សំណួរ ទាក់ទងនឹងពេលវេលាទទួលរបាយការណ៍ និងបញ្ហាប្រឈមនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀន។ ក្នុងផ្នែកនេះយើងចង់ដឹងពីការលំបាកខ្លាំងរបស់គ្រូនាយកទាក់ទងនឹងការអនុវត្តផ្ទាល់ នៃអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់ដែលក្រុមការងារអធិការកិច្ចបានដាក់ជូន។

ផ្នែកទី៤៖ការយល់ឃើញរបស់នាយកចំពោះការអនុវត្តការងារអធិការកិច្ច

មាន០៣សំណួរ ទាក់ទងនឹងអត្ថប្រយោជន៍នៃរបាយការណ៍អធិការកិច្ចក្នុងការអភិវឌ្ឍសាលារៀន ភាគរយនៃការអនុវត្តអនុសាសន៍ដែលក្រុមអធិការកិច្ចដាក់ជូន កម្រិតអភិវឌ្ឍសាលារៀន និងសកម្មភាពប្រែប្រួលនានាក្នុងសាលារៀន។ក្នុងផ្នែកនេះយើងចង់ដឹងអំពីការយល់ឃើញរបស់នាយក នាយិកា នាយករងចំពោះរបាយការណ៍អធិការកិច្ចតាមកាលកំណត់ ព្រមទាំងកម្រិតលទ្ធផលអភិវឌ្ឍសាលារៀនផងដែរ។

## ៣.២ ការប្រមូលទិន្នន័យ

ដើម្បីឱ្យការប្រមូលទិន្នន័យបានគ្រប់គ្រាន់ យើងបានជ្រើសសំណាក និងសាលាគោលដៅរួចជាស្រេចដោយរង់ចាំការចេញលិខិតឧទ្ទេសនាម និងលិខិតអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡាក្រោមការរៀបចំរបស់វិទ្យាស្ថានជាតិអប់រំ។ បន្ទាប់ពីបានលិខិតមកឧទ្ទេសនាម និងលិខិតអនុញ្ញាតចុះសិក្សាស្រាវជ្រាវ[3]រួចមក យើងយកលិខិតនោះ បញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យដើម្បីចេញលិខិតជូនដំណឹងមួយទៀតទុកជាការបើកផ្លូវដល់យើងជាអ្នកស្រាវជ្រាវក្នុងការចុះទៅសម្ភាសសាលាគោលដៅទាំង១១ទូទាំងខេត្តឧត្តរមានជ័យ។ ក្រោយពីបានទទួលលិខិតចេញពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ[4]រួចហើយយើងបានបញ្ជូនលិខិតនេះទៅការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុកទាំង៤គឺ ក្រុងសំរោង០៥សាលា ស្រុកចុងកាល់០២សាលា ស្រុកបន្ទាយអំពិល០២សាលា ស្រុកអន្លង់វែង០២សាលា ដើម្បីឱ្យបានជ្រាបជាព័ត៌មាននិងសម្គាល់ពីសាលាគោលដៅផងដែរ។ ដំណើរការបន្ទាប់យើងបានទំនាក់ទំនងជាមួយនាយកសាលាដើម្បីសុំការអនុញ្ញាត ក៏ដូចជាប្រាប់ពីគោលបំណងនៃការស្រាវជ្រាវ និងជួបសម្ភាសន៍ជាមួយគណៈគ្រប់គ្រងសាលារៀន លោកគ្រូអ្នកគ្រូផងដែរ។ បើតាមការគ្រោងទុក យើងចាំបាច់ត្រូវចុះទៅជួបសម្ភាសន៍ផ្ទាល់ជាមួយគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សនិងសហគមន៍មាតាបិតាសិស្សតាមសាលាគោលដៅទាំង១១ប៉ុន្តែដោយសារវិបត្តិកូវីដ-១៩ បានមកដល់ គម្រោងនេះត្រូវបានផ្លាស់ប្តូរពីការចុះជួបផ្ទាល់មកជាការសម្ភាសន៍ដោយប្រើកម្រងសំណួរ

[3] លិខិតលេខ ២៤០៩ អយក.វជអ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ របស់ក្រសួងអប់រំ យុវជន និងកីឡា

4 លិខិតលេខ ១២២២ អយកខ.របុប ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០២១ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ

តាម Google Form និងអនុវត្តតាមអនឡាញជំនួសវិញ។ យើងបានបង្កើតក្រុម Telegram ដែលក្នុងនោះមានសមាសភាពនាយក នាយិកា នាយករង និងលោកគ្រូអ្នកគ្រូសាលាគោលដៅទាំងអស់ផងដែរ។ ដោយឡែកផ្នែកសិស្សានុសិស្ស និងសហគមន៍ មាតាបិតាសិស្សអ្នកស្រាវជ្រាវមិនបានអនុវត្តឡើយ ព្រោះសមាសភាពទាំងនេះពិបាកទំនាក់ទំនង និងការប្រើបច្ចេកវិទ្យានៅមានកម្រិត។ បន្ទាប់មកយើងបានធ្វើការណែនាំពីរបៀបចូលបំពេញកម្រងសំណួរតាមរយៈការធ្វើបទបង្ហាញជាវីដេអូរួចទម្លាក់ចូលក្រុម មួយរយៈខ្លីក្រោយមកទើបទម្លាក់កម្រងសំណួរមានដែលបានបង្កើតរួចជាស្រេចនៃ Link Google Form ១.សម្រាប់ឱ្យលោកនាយក នាយិកា នាយករងសាលា និង២. សម្រាប់លោកគ្រូ អ្នកគ្រូបានបំពេញផងដែរ។យើងបានផ្ដល់ពេលវេលាពីរសប្ដាហ៍សម្រាប់សំណាកគោលដៅធ្វើការចូលបំពេញកម្រងសំណួរ។ ជារួមបន្ទាប់ពីពីរសប្ដាហ៍បានកន្លងផុតទៅលទ្ធផលនៃការចូលបំពេញកម្រងសំណួរព្រមទាំងបាន Submit មានចំនួន ៧៨នាក់នៃចំនួន១០០សំណាកក្នុងសាលាគោលដៅទាំង១១ដែលស្មើនឹង ៧៨%។ ហើយនៅសល់២២នាក់ស្មើនឹង២២% មិនបានចូលបំពេញបណ្ដាលមកពីមកពីកន្លែងដែលពួកគាត់រស់នៅពុំមានសេវាគ្រប់គ្រាន់ ខ្លះលំហែមាតុភាព ខ្លះជាប់ចក្ដាឡីស័ក និងមួយចំនួនទៀតទំនាក់ទំនងមិនបាន ។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ

ដើម្បីទទួលបានព័ត៌មានត្រឹមត្រូវ ទិន្នន័យ និងខ្លឹមសារសំខាន់នានាពីប្រសិទ្ធភាពនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀន យើងបានប្រើប្រាស់កម្រងសំណួរទម្រង់ Ms.Word និងទម្រង់ Google Form ធ្វើជាឧបករណ៍សម្រាប់ស្រាវជ្រាវ ដែលអាចឱ្យលោកគ្រូ អ្នកគ្រូ នាយក នាយិកា នាយករង ផ្ដល់ទិន្នន័យទៅតាមលំដាប់លំដោយនៃការរៀបចំក្នុងទម្រង់សំណួរនីមួយៗ។ កម្រងសំណួរនេះយើងបានប្រើប្រាស់ចំពោះអ្នកពាក់ព័ន្ធពីរប្រភេទគឺ សម្រាប់សម្ភាសន៍គណៈគ្រប់គ្រងសាលារៀន( នាយក នាយិកា នាយករង ) និងកម្រងសំណួរសម្រាប់សម្ភាសន៍គ្រូបង្រៀន។ បន្ទាប់ពីរៀបចំបញ្ចូលកម្រងសំណួរក្នុង Google Form រួចរាល់ យើងបានបញ្ជូនទៅគ្រូដឹកនាំដើម្បីជួយត្រួតពិនិត្យ និងកែសម្រួល។ ចំពោះមុខនេះយើងបានបង្កើតក្រុម តេឡេក្រាម(Telegram) ព្រមទាំងទម្លាក់វីដេអូណែនាំពីការចូលបំពេញកម្រងសំណួរឱ្យបានត្រឹមត្រូវ បន្ទាប់មកទម្លាក់ Link Google Form នៃកម្រងសំណួរ

សម្រាប់បំពេញ។ ការរៀបចំកម្រងសំណួរឱ្យស្របទៅនឹងប្រធានបទក៏ដូចជាគោលបំណងនៃការស្រាវជ្រាវ យើងបានបែងចែកសម្រាប់សម្ភាសន៍គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន ដែលកម្រងសំណួរនីមួយៗ អ្នកស្រាវជ្រាវបានបែងចែកជា៤ផ្នែកគឺ ផ្នែកទី១ព័ត៌មានទូទៅ ផ្នែកទី២ ការគ្រប់គ្រងនិងការដឹកនាំ ផ្នែកទី៣.បញ្ហាប្រឈមក្នុងការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់ និងផ្នែកទី៤. ការយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន និងលោកគ្រូ អ្នកគ្រូ ក្នុងការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀន។ ដើម្បីឆ្លើយតបនឹងខ្លឹមសារដែលបានគ្រោងថានឹងទទួលបានសម្រាប់សរសេរនិក្ខេបបទនេះ យើងបានសិក្សាពីសៀវភៅពាក់ព័ន្ធនានាដូចជា៖

-សៀវភៅ បំណិនវិជ្ជាជីវៈ សម្រាប់បំប៉ននាយកសាលាបឋមសិក្សានិងមធ្យមសិកក្សា (ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ), ២០១៦)

-សៀវភៅ ការគ្រប់គ្រងនឹងភាពជាអ្នកដឹកនាំ សម្រាប់បំប៉ននាយកសាលាបឋមសិក្សានិងមធ្យមសិកក្សា (ក្រសួងអប់រំ យុវជន និងកីឡា(នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ), ឆ្នាំ២០១៦ )

-ទម្រង់របាយការណ៍ស្វ័យវាយតម្លៃដំណើរការសិក្សាគន្លងជីវិតថ្មី (ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានធានាគុណភាពអប់រំ), ២០២១)

-សៀវភៅជំនួយស្មារតី អធិការកិច្ចតាមកាលកំណត់ ខែមករា ឆ្នាំ២០២១ (នាយកដ្ឋានធានាគុណភាពអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា, មករា ២០២១)

-វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត (វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ ២០០៨)

## ៣.៤.ការជ្រើសរើសគាគសំណាក

ដើម្បីសម្រេចបានលទ្ធផលល្អស្របនឹងតម្រូវការដែលអ្នកស្រាវជ្រាវចង់បាន ព្រមទាំងមានភាពជាក់លាក់ទាំងលទ្ធផលជាវិជ្ជមាននិងបញ្ហាប្រឈមនាកា ក្នុងការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀន យើងបានកំណត់យក គណៈគ្រប់គ្រង និងគ្រូបង្រៀននៃអនុវិទ្យាល័យទាំង១១ ដែលបានចុះអធិការកិច្ចតាមកាលកំណត់រួចក្នុងចំណោម១៦សាលា ក្រុង/ស្រុកចំនួន០៤។ អនុវិទ្យាល័យទាំងនោះរួមមាន១.ក្រុងសំរោងចំនួន០៥សាលា(អនុវិទ្យាល័យហ៊ុនសែនរូតចំប៉ី អនុវិទ្យាល័យស៊ូរ៉ែក

គុណពោធិវង្ស អនុវិទ្យាល័យបន្សាយរាក់ អនុវិទ្យាល័យកូនក្រៀល អនុវិទ្យាល័យបុស្សរ)។២.ស្រុកចុងកាល់ចំនួន០២សាលា(អនុវិ.សម្តេចតេជោ ហ៊ុនសែន ចុងកាល់ អនុវិ.ជើងទៀន)។ ៣.ស្រុកបន្ទាយអំពិលចំនួន០២សាលា (អនុវិ. គោកឪឡោក អនុវិទ្យាល័យ បេង)។ ៤.ស្រុកអន្លង់វែងចំនួន០២សាលា (អនុវិទ្យាល័យតេជោអូរស្រមរ អនុវិទ្យាល័យថ្លាត)។ ចំពោះសំណាកជាធនធានមនុស្សមាន នាយកសាលារៀន១៥នាក់ស្រី០១នាក់ គ្រូបង្រៀន៨៥នាក់ស្រី៣៥នាក់ សរុបចំនួន១០០នាក់ ស្រី៣៦នាក់។

## ៣.៥.ការវិភាគទិន្នន័យ

ដើម្បីទទួលបានលទ្ធផលល្អស្របទៅតាមការរៀបចំកម្រងសំណួរ និងការផ្តល់ចម្លើយពីគណៈគ្រប់គ្រង ព្រមទាំងលោកគ្រូអ្នកគ្រូ យើងបានប្រើប្រាស់កម្មវិធី Microsoft Excel ក្នុងការវិភាគទិន្នន័យ ធ្វើតារាង សង់ក្រាប ភាគរយ ដោយអនុវត្តតាមបែបបរិមាណវិស័យ ទាក់ទងនឹងការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀនពីអ្នកពាក់ព័ន្ធនានារួមមាន គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនតាមសាលាគោលដៅទាំង១១។ ចម្លើយដែលយើងទទួលបានពីសំណាកគោលដៅហើយបានយកមកធ្វើការវិភាគ គឺផ្តោតទៅលើការគ្រប់គ្រងនិងដឹកនាំរបស់គណៈគ្រប់គ្រងសាលា ការបំពេញការងាររបស់គណៈគ្រប់គ្រង និងគ្រូបង្រៀន ការកែលម្អសាលារៀនតាមអនុសាសន៍អធិការកិច្ច ការយល់ឃើញទៅលើរបាយការណ៍អធិការកិច្ច និងបញ្ហាប្រឈមរបស់សាលារៀនក្នុងការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់។ ចំពោះកម្រិតវាយតម្លៃយើងបានយកតាមទម្រង់និទ្ទេសនៃការដាក់ពិន្ទុសិស្សដែលចេញដោយក្រសួងអប់រំ យុវជន និងកីឡាមានដូចជា៖

| | | |
|---|---|---|
| - ល្អណាស់ | ៖៩.៥០ដល់១០ | =៩៥%-១០០% |
| - ល្អ | ៖៨.០០ដល់៩.៤៩ | =៨០%-៩៤.៩% |
| - ល្អបង្គួរ | ៖៦.៥០ដល់៧.៩៩ | =៦៥%-៧៩.៩% |
| - មធ្យម | ៖៥.០០ដល់៦.៤៩ | =៥០%-៦៤.៩% |
| - ខ្សោយ | ៖ក្រោម៥.០០ | =ក្រោម៥០% |

(ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០២១)

# ជំពូកទី៤

# ជំពូកទី៤
# លទ្ធផល និងការពិភាក្សា

ជំពូកនេះយើងនឹងបង្ហាញពីលទ្ធផល ដែលទទួលបានពីការស្រាវជ្រាវដើម្បីធ្វើការបកស្រាយ និងវិភាគទិន្នន័យទៅតាមចំណុចគោលនានាក្នុងកម្រងសំណួរជាលំដាប់លំដោយ។

## ៤.១.ឧបករណ៍វិភាគទិន្នន័យ

នៅក្នុងផ្នែកនេះដើម្បីបញ្ចូល និងវិភាគទិន្នន័យបាន ព្រមទាំងធ្វើការបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវមួយដែលធានានូវភាពត្រឹមត្រូវគ្រប់ជ្រុងជ្រោយកម្មវិធីMicrosoft Excel ជាឧបករណ៍បច្ចេកវិទ្យាវិទ្យាសាស្ត្រមួយបែបអាចធានាបាន។ វាត្រូវបានចាត់ទុកជាជញ្ជីងយុត្តិធម៌មួយក្នុងការវិភាគទិន្នន័យដែលទទួលបានពីលោកគ្រូ អ្នកគ្រូ និងនាយក នាយិកា នាយករងតាមរយៈតំណភ្ជាប់ Link Google Form ព្រមទាំង Telegram ជាជំនួយផងដែរ។ ផ្ដើមចេញពីកម្មវិធីទាំងអស់ យើងបានសង់ក្រាប និងវិភាគដោយមានការសរសេរបកស្រាយពន្យល់ឱ្យបានប្រាកដប្រជាទៅតាមអាទិភាពនៃសំណួរនីមួយៗផងដែរ។

## ៤.២.ដំណាក់កាលនៃការវិភាគទិន្នន័យ

បន្ទាប់ពីទទួលបានទិន្នន័យតាមរយៈកម្រងសំណួរទម្រង់ Google Form ពី លោកគ្រូ អ្នកគ្រូ និងនាយក នាយិកា នាយករង រួចមក ត្រូវបានបញ្ចូលទិន្នន័យទាំងនោះក្នុងកម្មវិធីរួចធ្វើការវិភាគលទ្ធផលនៅក្នុងជំពូក៤ ទៅតាមលំដាប់លំដោយនៃកម្រងសំណួរ ដើម្បីរកឱ្យឃើញពីប្រសិទ្ធភាពនៃការអនុវត្តអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀន ព្រមទាំងរកឱ្យឃើញពីបញ្ហាប្រឈមនានារបស់សាលាក្នុងការអនុវត្តរបាយការណ៍នេះផងដែរ។ អ្វីដែលកាន់តែពិសេសនោះគឺដើម្បីចូលរួមចំណែកជាទុនមួយ ក្នុងការជំរុញដល់ការអភិវឌ្ឍវិស័យអប់រំ ស្របតាមការចង់បាន និងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា។

## ៤.៣.ការវិភាគទិន្នន័យ

ជាក់ស្ដែងបន្ទាប់ពីមានឧបករណ៍វិភាគគ្រប់គ្រាន់ ទិន្នន័យក្នុងដៃគ្រប់ជ្រុងជ្រោយ ស្ថិតក្នុងដំណាក់កាលនៃការអនុវត្តកិច្ចដំណើរការស្រាវជ្រាវតាមកម្មវិធី និងផែនការរបស់សាលារៀនផងដែរនោះ យើងបាន

ស្រាវជ្រាវដោយលើកយកការផ្តល់ទិន្នន័យត្រឡប់ពី នាយក នាយិកា លោកគ្រូ អ្នកគ្រូ តាមលំដាប់លំដោយពីកម្រងសំណួរ សម្រាប់លោកគ្រូ អ្នកគ្រូ រហូតដល់កម្រងសំណួររបស់នាយក នាយិកា នាយករងសាលារៀន។ ពិសេសវិភាគលើចំណុចទាំង០៧នៃអនុសាសន៍របស់ក្រុមអធិការកិច្ចដែលបានដាក់ឱ្យសាលារៀនអនុវត្តដើម្បីកែលម្អ និងអភិវឌ្ឍទៀតផង។

## ៤.៣.១.ការវិភាគទិន្នន័យលើកម្រងសំណួរគ្រូបង្រៀន

### ៤.៣.១.១.ផ្នែកទី១ ព័ត៌មានទូទៅ

**ក.ភេទ**

ក្រាបផ្ទិតខាងក្រោមនេះបង្ហាញពីភេទរបស់គ្រូបង្រៀនដែលបានផ្តល់ទិន្នន័យក្នុងការស្រាវជ្រាវៈ




រូបភាព 1 បង្ហាញពីភេទរបស់គ្រូបង្រៀន

ផ្អែកតាមក្រាបខាងលើនេះបង្ហាញថា គ្រូបង្រៀនភេទស្រីចំនួន៤២%នៃគ្រូបង្រៀន៦៦នាក់ បានបំពេញកម្រងសំណួរស្រាវជ្រាវ និងគ្រូបង្រៀនភេទប្រុសចំនួន៥៨%នៃគ្រូបង្រៀនដែលបានចូលបំពេញកម្រងសំណួរទាំង៦៦នាក់។ ករណីនេះអាចសន្និដ្ឋានថា អាជីពជាគ្រូបង្រៀនត្រូវបានចាប់អារម្មណ៍ និងលើកកម្ពស់ឱ្យបានការចូលរួមស្ថិតក្នុងសមាសភាពយ៉េនឌ័រស្ថិតក្នុងកម្រិតប្រហាក់ប្រហែលគ្នា។

## ខ.មុខវិជ្ជាឯកទេស

នៅក្នុងក្រាបខាងក្រោមបង្ហាញពីឯកទេសរបស់ គ្រូបង្រៀន នៃសាលាគោលដៅទាំង១១ ដែលបានបំពេញក្នុងកម្រងសំណួរទាក់ទងនឹងមុខវិជ្ជាឯកទេសដូចជា៖




រូបភាព 2 បង្ហាញពីមុខវិជ្ជាឯកទេសរបស់គ្រូបង្រៀនដែលបានបំពេញកម្រងសំណួរ

ផ្អែកលើក្រាបបង្ហាញថា គ្រូបង្រៀននៃសាលាគោលដៅបានចូលបំពេញកម្រងសំណួរ មាន១១ ឯកទេសគោល ហើយក្នុងនោះមានបីឯកទេសគោលដែលមានចំនួនច្រើនជាងគេគឺ ១.គណិតវិទ្យា និងរូបវិទ្យាមានចំនួន១០នាក់ ២.ឯកទេសភាសាខ្មែរ និងសីលធម៌ពលរដ្ឋ មានចំនួន១០នាក់ ៣.ឯកទេសអង់គ្លេស និងភាសាខ្មែរមានចំនួន១០នាក់។ រីឯកទេសច្រើនលំដាប់ទីពីរនេះគឺ ១.ឯកទេស ជីវវិទ្យានិងផែនដីវិទ្យា មានចំនួន០៨នាក់ និងឯកទេសរូបវិទ្យានិងគីមីវិទ្យាមានចំនួន០៨នាក់។ បន្ទាប់មកមានឯកទេសភាសាខ្មែរ និងគេហវិទ្យាមានចំនួន០៦នាក់ ឯកទេសប្រវត្តិវិទ្យានិងភូមិវិទ្យាមានចំនួន០៥នាក់ ឯកទេសអប់រំកាយនិងកីឡាមានចំនួន០៥នាក់ ឯកទេសភូមិវិទ្យា និងប្រវត្តិវិទ្យាមានចំនួន០២នាក់ និងឯកទេសសីលធម៌ពលរដ្ឋ និងភូមិវិទ្យាមានចំនួន០១នាក់ឯកទេស ICT និងអង់គ្លេសមានចំនួន០១នាក់។

ករណីនេះអាចសន្និដ្ឋានបានថា ភាគរយច្រើននៃគ្រូបង្រៀនមុខវិជ្ជាឯកទេសគឺ ១.គណិតវិទ្យា និងរូបវិទ្យា ២.ភាសាខ្មែរ និងសីលធម៌ពលរដ្ឋ ៣.អង់គ្លេស និងភាសាខ្មែរ មានចំនួន១០នាក់ដូចៗគ្នា ស្មើនឹង ៨៣.៣៣% ចំណែកមុខវិជ្ជាដែលមានតិចតួចគឺ ១.សីលធម៌ពលរដ្ឋនិងភូមិវិទ្យា និង ២.ឯកទេស ICTនិង អង់គ្លេស មានចំនួន០១នាក់ដូចគ្នាស្មើនឹង៨.៣៣%។ ហើយបើតាមការត្រួតពិនិត្យជាក់ស្តែងឃើញថា សាលាគោលដៅទាំង១១ខ្វះគ្រូបង្រៀនដែលមានឯកទេសទី១ គឺមីវិទ្យាទាំងអស់។ ជារួមការវិភាគពីឯកទេសរបស់គ្រូបង្រៀននេះគឺជាផ្នែកមួយនៃគុណភាព និងលទ្ធផលសិក្សារបស់សិស្សដែលចាំបាច់ទៅតាម និយាមក្នុងការប្រើប្រាស់គ្រូបង្រៀន នេះមានន័យថា បើសាលារៀនមានគ្រូបង្រៀនគ្រប់ឯកទេសនោះ លទ្ធភាពបង្រៀនដល់សិស្សបានគ្រប់គ្រាន់តាមតម្រូវការជាក់ស្តែងនៃការសិក្សារបស់សិស្សផងដែរ។

**គ.អាយុ**

ចំណុចនេះបង្ហាញពីអាយុរបស់លោកគ្រូ អ្នកគ្រូនៃសាលាគោលដៅទាំង១១ ដែលបានបំពេញក្នុង កម្រងសំណួរទាក់ទងនឹងភេទដូចក្រាបបង្ហាញខាងក្រោមនេះ៖




*រូបភាព 3 ក្រាបបង្ហាញពីអាយុរបស់លោកគ្រូ អ្នកគ្រូដែលបានចូលបំពេញកម្រងសំណួរ*

ផ្អែកលើក្រាបខាងលើនេះបង្ហាញថា លោកគ្រូអ្នកគ្រូដែលមានអាយុចន្លោះពី១៨ដល់២៥ឆ្នាំមាន ចំនួន១០នាក់ លោកគ្រូអ្នកគ្រូដែលមានអាយុ២៦ដល់៣៥ឆ្នាំមានចំនួន៣៨នាក់ លោកគ្រូអ្នកគ្រូដែល មានអាយុចន្លោះពី៣៦ដល់៤៥ឆ្នាំមានចំនួន១៧នាក់ លោកគ្រូអ្នកគ្រូមានអាយុចន្លោះពី៤៦ដល់៥៥ឆ្នាំ

មានចំនួន០១នាក់ ។ ជារួមការវិភាគពីអាយុរបស់គ្រូបង្រៀនគឺដើម្បីបង្ហាញពីបទពិសោធន៍ក្នុងការបង្រៀន និងចំណេះដឹងបន្ថែមថ្មីៗរបស់គ្រូ រវាងគ្រូចាស់និងគ្រូថ្មីស្របតាមបរិបទរីកចម្រើននាពេលបច្ចុប្បន្ន។ម្យ៉ាងទៀតវាអាចនឹងដូចពាក្យសុភាសិតរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា បានលើកឡើងថា **ក្មេងរត់លឿន ចាស់ស្គាល់ផ្លូវ** នោះផងដែរ។ មានន័យថា គ្រូចាស់និងគ្រូក្មេង ទោះជាអាយុក្តី បទពិសោធន៍ក្តីមិនអាចខ្វះគ្នាបានឡើង គឺទាំងពីរភាគីត្រូវរួមគ្នាបង្កើតស្នាដៃ និងកសាងធនធានអប់រំឱ្យបានល្អប្រសើរ។

### ឃ.បទពិសោធន៍បង្រៀន

ក្រាបខាងក្រោមនេះបង្ហាញពីបទពិសោធន៍បង្រៀនរបស់គ្រូបង្រៀនក្នុងអាជីពជាគ្រូបង្រៀន៖




*រូបភាព 4 បទពិសោធន៍របស់គ្រូបង្រៀនក្នុងការបង្រៀន*

ផ្អែកតាមទិន្នន័យក្នុងក្រាបខាងលើបង្ហាញថា គ្រូបង្រៀនដែលមានបទពិសោធន៍ចន្លោះពី០១ឆ្នាំដល់១០ឆ្នាំមានចំនួន៣៨នាក់ គ្រូបង្រៀនដែលមានបទពិសោធន៍ចន្លោះពី១១ឆ្នាំដល់២០ឆ្នាំមានចំនួន២៤នាក់ គ្រូបង្រៀនដែលមានបទពិសោធន៍ចន្លោះពី២១ឆ្នាំដល់៣០ឆ្នាំមានចំនួន០៤នាក់ គ្រូបង្រៀនដែលមានបទពិសោធន៍ចាប់ពី៣១ឆ្នាំឡើងមានចំនួន០០នាក់ ។ ក្នុងន័យនេះបញ្ជាក់ថា គ្រូបង្រៀនភាគ

ច្រើនទើបចេញថ្មី ស្របនឹងតម្រូវការរបស់សាលារៀន ពិសេសត្រូវនឹងការដាក់ចេញជាអនុសាសន៍របស់ក្រុមអធិការកិច្ចពាក់ព័ន្ធនឹងចំណុចដែលបានរកឃើញ និងសំណូមពររបស់សាលារៀន។

**ខ.ចំនួនគ្រូតាមសាលារៀនដែលបានចូលបំពេញកម្រងសំណួរ**

តារាងខាងក្រោមនេះបង្ហាញពីចំនួនគ្រូតាមសាលារៀនគោលដៅទាំងអស់ដែលបានចូលបំពេញកម្រងសំណួររបស់អ្នកស្រាវជ្រាវ

| ល.រ | ឈ្មោះសាលាគោលដៅ | ចំនួនគ្រូ |
|---|---|---|
| ១ | អនុវិទ្យាល័យ ហ៊ុន សែនរួតចំប៉ី | ០៩ |
| ២ | អនុវិទ្យាល័យ ស៊ូវ៉ែកគុណពោធិវង្ស | ០៥ |
| ៣ | អនុវិទ្យាល័យ បន្ទាយរាក់ | ០៦ |
| ៤ | អនុវិទ្យាល័យ កូនក្រៀល | ០៨ |
| ៥ | អនុវិទ្យាល័យ បុស្សួរ | ០៨ |
| ៦ | អនុវិ.សម្តេចតេជោ ហ៊ុន សែន ចុងកាល់ | ០៣ |
| ៧ | អនុវិទ្យាល័យ ជើងទៀន | ០៥ |
| ៨ | អនុវិទ្យាល័យ គោកឪឡោក | ០៧ |
| ៩ | អនុវិទ្យាល័យ បេង | ០៦ |
| ១០ | អនុវិទ្យាល័យ តេជោ អូរស្រមរ | ០៣ |
| ១១ | អនុវិទ្យាល័យ ថ្លាត | ០៦ |
| **សរុប** | | **៦៦** |

*តារាងទី 1 ចំនួនគ្រូតាមសាលារៀនគោលដៅទាំងអស់ដែលបានចូលបំពេញកម្រងសំណួរ*

ផ្អែកតាមតារាងខាងលើបង្ហាញថា លោកគ្រូ អ្នកគ្រូសាលាគោលដៅទាំងអស់បានចូលបំពេញ

កម្រងសំណួររបស់អ្នកស្រាវជ្រាវមានចំនួនសរុប៦៦នាក់ក្នុងនោះ អនុវិទ្យាល័យ ហ៊ុន សែនរួតចំប៉ី មានចំនួន០៩នាក់, អនុវិទ្យាល័យ ស៊ូវ៉ែកគុណពោធិវង្ស មានចំនួន០៥នាក់, អនុវិទ្យាល័យ បន្សាយរាក់ មានចំនួន០៦នាក់, អនុវិទ្យាល័យ កូនក្រៀល មានចំនួន០៨នាក់, អនុវិទ្យាល័យ បុស្សូរ មានចំនួន ០៨ នាក់ , អនុវិ.សម្តេចតេជោ ហ៊ុន សែន ចុងកាល់ មានចំនួន០៣នាក់ ,អនុវិទ្យាល័យ ដើងទៀន មានចំនួន ០៥នាក់ ,អនុវិទ្យាល័យ គោកឪឡោក មានចំនួន០៧នាក់ ,អនុវិទ្យាល័យ បេង មានចំនួន០៦នាក់, អនុវិទ្យាល័យ តេជោ អូរស្រមរ មានចំនួន០៣នាក់, អនុវិទ្យាល័យ ថ្លាត មានចំនួន០៦នាក់។ តាមទិន្នន័យនេះបញ្ជាក់ថា គ្រូបង្រៀនដែលបានចូលបំពេញមានចំនួន៧៧.៦៥% នៃសាលាគោលដៅទាំង១១ ករណីគ្រូមិនបានចូលបំពេញកម្រងសំណួរបាន១០០% នេះបើតាមការទទួលព័ត៌មានត្រឡប់ពីលោកគ្រូអ្នកគ្រូ និងនាយកសាលាគឺ មកពីគ្រូបង្រៀនជាប់ការងារជួយត្រួតពិនិត្យសិស្សចាក់វ៉ាក់សាំង ហើយខ្លះទៀតជាប់ចត្តាឡីស័ក និងមួយចំនួនទៀតនៅតំបន់គ្មានសេវាគ្រប់គ្រាន់មិនអាចបំពេញកម្រងសំណួរបាន។

### ច.ចម្ងាយធ្វើដំណើរពីផ្ទះឬកន្លែងស្នាក់នៅ ទៅសាលារៀន

តារាងខាងក្រោមបង្ហាញពីចម្ងាយធ្វើដំណើរពីផ្ទះ ទៅសាលារៀនរបស់គ្រូបង្រៀន

| ល.រ | ប្រភេទចម្ងាយ | ចំនួនគ្រូ |
|---|---|---|
| ១ | ក.០គីឡូម៉ែត្រ ដល់៥គីឡូម៉ែត្រ | ៣១នាក់ |
| ២ | ខ.៦គីឡូម៉ែត្រ ដល់១០គីឡូម៉ែត្រ | ១២នាក់ |
| ៣ | គ.១១គីឡូម៉ែត្រ ដល់២០គីឡូម៉ែត្រ | ១៥នាក់ |
| ៤ | ឃ.២១គីឡូម៉ែត្រ ដល់២៥គីឡូម៉ែត្រ | ០០នាក់ |
| ៥ | ង.២៦គីឡូម៉ែត្រ ដល់៣០គីឡូម៉ែត្រ | ០៣នាក់ |
| ៦ | ច.៣១គីឡូម៉ែត្រឡើង | ០៥នាក់ |
| សរុប | | ៦៦នាក់ |

*តារាងទី 2 បង្ហាញពីចម្ងាយធ្វើដំណើររបស់លោកគ្រូ អ្នកគ្រូពីផ្ទះឬកន្លែងស្នាក់នៅ ទៅសាលារៀន*

ផ្អែកតាមទិន្នន័យក្នុងតារាងខាងលើបង្ហាញថា គ្រូបង្រៀនដែលបានផ្តល់ព័ត៌មានត្រឡប់ តាមទម្រង់ Google Form ចំនួនសរុប ៦៦នាក់ ស្មើនឹង ៧៧.៦៥%នៃគ្រូបង្រៀនសរុបក្នុងសាលាគោលដៅទាំង១១។ ម្យ៉ាងទៀត គ្រូបង្រៀនដែលមានទីលំនៅជិតបំផុតធៀបនឹងសាលារៀនចម្ងាយចន្លោះពី០គីឡូម៉ែត្រ ដល់០៥គីឡូម៉ែត្រមានចំនួន៣១នាក់ ស្មើនឹង៣៦.៤៧% ពី០៦គីឡូម៉ែត្រ ដល់១០គីឡូម៉ែត្រមានចំនួន១២នាក់ស្មើនឹង ១៤.១២% ពី១១គីឡូម៉ែត្រ ដល់២០គីឡូម៉ែត្រមានចំនួន១៥នាក់ ស្មើនឹង ១៧.៦៥% ពី២១គីឡូម៉ែត្រ ដល់២៥គីឡូម៉ែត្រគ្មានទិន្នន័យ ពី២៦គីឡូម៉ែត្រ ដល់៣០គីឡូម៉ែត្រមានចំនួន០៣នាក់ ស្មើនឹង ៣.៥៣% និងគ្រូបង្រៀនដែលមានទីលំនៅឆ្ងាយបំផុតចាប់ពី៣១គីឡូម៉ែត្រឡើងមានចំនួន០៥នាក់ស្មើនឹង៥.៨៨%។ លទ្ធលនេះយើងសន្និដ្ឋានថា គ្រូបង្រៀនដែលមានលំនៅដ្ឋាន ឬកន្លែងស្នាក់នៅជិតសាលារៀនមានភាគរយច្រើន ដែលជាឱកាសបង្កលក្ខណៈងាយស្រួលក្នុងការទៅបំពេញការងារបង្រៀននៅសាលារៀន ប៉ុន្តែបើគ្រូបង្រៀនណាម្នាក់ពុំមាន ឆន្ទៈក្នុងការងាររបស់ខ្លួនអាចនឹងមិនបំពេញការងារបានល្អឡើយទោះជានៅជិតឬឆ្ងាយក៏ដោយ។ផ្ទុយទៅវិញអាចបំពេញការងារបានល្អប្រសិនជាគ្រូបង្រៀនរូបណាមួយមានឆន្ទៈក្នុងកិច្ចការរបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួននោះ។

**ឆ.កម្រិតជំនាញវិជ្ជាជីវៈ**

ក្រាបខាងក្រោមនេះបង្ហាញពីកម្រិតជំនាញវិជ្ជាជីវៈរបស់គ្រូបង្រៀន នៃសាលាគោលដៅ៖




រូបភាព 5 ក្រាបបង្ហាញពីកម្រិតជំនាញវិជ្ជាជីវៈរបស់គ្រូបង្រៀន

ផ្អែកតាមក្រាបខាងលើបានបង្ហាញថា គ្រូបង្រៀនដែលមានកម្រិតជំនាញវិជ្ជាជីវៈនៅមធ្យមសិក្សាបឋមភូមិនៃសាលាគោលដៅដែលបានស្រាវជ្រាវមានដូចជា៖ ក្រោមបរិញ្ញាបត្រចំនួន៤៧នាក់ស្មើនឹង ៥៥.២៩%នៃចំនួនគ្រូបង្រៀនសរុប៨៥នាក់, បរិញ្ញាបត្រមានចំនួន១៨នាក់ ស្មើនឹង២១.១៨%, បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន០១នាក់ស្មើនឹង១.១៨%។ ករណីនេះអាចសន្និដ្ឋានថា គ្រូ១៩នាក់ស្មើនឹង ២២.៣៥%មានឱកាលក្នុងការសិក្សាស្រាវជ្រាវបន្ថែមចំណេះដឹង សមត្ថភាព លើមុខវិជ្ជារបស់ខ្លួន។ ពិសេសអាចមានការបង្រៀននិងរៀនមានវិធីសាស្ត្រល្អៗស្របតាមការធ្វើបច្ចុប្បន្នភាពវិស័យអប់រំ។ យើងលើកបែបនេះប្រសិនណាគ្រូបង្រៀនទាំងនោះចេះប្រើប្រាស់ចំណេះដឹងដែលទទួលបានថ្មីៗ របស់ខ្លួនប្រកបដោយមនសិការ និងឆន្ទៈខ្ពស់។ ផ្ទុយទៅវិញបើគ្រូបង្រៀនដែលទទួលមានវិជ្ជាជីវៈខ្ពស់ហើយ ប៉ុន្តែមិនមានឆន្ទៈនិងមនសិការក្នុងការងាររបស់ខ្លួនទេ នោះការមានវិជ្ជាជីវៈឬសញ្ញាបត្រខ្ពស់ក៏មិនបានជាប្រយោជន៍ឡើយ។ ចំណែកគ្រូបង្រៀនដែលមានវិជ្ជាជីវៈក្រោមបរិញ្ញាបត្រមានត្រឹមតែ៤៧នាក់ស្មើនឹង ៥៥.២៩%នេះជាចំនួនមួយដែលបង្ហាញថា គ្រូជាងពាក់កណ្តាលនៃសាលាគោលដៅមិនបានបន្តការសិក្សាបន្ថែមចំណេះដឹង និងសមត្ថភាពរបស់ខ្លួនឡើយ។ ចំណុចនេះយើងអាចសន្និដ្ឋានថា គ្រូបង្រៀនប្រើប្រាស់វិធីសាស្ត្រដដែលៗក្នុងការបង្រៀនតាមទម្លាប់របស់ខ្លួន ដែលជាការផ្ទុយនឹងអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនត្រង់មាត្រា៩បានលើកឡើងថា គ្រូបង្រៀនត្រូវស្វ័យសិក្សា និងស្រាវជ្រាវសម្រិតសម្រាំងបង្កើនចំណេះដឹងរបស់ខ្លួន និងចូលរួមក្នុងគ្រប់សកម្មភាពបណ្តុះបណ្តាលជាប្រចាំ។ គ្រូបង្រៀនត្រូវធ្វើការស្វ័យវាយតម្លៃ និងវាយតម្លៃលើការប្រតិបត្តិវិជ្ជាជីវៈបង្រៀន (រាជរដ្ឋាភិបាលកម្ពុជា, ខែកញ្ញា ឆ្នាំ២០០៨)។ ប៉ុន្តែបើករណីគ្រូបង្រៀនរូបណាមួយមានការសិក្សាស្រាវជ្រាវបន្ថែមចំពោះវិជ្ជាជីវៈរបស់ខ្លួនគ្រូបង្រៀនរូបនោះនឹងមានវិធីសាស្ត្រថ្មី ហើយការបង្រៀនក៏ល្អផងដែរ។ ការវិភាគខាងលើនេះយើងធ្វើឡើងចំពោះតែគ្រូបង្រៀនសាលាគោលដៅដែលបានផ្តល់ព័ត៌មានត្រឡប់ប៉ុណ្ណោះ ចំណែកគ្រូបង្រៀនដែលមិនបានផ្តល់ព័ត៌មានត្រឡប់យើងមិនបានយកមកគិតក្នុងទិន្នន័យនេះឡើង។

**ជ.ការចូលរួមក្នុងវគ្គបំប៉ន ឬសិក្ខាសាលា**

តារាងខាងក្រោមនេះបង្ហាញពីការចូលរួមក្នុងវគ្គបំប៉ន ឬសិក្ខាសាលានានារបស់គ្រូបង្រៀន ដែល

បានផ្តល់ព័ត៌មានត្រឡប់តាមរយៈកម្រងសំណួរ Google Form ពីសាលាគោលដៅទាំង១១ដែលមានជាបន្តបន្ទាប់ដូចជា៖

| ល.រ | ចម្លើយរបស់គ្រូបង្រៀន | ចំនួន | ភាគរយ |
|---|---|---|---|
| ១ | ធ្លាប់បានចូលរួមសិក្ខាសាលា | ៣៣នាក់ | ៣៨.៨២% |
| ២ | ធ្លាប់បានចូលរួមម្តងគត់ | ០១នាក់ | ១.១៨% |
| ៣ | ចូលរួមបានតិចតួច | ០២នាក់ | ២.៣៥% |
| ៤ | មិនធ្លាប់បានចូលរួម | ២៨នាក់ | ៣២.៩៤% |
| ៥ | មិនដែលធ្លាប់បានចូលរួមសោះ | ០២នាក់ | ២.៣៥% |
| សរុប | | ៦៦នាក់ | ៧៧.៦៥% |

*តារាងទី 3 ការចូលរួមក្នុងវគ្គបំប៉ន ឬសិក្ខាសាលានានារបស់គ្រូបង្រៀន*

ផ្អែកតាមទិន្នន័យក្នុងតារាងខាងលើបានបង្ហាញថា គ្រូបង្រៀនធ្លាប់បានចូលរួមសិក្ខាសាលាមានចំនួន៣៣នាក់ស្មើនឹង៣៨.៨២% គ្រូបង្រៀនធ្លាប់បានចូលរួមម្តងគត់មានចំនួន០១នាក់ ស្មើនឹង១.១៨% គ្រូបង្រៀនចូលរួមបានតិចតួចមានចំនួន០២នាក់ ស្មើនឹង២.៣៥% គ្រូបង្រៀនមិនធ្លាប់បានចូលរួមមានចំនួន២៨នាក់ ស្មើនឹង៣២.៩៤% គ្រូបង្រៀនមិនធ្លាប់បានចូលរួមទាល់តែសោះមានចំនួន០២នាក់ស្មើនឹង២.៣៥%។ ជារួមគ្រូបង្រៀនដែលធ្លាប់បានចូលរួមសិក្ខាសាលាមានចំនួន៣៦នាក់ស្មើនឹង ៤២.៣៥% និងគ្រូបង្រៀនដែលមិនធ្លាប់បានចូលរួមសិក្ខាសាលាមានចំនួន៣០នាក់ស្មើនឹងស្មើនឹង៣៥.២៩% ពោលគឺមានគម្លាតពីគ្នាត្រឹម០៦នាក់ ស្មើនឹង៧.០៦%ប៉ុណ្ណោះ។ ចំណុចនេះយើងអាចសន្និដ្ឋានថា៖ គ្រូបង្រៀនដែលធ្លាប់បានចូលរួមសិក្ខាសាលា និងគ្រូបង្រៀនដែលមិនធ្លាប់បានចូលរួមសិក្ខាសាលាមានចំនួនប្រហាក់ប្រហែលគ្នា ចំណុចនេះវាជាកត្តាជះឥទ្ធិពលដល់គុណភាពបង្រៀនរបស់គ្រូបង្រៀន និងលទ្ធផលសិក្សារបស់សិស្ស នៅសាលារៀនគោលដៅទាំង១១នៅមានកម្រិត។ ការវាយតម្លៃនេះគិតតែទិន្នន័យដែលយើងទទួលបានប៉ុណ្ណោះចំណែកទិន្នន័យដែលមិនបានទទួលយើងមិនបានបញ្ចូលឡើយ។

### ឈ.ចំនួនបុគ្គលិកតាមសាលាគោលដៅ

តារាងខាងក្រោមនេះបង្ហាញពីចំនួនបុគ្គលិកតាមសាលាគោលដៅនីមួយៗដែលកំពុងបម្រើការងារក្នុងពេលបច្ចុប្បន្ន៖

| ល.រ | ឈ្មោះសាលារៀន | ចំនួនបុគ្គលិកតាមសាលាដែលបានផ្តល់ចម្លើយ | ចំនួនបុគ្គលិកក្នុងសាលាគោលដៅ | |
|---|---|---|---|---|
| | | | សរុប | ស្រី |
| ១ | អនុវិទ្យាល័យ ហ៊ុន សែនរួតចំប៉ី | ០៩នាក់ | ១១នាក់ | ០២នាក់ |
| ២ | អនុវិទ្យាល័យ ស៊ូវ៉ែកគុណពោធិវង្ស | ០៥នាក់ | ០៩នាក់ | ០៤នាក់ |
| ៣ | អនុវិទ្យាល័យ បន្សាយរាក់ | ០៦នាក់ | ០៩នាក់ | ០៣នាក់ |
| ៤ | អនុវិទ្យាល័យ កូនក្រៀល | ០៨នាក់ | ១០នាក់ | ០១នាក់ |
| ៥ | អនុវិទ្យាល័យ បុស្សួរ | ០៨នាក់ | ១១នាក់ | ០៥នាក់ |
| ៦ | អនុវិ.សម្តេចតេជោហ៊ុនសែនចុងកាល់ | ០៣នាក់ | ១០នាក់ | ០៤នាក់ |
| ៧ | អនុវិទ្យាល័យ ជើងទៀន | ០៥នាក់ | ១៣នាក់ | ០៤នាក់ |
| ៨ | អនុវិទ្យាល័យ គោកឪឡោក | ០៧នាក់ | ០៨នាក់ | ០១នាក់ |
| ៩ | អនុវិទ្យាល័យ បេង | ០៦នាក់ | ០៧នាក់ | ០៦នាក់ |
| ១០ | អនុវិទ្យាល័យ តេជោ អូរស្រមរ | ០៣នាក់ | ០៥នាក់ | ០៣នាក់ |
| ១១ | អនុវិទ្យាល័យ ថ្លាត | ០៦នាក់ | ០៧នាក់ | ០៣នាក់ |
| សរុប | | ៦៦នាក់ | ១០០នាក់ | ៣៦នាក់ |

*តារាងទី 4 បង្ហាញពីចំនួនបុគ្គលិកតាមសាលាគោលដៅនីមួយៗ*

ផ្អែកលើតារាងខាងលើបង្ហាញថា ចំនួនបុគ្គលិកក្នុងសាលារៀននីមួយៗដែលបានផ្តល់ស្ថិតិឱ្យតាមកម្រងសំណួរឃើញថា ក្រុងសំរោង៖ អនុវិទ្យាល័យ ហ៊ុន សែនរួតចំប៉ី មានគ្រូចំនួន០៩នាក់ ស្មើនឹង

៨១.៨១%។ អនុវិទ្យាល័យ ស៊ូរ៉ែកគុណពោធិវង្សមានចំនួន០៥នាក់ ស្មើនឹង៦២.៥%។ អនុវិទ្យាល័យ បន្ទាយរាក់មានចំនួន០៦នាក់ស្មើនឹង៧៥%។អនុវិទ្យាល័យកូនក្រៀលមានចំនួន០៨នាក់ស្មើនឹង៨០%។ អនុវិទ្យាល័យ បុស្សូរ មានចំនួន០៨នាក់ស្មើនឹង៧២.៧៣%។ ស្រុកចុងកាល់៖ អនុវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន ចុងកាល់ មានចំនួន០៣នាក់ ស្មើនឹង៣៣.៣៣%។ និងអនុវិទ្យាល័យ ដើងទៀនមានចំនួន០៥នាក់ស្មើនឹង៤៥%។ ស្រុកបន្ទាយអំពិល៖ អនុវិទ្យាល័យ គោកឪឡោក មានចំនួន០៧នាក់ស្មើនឹង៨៧.៥០% និងអនុវិទ្យាល័យ បេងមានចំនួន០៦នាក់ស្មើនឹង៨៥.៧១% ។ ស្រុកអន្លង់វែង៖ អនុវិ.តេជោ អូរស្រមរ មានចំនួន០៣នាក់ស្មើនឹង៧៥% និងអនុវិទ្យាល័យ ថ្លាត មានចំនួន ០៦នាក់ស្មើនឹង៨៥.៧១%។ តាមលទ្ធផលខាងលើនេះយើងសន្និដ្ឋានថា គ្រូបង្រៀនតាមសាលាគោលដៅទាំងអស់សុទ្ធតែអាចក្តាប់បានទិន្នន័យបុគ្គលិកអប់រំក្នុងសាលារៀនរបស់ខ្លួនបានត្រឹមត្រូវច្បាស់លាស់ ពិសេសគ្រូបង្រៀនតាមសាលារៀនចាប់ពី៦២.៥%ទៅ១០០% បានផ្តល់ព័ត៌មានត្រឡប់មានចំនួន០៩សាលាស្មើនឹង៨១.៨២%នៃសាលាគោលដៅ។ ដោយឡែកសាលាចំនួន០២ស្មើនឹង១៨.១៨% មានគ្រូចូលបំពេញកម្រងសំណួរទាបជាង៥០% ។ ជារួមការវិភាគពីការចូលរួមរបស់បុគ្គលិកអប់រំតាមសាលាគោលដៅទាំង១១ក្នុងការផ្តល់ព័ត៌មានត្រឡប់ ជុំវិញការចុះស្រាវជ្រាវរបស់នេះបង្ហាញពីកិច្ចសហការល្អរបស់គ្រូបង្រៀនក៏ដូចជាបង្ហាញពីការចូលរួមគាំទ្រដល់ការសិក្សារបស់អ្នកសិក្សានានាផងដែរ។ ហើយក្នុងនោះក៏អាចរកឃើញពីការមិនសហការ ឬគាំទ្ររបស់គ្រូបង្រៀនជុំវិញការសិក្សាស្រាវជ្រាវដែរ។

### ញ.ចំនួនអគារ និងចំនួនបន្ទប់តាមសាលារៀន

តារាងខាងក្រោមនេះ បង្ហាញពីចំនួនអគារ និងចំនួនបន្ទប់តាមសាលារៀនគោលដៅទាំងអស់៖

| ល.រ | ឈ្មោះសាលារៀន | ចំនួនបុគ្គលិកតាមសាលា ដែលបានផ្តល់ចម្លើយ | ចម្លើយផ្តល់ដោយ បុគ្គលិកក្នុងសាលា | |
|---|---|---|---|---|
| | | | ចំនួនអគារ | ចំនួនបន្ទប់ |
| ១ | អនុវិទ្យាល័យ ហ៊ុន សែនរូតចំប៉ី | ០៩នាក់ | ០២ខ្នង | ១១បន្ទប់ |

| | | | | |
|---|---|---|---|---|
| ២ | អនុវិទ្យាល័យ ស៊ូរ៉ែកគុណពោធិវង្ស | ០៥នាក់ | ០១ខ្នង | ០៤បន្ទប់ |
| ៣ | អនុវិទ្យាល័យ បន្សាយរាក់ | ០៦នាក់ | ០១ខ្នង | ០៥បន្ទប់ |
| ៤ | អនុវិទ្យាល័យ កូនក្រៀល | ០៨នាក់ | ០២ខ្នង | ០៩បន្ទប់ |
| ៥ | អនុវិទ្យាល័យ បុស្បូវ | ០៨នាក់ | ០១ខ្នង | ០៦បន្ទប់ |
| ៦ | អនុវិ.សម្តេចតេជោហ៊ុនសែនចុងកាល់ | ០៣នាក់ | ០១ខ្នង | ១២បន្ទប់ |
| ៧ | អនុវិទ្យាល័យ ជើងទៀន | ០៥នាក់ | ០១ខ្នង | ០៥បន្ទប់ |
| ៨ | អនុវិទ្យាល័យ គោកឪឡោក | ០៧នាក់ | ០១ខ្នង | ០៥បន្ទប់ |
| ៩ | អនុវិទ្យាល័យ បេង | ០៦នាក់ | ០១ខ្នង | ០៥បន្ទប់ |
| ១០ | អនុវិទ្យាល័យ តេជោ អូរស្រមរ | ០៣នាក់ | ០១ខ្នង | ១២បន្ទប់ |
| ១១ | អនុវិទ្យាល័យ ថ្លាត | ០៦នាក់ | ០១ខ្នង | ០៥បន្ទប់ |
| សរុប | | ៦៦នាក់ | ១៣ខ្នង | ៧៩បន្ទប់ |

*តារាងទី 5 បង្ហាញពីចំនួនអគារ និងចំនួនបន្ទប់តាមសាលារៀន*

ផ្អែកតារាងខាងលើបានបង្ហាញថា លោកគ្រូអ្នកគ្រូស្គាល់សាលារៀនច្បាស់លាស់ទើបអាចផ្តល់ព័ត៌មាននិងទិន្នន័យបានត្រឹមត្រូវទាំងអស់គ្នា។ ក្រុងសំរោង៖ អនុវិទ្យាល័យ ហ៊ុន សែនរួតចំប៉ី មានគ្រូចំនួន០៩នាក់ ស្មើនឹង៨១.៨១%។ អនុវិទ្យាល័យ ស៊ូរ៉ែកគុណពោធិវង្សមានចំនួន០៥នាក់ ស្មើនឹង៦២.៥%។ អនុវិទ្យាល័យ បន្សាយរាក់មានចំនួន០៦នាក់ស្មើនឹង៧៥%។អនុវិទ្យាល័យកូនក្រៀលមានចំនួន០៨នាក់ស្មើនឹង៨០%។ អនុវិទ្យាល័យ បុស្បូវ មានចំនួន០៨នាក់ស្មើនឹង៧២.៧៣%។ ស្រុកចុងកាល់៖ អនុវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន ចុងកាល់ មានចំនួន០៣នាក់ ស្មើនឹង៣៣.៣៣%។ និងអនុវិទ្យាល័យ ជើងទៀនមានចំនួន០៥នាក់ស្មើនឹង៤៥%។ ស្រុកបន្ទាយអំពិល៖ អនុវិទ្យាល័យ គោកឪឡោក មានចំនួន០៧នាក់ស្មើនឹង៨៧.៥០% និងអនុវិទ្យាល័យ បេងមានចំនួន០៦នាក់ស្មើនឹង៨៥.៧១% ។ ស្រុកអន្លង់វែង៖ អនុវិ. តេជោ អូរស្រមរ មានចំនួន០៣នាក់ស្មើនឹង៧៥% និងអនុវិទ្យាល័

យ ថ្លាត មានចំនួន ០៦នាក់ស្មើនឹង៨៥.៧១%។ តាមលទ្ធផលខាងលើនេះយើងសន្និដ្ឋានថា គ្រូបង្រៀនតាមសាលាគោលដៅ សុទ្ធតែអាចក្តាប់បានទិន្នន័យអគារ និងបន្ទប់ក្នុងសាលារៀនរបស់ខ្លួនបានត្រឹមត្រូវច្បាស់លាស់។រីឯសាលាចំនួន០២ស្មើនឹង១៨.១៨%បានចូលបំពេញកម្រងសំណួរទាបជាង៥០% ។

### ង.ចំនួនបង្គន់ និងចំនួនបន្ទប់តាមសាលារៀន

តារាងខាងក្រោមនេះ បង្ហាញពីចំនួនបង្គន់ និងចំនួនបន្ទប់តាមសាលារៀនគោលដៅទាំងអស់៖

| ល.រ | ឈ្មោះសាលារៀន | ចំនួនបុគ្គលិកតាមសាលាដែលបានផ្ដល់ចម្លើយ | ចំនួនបង្គន់ និងចំនួនបន្ទប់ | |
|---|---|---|---|---|
| | | | ចំនួនខ្នង | ចំនួនបន្ទប់ |
| ១ | អនុវិទ្យាល័យ ហ៊ុន សែនរួតចំប៉ី | ០១នាក់ | ០២ខ្នង | ០៤បន្ទប់ |
| | | ០៣នាក់ | ០២ខ្នង | ០៥បន្ទប់ |
| | | ០៤នាក់ | ០២ខ្នង | ០៦បន្ទប់ |
| | | ០១នាក់ | ០២ខ្នង | ១១បន្ទប់ |
| ២ | អនុវិទ្យាល័យ ស៊ូវ៉ែកគុណពោធិវង្ស | ០៤នាក់ | ០១ខ្នង | ០៦បន្ទប់ |
| | | ០១នាក់ | ០១ខ្នង | ០៨បន្ទប់ |
| ៣ | អនុវិទ្យាល័យ បន្សាយរាក់ | ០១នាក់ | ០២ខ្នង | ០៥បន្ទប់ |
| | | ០២នាក់ | ០២ខ្នង | ០៧បន្ទប់ |
| | | ០១នាក់ | ០២ខ្នង | ០៨បន្ទប់ |
| | | ០២នាក់ | ០២ខ្នង | ០៩បន្ទប់ |
| ៤ | អនុវិទ្យាល័យ កូនក្រៀល | ០១នាក់ | ០២ខ្នង | ០៤បន្ទប់ |
| | | ០២នាក់ | ០២ខ្នង | ០៥បន្ទប់ |
| | | ០៥នាក់ | ០២ខ្នង | ០៦បន្ទប់ |

| | | | | |
|---|---|---|---|---|
| ៥ | អនុវិទ្យាល័យ បុស្សូរ | ០៨នាក់ | ០១ខ្នង | ០៤បន្ទប់ |
| ៦ | អនុវិ.សម្តេចតេជោហ៊ុនសែនចុងកាល់ | ០៣នាក់ | ០១ខ្នង | ០៨បន្ទប់ |
| ៧ | អនុវិទ្យាល័យ ដើងទៀន | ០៥នាក់ | ០១ខ្នង | ០២បន្ទប់ |
| ៨ | អនុវិទ្យាល័យ គោកឪឡោក | ០៧នាក់ | ០១ខ្នង | ០៥បន្ទប់ |
| ៩ | អនុវិទ្យាល័យ បេង | ០៦នាក់ | ០១ខ្នង | ០៤បន្ទប់ |
| ១០ | អនុវិទ្យាល័យ តេជោ អូរស្រមរ | ០១នាក់<br>០២នាក់ | ០១ខ្នង<br>០១ខ្នង | ០៤បន្ទប់<br>០៨បន្ទប់ |
| ១១ | អនុវិទ្យាល័យ ថ្លាត | ០១នាក់<br>០២នាក់<br>០៣នាក់ | ០១ខ្នង<br>០១ខ្នង<br>០២ខ្នង | ០៤បន្ទប់<br>០៥បន្ទប់<br>០៩បន្ទប់ |
| សរុប | | ៦៦នាក់ | X | X |

*តារាងទី 6 បង្ហាញពីចំនួនបង្គន់ និងចំនួនបន្ទប់តាមសាលារៀន*

ផ្អែកតាមតារាងខាងលើបង្ហាញថា សាលារៀនចំនួន៥ ក្នុងនោះមានអនុវិទ្យាល័យ បុស្សូរ,អនុវិ. សម្តេចតេជោ ហ៊ុន សែន ចុងកាល់, អនុវិទ្យាល័យ ដើងទៀន, អនុវិទ្យាល័យ គោកឪឡោក, អនុវិទ្យាល័យ បេង និងអនុវិទ្យាល័យ តេជោអូរស្រមរ មានលោកគ្រូអ្នកគ្រូផ្តល់ទិន្នន័យបានត្រឹមត្រូវទាំងអស់គ្នា។ ចំណុចនេះបង្ហាញថា លោកគ្រូ អ្នកគ្រូស្គាល់ច្បាស់ពីហេដ្ឋារចនាសម្ព័ន្ធក្នុងសាលារៀនរបស់ខ្លួន។ ចំណែកសាលារៀនចំនួន០៦មាន គ្រូបង្រៀនផ្តល់ចម្លើយមិនបានត្រឹមត្រូវព្រមគ្នាឡើយ គឺអនុវិទ្យាល័យ ហ៊ុន សែនរូតចំប៉ី ក្នុងចំណោម០៨នាក់ អ្នកផ្តល់ចម្លើយត្រឹមត្រូវចំនួន០៤នាក់ ស្មើនឹង៥០%នៃចំនួនគ្រូដែលបានផ្តល់ព័ត៌មានត្រឡប់។ អនុវិទ្យាល័យ ស៊ូវ៉ែកគុណពោធិវង្ស បានផ្តល់ចម្លើយត្រឹមត្រូវ០៤នាក់ស្មើនឹង ៨០%នៃចំនួនគ្រូដែលបានផ្តល់ព័ត៌មានត្រឡប់ ។ អនុវិទ្យាល័យ បន្សាយរាក់ បានផ្តល់ចម្លើយត្រឹមត្រូវ ០២នាក់ស្មើនឹង ៣៣.៣៣%នៃចំនួនគ្រូដែលបានផ្តល់ព័ត៌មានត្រឡប់ ។ អនុវិទ្យាល័យ កូនក្រៀល បាន

ផ្តល់ចម្លើយត្រឹមត្រូវ០៥នាក់ស្មើនឹង ៦២.៥០%នៃចំនួនគ្រូដែលបានផ្តល់ព័ត៌មានត្រឡប់។ អនុវិទ្យាល័យ តេជោ អូរស្រមរ បានផ្តល់ចម្លើយត្រឹមត្រូវ០២នាក់ស្មើនឹង ៦៦.៦៧%នៃចំនួនគ្រូដែលបានផ្តល់ព័ត៌មានត្រឡប់ ។ អនុវិទ្យាល័យ ថ្លាត បានផ្តល់ចម្លើយត្រឹមត្រូវ០២នាក់ស្មើនឹង ៣៣.៣៣%នៃចំនួនគ្រូដែលបានផ្តល់ព័ត៌មានត្រឡប់។ ករណីនេះយើងសន្និដ្ឋានថា គ្រូបង្រៀននៅសាលាដែលមានភាគរយតិចក្នុងការផ្តល់ព័ត៌មានត្រឹមត្រូវនេះ មកពីគ្រូបង្រៀនទាំងអស់មិនចាប់អារម្មណ៍នឹងហេដ្ឋារចនាសម្ព័ន្ធសាលារៀន។

### ៤.៣.១.២.ផ្នែកទី២ការគ្រប់គ្រងនិងដឹកនាំ

### ៥.ការរៀបចំតុបតែងទីចាត់ការ និងហេដ្ឋារចនាសម្ព័ន្ធនានារបស់សាលារៀន

ក្រាបខាងក្រោមនេះបង្ហាញពីការកម្រិតនៃការរៀបចំតុបតែងទីចាត់ការ និងហេដ្ឋារចនាសម្ព័ន្ធនានារបស់សាលារៀនរបស់សាលាគោលដៅទាំងអស់៖




តារាងទី 7 ក្រាបបង្ហាញពីកម្រិតរៀបចំទីចាត់ការសាលារៀន

ផ្អែកតាមទិន្នន័យក្នុងក្រាបខាងលើបានបង្ហាញថា គ្មានសាលារៀនណាមួយបានរៀបចំតុបតែងទីចាត់ការលើសពី១០០%ឡើយ ប៉ុន្តែមានលោកគ្រូ អ្នកគ្រូចំនួន០១នាក់ស្មើនឹង១.១៨% បានផ្តល់ចម្លើយក្នុងទិន្នន័យថា សាលារៀនបានរៀបចំទីចាក់ការ១០០%។ លោកគ្រូ អ្នកគ្រូចំនួន១៨នាក់ស្មើនឹង ២១.១៨% បានផ្តល់ចម្លើយថា សាលារៀនបានរៀបចំទីចាក់ការ៨០-៩៩%។ លោកគ្រូ អ្នកគ្រូចំនួន២៧

នាក់ស្មើនឹង៣១.៧៦% បានផ្តល់ថា សាលារៀនបានរៀបចំទីចាក់ការ៦០-៧៩%។ លោកគ្រូ អ្នកគ្រូចំនួន ១៨នាក់ស្មើនឹង២១.១៨% បានផ្តល់ថា សាលារៀនបានរៀបចំទីចាក់ការ៥០-៥៩%។ លោកគ្រូ អ្នកគ្រូ ចំនួន០២នាក់ស្មើនឹង២.៣៥% បានផ្តល់ចម្លើយថា សាលារៀនបានរៀបចំទីចាក់ការក្រោម ៥០%។ ជារួមយើងសន្និដ្ឋានថា សាលារៀនភាគច្រើនបានរៀបចំតុបតែងទីចាត់ការ និងហេដ្ឋារចនាសម្ព័ន្ធនានាក្នុងអង្គភាពរបស់ខ្លួន។ ដោយឡែកសាលារៀនមួយចំនួនតូចបានរៀបចំប៉ុន្តែស្ថិតក្នុងកម្រិតក្រោម៥០% ដោយសាលារៀននោះទើបតែក្រុមអធិការកិច្ចចុះរួចរាល់ក្នុងឆ្នាំ២០២០ ក្រោយមកក៏ស្ថិតក្រោមឥទ្ធិពលវិបត្តិកូវីដ-១៩ សាលាត្រូវបានយកធ្វើជាមណ្ឌលចត្តាឡីស័ក ទើបបណ្តាលឱ្យសាលារៀនពុំមានឱកាសគ្រប់គ្រាន់ក្នុងការកែលម្អ។

## ឌ.ការរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនរបស់នាយក

ក្រាបខាងក្រោមនេះបង្ហាញពីការរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀន របស់លោកនាយក នាយិកាសាលារៀនស្របតាមអនុសាសន៍ក្រុមអធិការកិច្ច៖




រូបភាព 6 ក្រាបបង្ហាញពីការរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍របស់នាយក

ផ្អែកតាមក្រាបខាងលើនេះ លោកគ្រូ អ្នកគ្រូចំនួន០៣នាក់ស្មើនឹង៣.៥៣%បានផ្តល់ព័ត៌មាន

គ្រឡប់ថា នាយកសាលាបានរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍ជា រៀងរាល់សប្តាហ៍។ លោកគ្រូ អ្នកគ្រូចំនួន០២នាក់ស្មើនឹង២.៣៥%បានផ្តល់ព័ត៌មានត្រឡប់ថា នាយកសាលាបានរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍រៀងរាល់២សប្តាហ៍ម្តង។ លោកគ្រូ អ្នកគ្រូចំនួន៥០នាក់ស្មើនឹង៥៨.៨២%បានផ្តល់ព័ត៌មានត្រឡប់ថា នាយកសាលាបានរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍ជា ០១ខែម្តង។ ហើយលោកគ្រូ អ្នកគ្រូចំនួន០៤នាក់ស្មើនឹង៤.៧១%បានផ្តល់ព័ត៌មានត្រឡប់ថា នាយកសាលាមិនបានរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍ទាល់តែសោះ។ ជារួមអ្នកស្រាវជ្រាវសន្និដ្ឋានបានថា នាយកសាលាយកចិត្តទុកដាក់ក្នុងការអនុវត្តតាមអនុសាសន៍អធិការកិច្ចតាមកាលកំណត់ ដែលក្រុមការងារអធិការកិច្ចបានរកឃើញចំណុចត្រូវធ្វើការកែលម្អនៅសាលារៀន។

**៧.ការទទួលការចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនពី នាយកសាលា**

ក្រាបខាងក្រោមនេះបង្ហាញពីការទទួលការចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនពី នាយកសាលាចំពោះគ្រូបង្រៀន៖




រូបភាព 7 ក្រាបបង្ហាញពីការទទួលការចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនពីនាយក

ផ្អែកតាមក្រាបខាងលើបានបង្ហាញថា គ្រូបង្រៀនបាទទទួលការចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនពីនាយក បានតាមផែនការមានចំនួន ៤៣នាក់ ស្មើនឹង ៥០.៥៩% នៃសាលាគោលដៅ។ ម្យ៉ាងទៀតចម្លើយពីគ្រូបង្រៀនបានបញ្ជាក់ផ្អែកបានចុះដែរប៉ុន្តែមិនបានតាមផែនការមានចំនួន ១២នាក់ស្មើនឹង ១៤.១២%។ ដោយឡែកគ្រូបង្រៀនមួយភាគទៀតបានផ្តល់ចម្លើយមកថា មិនបានទទួលការចុះទាល់តែសោះមានចំនួន ១១នាក់ ស្មើនឹង១២.៩៤% ។ លទ្ធផលនេះយើងសន្និដានថា នាយកបានគោរពតាមអនុសាសន៍ក្នុងរបាយកាណ៍អធិការកិច្ច ដោយចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនរបស់ខ្លួនលើគ្រូបង្រៀន ប៉ុន្តែមួយភាគផ្សេងទៀតមិនបានចុះទាល់តែសោះដោយគ្រូបង្រៀនបញ្ជាក់ថា មកពីនាយករវល់ពេកក្នុងការងារ ម្យ៉ាងទៀតនាយកគាត់ជាប់បង្រៀនសិស្សដូចគ្រូបង្រៀនដែរ ខ្លះទៀតរវល់តែកែលម្អផ្នែកបរិស្ថាន និងមួយចំណុចទៀតគឺបណ្តាលមកពីវិបត្តិកូវីដ-១៩។

**ឈ.ការចូលរួមកែលម្អបរិស្ថានសាលារៀនរបស់គ្រូបង្រៀន**

ក្រាបខាងក្រោមនេះបង្ហាញពីកម្រិតចូលរួមកែលម្អបរិស្ថានសាលារៀនរបស់លោកគ្រូអ្នកគ្រូនៅតាមសាលារៀនគោលដៅទាំងអស់៖




*រូបភាព ៩ ក្រាបបង្ហាញពីកម្រិតចូលរួមកែលម្អបរិស្ថានសាលារៀនរបស់គ្រូបង្រៀន*

ផ្អែកលើទិន្នន័យតាមក្រាបខាងលើនេះបង្ហាញថា គ្រូបង្រៀនបានផ្តល់ព័ត៌មានត្រឡប់អំពីកម្រិតចូលរួមកែលម្អបរិស្ថានសាលារៀនបានលើសពី១០០%មានចំនួន០១នាក់ស្មើនឹង១.១៨%។បាន១០០% មានចំនួន០៥នាក់ស្មើនឹង៥.៨៨%។ បានពី៨០ទៅ៩០%មានចំនួន១៩នាក់ស្មើនឹង២២.៣៥%។ បានពី ៦០ទៅ៧០%មានចំនួន៣១នាក់ស្មើនឹង៣៦.៤៧%។ បានក្នុងកម្រិត៥០%មានចំនួន០៨នាក់ ស្មើនឹង ៩.៤៧%។ បានតិចជាង៥០%មានចំនួន០១នាក់ស្មើនឹង១.១៨%។ មិនបានកែលម្អទាល់តែសោះមានចំនួន០១នាក់ស្មើ១.១៨%។ លទ្ធផលនេះយើងសន្និដ្ឋានថា គ្រូបង្រៀនភាគច្រើនក្នុងបរិមាណ៦៤នាក់ស្មើនឹង៧៥%បានចូលរួមក្នុងការកែលម្អបរិស្ថានសាលារៀន។ ដោយឡែកគ្រូបង្រៀន០២នាក់ស្មើនឹង ២.៣៥%មិនបានចូលរួមកែលម្អបរិស្ថានសាលារៀន មូលហេតុចម្បងរបស់ពួកគាត់គឺមកពីបញ្ហាកូវីដ-១៩ ហើយសាលារៀនត្រូវបានដាក់ជាបណ្ឌលចត្តាឡីស័ក។

**គ.ការធ្វើកិច្ចតែងការ និងការឆ្លងនាយក ត្រួតពិនិត្យ**

ក្រាបខាងក្រោមនេះបង្ហាញពីកម្រិតបានធ្វើកិច្ចតែងការ និងបានយកមកឱ្យនាយក ត្រួតពិនិត្យដោយចុះហត្ថលេខា គ្រប់គ្រាន់មុននឹងបង្រៀនរបស់គ្រូបង្រៀននៅតាមសាលារៀនគោលដៅទាំងអស់៖




*រូបភាព ១ ក្រាបបង្ហាញពីកម្រិតនៃការធ្វើកិច្ចតែងការបង្រៀនរបស់គ្រូបង្រៀន*

ផ្អែកតាមក្រាបខាងលើបង្ហាញថា កម្រិតបានធ្វើកិច្ចតែងការបង្រៀន និងបានយកមកឱ្យនាយកត្រួតពិនិត្យ ដោយចុះហត្ថលេខា គ្រប់គ្រាន់មុននឹងយកទៅបង្រៀនរបស់លោកគ្រូ អ្នកគ្រូមានដូចជា៖ បានអនុវត្ត១០០% ទិន្នន័យ០០។ បានអនុវត្តពី៨០ទៅ៩០%មានចំនួន១២នាក់ស្មើនឹង១៤.១២%។ បានអនុវត្តពី៦០ទៅ៧០%បានចំនួន២០នាក់ស្មើនឹង២៣.៥៣%។ បានអនុវត្តត្រឹម៥០%មានចំនួន១៤នាក់ស្មើនឹង១៦.៤៧%។ បានអនុវត្តតិចជាង៥០%មានចំនួន២០នាក់ស្មើ២៣.៥៣%។ មិនបានអនុវត្តទាល់តែសោះគ្មានទិន្នន័យឡើយ។ តាមលទ្ធផលខាងលើនេះយើងសន្និដ្ឋានថា គ្រូបង្រៀនភាគច្រើនចំនួន៦៦នាក់ ស្មើនឹង៧៧.៦៥% បានធ្វើកិច្ចតែងការបង្រៀន និងបានយកមកឱ្យនាយក ត្រួតពិនិត្យដោយមានចុះហត្ថលេខាមុននឹងយកទៅបង្រៀន។ ក្នុងលទ្ធផលនេះផងដែរក៏មានគ្រូបង្រៀនខ្លះអនុវត្តបានតិចជា៥០%(ទិន្នន័យ ២៣.៥៣%) ដោយបានផ្តល់ព័ត៌មានមកថា បណ្តាលមកពីសសៃខ្ចី(ទើបសម្រាលកូនរួច) រវល់ការងារច្រើនបង្រៀនផង គណនេយ្យប្រចាំសាលាផង ម៉ោងបំពេញការងារច្រើន ពិសេសគឺបញ្ហាការរីករាលដាលនៃជំងឺកូវីដ១៩ ការបង្រៀននៅតាមផ្ទះ និងតាមអនឡាញ។

### ថ.ការតុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់របស់គ្រូបង្រៀន

ក្រាបខាងក្រោមនេះបង្ហាញពីកម្រិតបានតុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់របស់គ្រូបង្រៀន ៖




រូបភាព 10 កម្រិតបានតុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់របស់គ្រូបង្រៀន

ផ្អែកតាមក្រាបខាងលើបង្ហាញថា កម្រិតបានតុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់របស់គ្រូបង្រៀនមានទិន្នន័យដូចជាៈ បានអនុវត្ត១០០%ចំនួន ០១នាក់ ស្មើនឹង១.១៨%។ កម្រិតបានអនុវត្តពី៨០ទៅ៩០%មានចំនួន១៦នាក់ស្មើនឹង១៨.៨២%។ បានអនុវត្តពី៦០ទៅ៧០%បានចំនួន២៩នាក់ ស្មើនឹង៣៤.១២%។ បានអនុវត្តត្រឹម៥០%មានចំនួន១៥នាក់ស្មើនឹង១៧.៦៥%។ បានអនុវត្តតិចជាង៥០%មានចំនួន០២នាក់ស្មើនឹង២.៣៥%។ មិនបានអនុវត្តទាល់តែសោះមានចំនួន០៣នាក់ស្មើនឹង៣.៥៣%។ លទ្ធផលខាងលើនេះយើងសន្និដ្ឋានថា គ្រូបង្រៀនភាគច្រើនបាន៦៣នាក់ ស្មើនឹង៧៤.១២% បានតុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់នៅតាមសាលារៀនគោលដៅ។ ដោយឡែកលទ្ធផលចំនួន០៣នាក់ស្មើនឹង ៣.៥៣% បង្ហាញថាមិនបានអនុវត្តទាន់តែសោះដោយបណ្តាលមកពីការងារច្រើន បង្រៀនផង កាន់ការងារគណនេយ្យសាលាផង ខ្លះថាបង្រៀនក្រៅថ្នាក់ ហើយខ្លះទៀតថាសាលារៀនថ្មី មិនទាន់បានតុបតែង។

**ខ.ការរៀបចំសៀវភៅនានាតាមបែបបទរដ្ឋបាលគ្រូរបស់គ្រូបង្រៀន**

ក្រាបខាងក្រោមនេះបង្ហាញពីកម្រិតបានរៀបចំឱ្យមានសៀវភៅនានាតាមបែបបទរដ្ឋបាលគ្រូ ៖




*រូបភាព 11 ក្រាបបង្ហាញពីកម្រិតបានរៀបចំសៀវភៅនានាតាមបែបបទរដ្ឋបាលគ្រូ*

ផ្អែកតាមក្រាបខាងលើបង្ហាញថា កម្រិតបានរៀបចំសៀវភៅនានាតាមបែបបទរដ្ឋបាលគ្រូ មាន

ទិន្នន័យដូចជា៖ បានអនុវត្ត១០០%ចំនួន ០៥នាក់ ស្មើនឹង៥.៨៨%។ បានអនុវត្តបានអនុវត្តពី៨០ទៅ៩០%មានចំនួន១៨នាក់ស្មើនឹង២១.១៨%។បានអនុវត្តពី៦០ទៅ៧០% បានចំនួន២៤នាក់ស្មើនឹង២៨.២៤%។ បានអនុវត្តត្រឹម៥០%មានចំនួន១៦នាក់ស្មើនឹង១៨.៨២%។ បានអនុវត្តតិចជាង៥០%មានចំនួន០២នាក់ស្មើនឹង២.៣៥%។ មិនបានអនុវត្តទាល់តែសោះមានចំនួន០១នាក់ស្មើនឹង១.១៨%។ លទ្ធផលខាងលើនេះអ្នកស្រាវជ្រាវអាចសន្និដ្ឋានបានថា គ្រូបង្រៀនភាគច្រើនបាន ៦៥នាក់ ស្មើនឹង៧៦.៤៧% បានរៀបចំសៀវភៅនានាតាមបែបបទរដ្ឋបាលគ្រូដូចជា សៀវភៅពិន្ទុសិស្ស បញ្ជីហៅឈ្មោះ សេវាប្រចាំថ្ងៃគ្រូ និងសិស្ស សៀវភៅសម្រង់អត្តបទ សៀវភៅអវត្តមានថ្នាក់រៀនសិស្ស សៀវភៅតាមដានសៀវភៅសិក្ខាគារិក សៀវភៅអនុសាសន៍អធិការកិច្ច សៀវភៅប្រជុំ កិច្ចតែងការបង្រៀន សៀវភៅទំនាក់ទំនងអាណាព្យាបាលសិស្ស សៀវភៅរបាយការណ៍បរិបទកូវីដ-១៩ ។ ដោយឡែកលទ្ធផលចំនួន០១នាក់ស្មើនឹង១.១៨% បង្ហាញថាមិនបានអនុវត្តទាន់តែសោះដោយលើកជាយោបល់ថាមិនបានរៀបចំតែម្តង។

**ឆ.គុណភាព និងលទ្ធផលសិក្សារបស់សិស្ស**

ក្រាបខាងក្រោមនេះបង្ហាញពីគុណភាព និងលទ្ធផលសិក្សារបស់សិស្សមានការកើនឡើង ៖




រូបភាព 12 ក្រាបបង្ហាញពីគុណភាព និងលទ្ធផលសិក្សារបស់សិស្សកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ

ផ្អែកតាមទិន្នន័យក្នុងក្រាបខាងលើបង្ហាញថា មុខវិជ្ជាឯកទេសដែលមានគុណភាព និងលទ្ធផលសិក្សារបស់សិស្សមានការកើនឡើងជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំមានដូចជា៖ គណិតវិទ្យានិងរូបវិទ្យា ICT - អង់គ្លេស ប្រវត្តិវិទ្យានិងភូមិវិទ្យា ភាសាខ្មែរនិងសីលធម៌ពលរដ្ឋ រូបវិទ្យានិងគីមីវិទ្យា គណិតវិទ្យានិងរូបវិទ្យា ជីវវិទ្យានិងផែនដីវិទ្យា អប់រំកាយ និងកីឡា ភាសាខ្មែរនិងគេហវិទ្យា កើនពី១ដល់៥%ជារៀងរាល់ឆ្នាំមានគ្រូបង្រៀនចំនួន១៣នាក់ស្មើនឹង១៥.២៩%បានផ្តល់ព័ត៌មានត្រឡប់។ មុខវិជ្ជា ជីវវិទ្យានិងផែនដីវិទ្យា អប់រំកាយ និងកីឡា អង់គ្លេសនិងភាសាខ្មែរ គណិតវិទ្យានិងរូបវិទ្យា អង់គ្លេសនិងភាសាខ្មែរ ប្រវត្តិវិទ្យានិងភូមិវិទ្យា ភាសាខ្មែរនិងសីលធម៌ពលរដ្ឋ រូបវិទ្យានិងគីមីវិទ្យា អង់គ្លេសនិងភាសាខ្មែរ កើនពី៦ដល់១០%ជារៀងរាល់ឆ្នាំ មានគ្រូបង្រៀនចំនួន១៦នាក់ស្មើនឹង១៨.៨២%បានផ្តល់ព័ត៌មានត្រឡប់។ មុខវិជ្ជា ភាសាខ្មែរនិងគេហវិទ្យា សីលធម៌ពលរដ្ឋនិងភូមិវិទ្យា ភាសាខ្មែរនិងសីលធម៌ពលរដ្ឋ គណិតវិទ្យានិងរូបវិទ្យា រូបវិទ្យានិងគីមីវិទ្យា អប់រំកាយនិងកីឡា ជីវវិទ្យានិងផែនដីវិទ្យា អង់គ្លេសនិងភាសាខ្មែរ ភូមិវិទ្យានិងប្រវត្តិវិទ្យា កើនពី១១ដល់១៥%ជារៀងរាល់ឆ្នាំមានគ្រូបង្រៀនចំនួន១៧នាក់ស្មើនឹង២០.០០%បានផ្តល់ទិន្នន័យ។ មុខវិជ្ជា ជីវវិទ្យានិងផែនដីវិទ្យា អង់គ្លេសនិងភាសាខ្មែរ ភាសាខ្មែរនិងសីលធម៌ពលរដ្ឋ ភូមិវិទ្យានិងប្រវត្តិវិទ្យា រូបវិទ្យានិងគីមីវិទ្យា អង់គ្លេសនិងភាសាខ្មែរ ប្រវត្តិវិទ្យានិងភូមិវិទ្យា គណិតវិទ្យានិងរូបវិទ្យា អប់រំកាយនិងកីឡា ភាសាខ្មែរនិងគេហវិទ្យា មានលោកគ្រូអ្នកគ្រូផ្តល់ព័ត៌មានត្រឡប់ចំនួន១០នាក់ស្មើនឹង ១១.៧៦% ។ ហើយពុំមានមុខវិជ្ជាឯកទេសណាមួយដែលមានការកើនឡើងលើសពី២១%ឡើង។ ប៉ុន្តែមុខវិជ្ជាដែលលទ្ធផលសិក្សារបស់សិស្សមិនកើនទាល់តែសោះមានដូចជា៖ ភាសាខ្មែរនិងសីលធម៌ពលរដ្ឋ អង់គ្លេសនិងភាសាខ្មែរ គណិតវិទ្យានិងរូបវិទ្យា ភាសាខ្មែរនិងគេហវិទ្យា ជីវវិទ្យានិងផែនដីវិទ្យា អង់គ្លេសនិងភាសាខ្មែរ ភាសាខ្មែរនិងគេហវិទ្យា មានគ្រូបង្រៀនផ្តល់ទិន្នន័យចំនួន១០នាក់ស្មើ១១.៧៦%មកពី អនុវិ.កូនក្រៀល អនុវិ.បុស្សូរ អនុវិ.សម្តេចតេជោហ៊ុនសែនចុងកាល់ អនុវិ.គោកឪឡោក និងអនុវិ.បេង។ លទ្ធផលនេះយើងសន្និដ្ឋានថា មុខវិជ្ជាភាគច្រើនពីសាលាគោលដៅមានគុណភាព និងលទ្ធផលសិក្សារបស់សិស្សមានការកើតនឡើងជារៀងរាល់ឆ្នាំដោយឡែកមុខវិជ្ជា មួយចំនួននៃសាលាគោលដៅមិនមានលទ្ធផលសិក្សាកើនឡើង ព្រោះសិស្សមិនចូលចិត្តរៀន មិនចូលចិត្តអាន អវត្តមានច្រើន និងបោះបង់។

### ន.កម្រិតការចូលរួមពីសហគមន៍ជាមួយសាលារៀន

ក្រាបខាងក្រោមនេះបង្ហាញពីកម្រិតការចូលរួមពីសហគមន៍ជាមួយសាលារៀនគោលដៅ ៖




*រូបភាព 13 កម្រិតការចូលរួមពីសហគមន៍ជាមួយសាលារៀន*

ផ្អែកតាមទិន្នន័យក្នុងក្រាបខាងលើបង្ហាញថា គ្មានគ្រូបង្រៀនណាម្នាក់បានផ្តល់ទិន្នន័យអំពីការចូលរួមរបស់សហគមន៍ស្ថិតក្នុងកម្រិត ល្អណាស់ ឡើយ។ ប៉ុន្តែគ្រូបង្រៀនដែលបានផ្តល់ទិន្នន័យស្ថិតក្នុងកម្រិត ល្អ មានចំនួន១២នាក់ស្មើនឹង១៤.១២%។ កម្រិត ល្អបង្គួរ មានចំនួន១៩នាក់ស្មើនឹង២២.៣៥%។ កម្រិត មធ្យម មានចំនួន ៣១នាក់ស្មើនឹង ៣៦.៤៧%។ កម្រិត ក្រោមមធ្យម មានចំនួន០៣នាក់ស្មើនឹង៣.៥៣%។ កម្រិត ខ្សោយ មានចំនួន០១នាក់ស្មើនឹង១.១៨%។ តាមលទ្ធផលខាងលើនេះ យើងសន្និដ្ឋានថា គ្រូបង្រៀន៦២នាក់ស្មើនឹង៧២.៩៤%បានផ្តល់ទិន្នន័យពីកម្រិតចូលរួមរបស់សហគមន៍ជាវិជ្ជមាន ប៉ុន្តែគ្រូបង្រៀនចំនួន០៤នាក់បានផ្តល់ទិន្នន័យពីការទំនាក់ទំនងរបស់សហគមន៍ជាមួយសាលារៀនស្ថិតក្នុងកម្រិតក្រោមមធ្យម និងខ្សោយ ដោយបានបង្ហាញពីមូលហេតុនានាដូចជា នៅជនបទមាតាបិតាសិស្សមិនសូវយល់ពីការសិក្សា នាយកមិនសូវទំនាក់ទំនងជាមួយសហគមន៍ សាលាដាក់ចត្តាឡីស័កគណៈគ្រប់គ្រងនិងគ្រូបង្រៀនពុំទាន់បានផ្តល់នូវទំនុកចិត្តភាពទាក់ទាញក្នុងការធ្វើទំនាក់ទំនងឱ្យអស់ពីលទ្ធភាព អាណាព្យាបាលសិស្សមិនចូលរួម និងមិនសហការ ។

### ឫ.កម្រិតនៃការអភិវឌ្ឍរីកចម្រើនសាលារៀនបន្ទាប់ពី ចុះធ្វើអធិការ

ក្រាបខាងក្រោមនេះបង្ហាញពីកម្រិតនៃការអភិវឌ្ឍរីកចម្រើនរបស់សាលារៀន បន្ទាប់ពីក្រុមការងារកិច្ចបានចុះអធិការកិច្ចតាមកាលកំណត់រួចៈ




រូបភាព 14 ក្រាបបង្ហាញពីកម្រិតរីកចម្រើនរបស់សាលារៀនបន្ទាប់ពីចុះអធិការកិច្ច

ផ្អែកតាមក្រាបខាងលើបង្ហាញថា កម្រិតនៃការអភិវឌ្ឍរីកចម្រើនរបស់សាលារៀនបន្ទាប់ពីក្រុមការងារកិច្ចបានចុះតាមសាលាគោលដៅ ដែលផ្តល់ទិន្នន័យដោយគ្រូបង្រៀនមានដូចជាៈបានអនុវត្ត ១០០% គ្មានទិន្នន័យ ,បានអនុវត្តពី ៨០-៩៩% មានចំនួន០៩នាក់ ស្មើនឹង១០.៥៩%, បានអនុវត្ត៦០-ទៅ៧៩%មានចំនួន៣០នាក់ស្មើនឹង៣៥.២៩%,បានអនុវត្តពី ៥០-៦០% មានចំនួន២៤នាក់ ស្មើនឹង ២៨.២៤%,បានអនុវត្ត ក្រោម៥០% មានចំនួន០២នាក់ស្មើនឹង ២.៣៥%,មិនបានអនុវត្តទាល់តែសោះ មានចំនួន០១នាក់ស្មើនឹង១.១៨%។ លទ្ធផលខាងលើនេះយើងសន្និដ្ឋានថា កម្រិតនៃការអភិវឌ្ឍរីកចម្រើនរបស់សាលារៀនបន្ទាប់ពីចុះអធិការកិច្ចរួចមកសុទ្ធតែមានដំណើរការអភិវឌ្ឍចាប់ពី ៥០%-៨០% ហើយភាគរយដែលមានលោកគ្រូអ្នកគ្រូផ្តល់ទិន្នន័យច្រើនជាងគេគឺ៦០-៧៩%មានរហូតដល់៣៥,២៩% ។ ចំណែកគ្រូបង្រៀនដែលផ្តល់ទិន្នន័យ មិនបានអនុវត្តទាល់តែសោះមានត្រឹមតែ១.១៨%ប៉ុណ្ណោះ។

## ផ.ការវាយតម្លៃចុងក្រោយជាប្រចាំខែនៃដំណើរការសិក្សារបស់សាលារៀន

ក្រាបខាងក្រោមនេះបង្ហាញពី កម្រិតនៃការវាយតម្លៃចុងក្រោយជាប្រចាំខែនៃ ដំណើរការសិក្សារបស់សាលារៀនក្នុងពេលបច្ចុប្បន្ន (របាយការណស្វ័យវាយតម្លៃដំណើរការសិក្សាគន្លងជីវិតថ្មី)តាមសាលាគោលដៅទាំងអស់ ដែលលោកគ្រូអ្នកគ្រូបានទិន្នន័យៈ




*រូបភាព 15 កម្រិតវាយតម្លៃចុងក្រោយប្រចាំខែនៃដំណើរការសិក្សារបស់សាលារៀនក្នុងពេលបច្ចុប្បន្ន*

ផ្អែកតាមក្រាបខាងលើបង្ហាញថា កម្រិតនៃការវាយតម្លៃចុងក្រោយជាប្រចាំខែនៃ ដំណើរការសិក្សារបស់សាលារៀនក្នុងពេលបច្ចុប្បន្ន(របាយការណ៍ស្វ័យវាយតម្លៃដំណើរការសិក្សាគន្លងជីវិតថ្មី)តាមសាលាគោលដៅទាំងអស់ ដែលលោកគ្រូអ្នកគ្រូបានផ្តល់ទិន្នន័យគឺ កម្រិតទាប( ១.០០-១.៩៩ ) មានចំនួន០២នាក់ស្មើនឹង២.៣៥%,កម្រិតក្រោមមធ្យម( ២.០០-២.៩៩ ) មានចំនួន០៦នាក់ស្មើនឹង៧.០៦នាក់,កម្រិតមធ្យម (៣.០០-៣.៩៩ )មានចំនួន៣៣នាក់ស្មើនឹង៣៨.៨២%,កម្រិតបង្គួរ( ៤.០០-៤.៩៩ ) មានចំនួន២៥នាក់ស្មើនឹង២៩.៤១%,កម្រិតល្អ( ៥.០០ )មិនបានទទួលបានទិន្នន័យ។ លទ្ធផលខាងលើនេះយើងសន្និដ្ឋានថា សាលារៀនភាគច្រើនក្នុងពេលបច្ចុប្បន្នមានដំណើរការអភិវឌ្ឍបួនកម្រិតធំៗ ដែលកម្រិតមធ្យមមានភាគរយច្រើនជាងគេ៣៨.៨២% និងកម្រិតបង្គួរ ២៩.៤១% ព្រមទាំងតិចទៅៗពីកម្រិតក្រោមធ្យម រហូតដល់កម្រិតទាបបំផុត។ ជារួមកម្រិតនៃការវាយតម្លៃសាលារៀននេះបង្ហាញថា សាលាបានធ្វើការកែលម្អសាលារៀនរបស់ខ្លួនបាន ទៅតាមឱកាលនៃការអនុវត្តក្នុងទិដ្ឋភាពជាក់ស្តែងផងដែរ។

### ៤.៣.១.៣.ផ្នែកទី៣ បញ្ហាប្រឈមក្នុងការអនុវត្តរបាយការណ៍អធិការកិច្ច

### ៣.ការផ្ញើរបាយការណ៍អធិការកិច្ចតាមកាលកំណត់

ក្រាបខាងក្រោមនេះបង្ហាញពី ការផ្ញើរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់ក្រុមអធិការកិច្ចបន្ទាប់ពីបញ្ចប់ការងាររបស់ខ្លួនដល់សាលារៀនគោលដៅ៖




*រូបភាព 16 ក្រាបបង្ហាញពីការផ្ញើរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់ក្រុមអធិការកិច្ច*

ផ្អែកតាមក្រាបខាងលើបង្ហាញថា ការផ្ញើរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់ក្រុមអធិការកិច្ចបន្ទាប់ពីបញ្ចប់ការងាររបស់ខ្លួនដល់សាលារៀន តាមសាលាគោលដៅទាំងអស់ ដែលលោកគ្រូអ្នកគ្រូបានផ្តល់ព័ត៌មានត្រឡប់មានដូចជា បានផ្ញើដល់ក្រោយ២សប្តាហ៍ មានចំនួន៣៧នាក់ ស្មើនឹង៤៣.៥៣%,បានផ្ញើដល់ក្រោយ៣សប្តាហ៍ មានចំនួន១០នាក់ស្មើនឹង១១.៧៦%,បានផ្ញើដល់ក្រោយ៤សប្តាហ៍ មានចំនួន០៦នាក់ស្មើនឹង៧.០៦% បានផ្ញើដល់ក្រោយ៥សប្តាហ៍ មានចំនួន០២នាក់ស្មើនឹង២.៣៥%,និងមិនបានទទួលទាល់តែសោះ មានចំនួន១១នាក់ស្មើនឹង១២.៩៤%។ លទ្ធផលខាងលើនេះយើងសន្និដ្ឋានថា គ្រូបង្រៀនដែលបានផ្តល់ទិន្នន័យពីសាលារៀនគោលដៅនីមួយៗគឺស្ថិតនូវជាល្បាយ

តាមកម្រិតសំណួរដែលយើងផ្តល់ជម្រើស ក្នុងនោះជម្រើសខ្ពស់ជាងគេគឺ បានផ្ញើដល់ក្រោយ២សប្តាហ៍ មានរហូតដល់៤៣.៥៣% ចំណែកចំណុចជម្រើស មិនបានទទួលទាល់តែសោះ មានរហូតដល់ ១២.៩៤%។ ករណីនេះយើងយល់ថា អាចមកពីសាលារៀនមិនបានប្រជុំផ្សព្វផ្សាយអំពីការទទួលបាននៃរបាយការណ៍អធិការកិច្ចតាមកាលកំណត់ ដែលផ្ញើមកដល់សាលារៀនទើបគ្រូបង្រៀន តាមសាលានីមួយៗផ្តល់ទិន្នន័យមិនបានព្រមគ្នាក្នុងជម្រើសតែមួយតាមសាលារៀនសាម៉ី។

## ឥ.បញ្ហាប្រឈមខ្លាំងក្នុងការអនុវត្តរបាយការណ៍អធិការកិច្ច

តារាងខាងក្រោមនេះបង្ហាញពីទិន្នន័យដែលគ្រូបង្រៀនជួបបញ្ហាប្រឈមក្នុងការអនុវត្តអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់ ដែលក្រុមការងារអធិការកិច្ចបានដាក់ឱ្យកែលម្អទាក់ទងនឹងការងារបង្រៀននិងរៀន តាមសាលាគោលដៅទាំងអស់ ដែលលោកគ្រូអ្នកគ្រូបានផ្តល់ព័ត៌មានត្រឡប់៖

| ល.រ | បញ្ហាប្រឈម/ងាយស្រួល | ចំនួន |
|---|---|---|
| ១ | សិស្សមួយចំនួនមិនយកចិត្តទុកដាក់ចំពោះការសិក្សា អាណាព្យាបាលសិស្សប្រងើយកន្តើយមិនសហការចំពោះការសិក្សារបស់កូន ខ្វះខាតសម្ភារៈឧបទេស... | ០៩នាក់ |
| ២ | ការបង្រៀនមានយឺតយ៉ាវដោយសារមានបញ្ហាជំងឺកូវីដ១៩ | ០៥នាក់ |
| ៣ | សិស្សក្នុង១ថ្នាក់ៗមានចំនួនច្រើនពេក ខ្វះតុអង្គុយ ខ្វះអគារសម្រាប់សិក្សា | ០៤នាក់ |
| ៤ | ផលវិបាកទាក់ទងនិងការធ្វើកិច្ចតែងការបង្រៀនព្រោះលោកគ្រូអ្នកគ្រូខ្លះត្រូវបង្រៀនពីរទៅបីមុខវិជ្ជា សរសេរដោយដៃហើយប៊ិកខៀវ មិនអោយប្រើបច្ចេកវិទ្យា | ០៤នាក់ |
| ៥ | ការបង្រៀនដាក់ស្តែងភាសារបរទេស សិស្សនៅមានកម្រិត | ០១នាក់ |
| ៦ | បញ្ហា សាលាគ្មានភ្លើងអគ្គសនីប្រើប្រាស់ ទើបធ្វើអោយមានការរាំងស្ទះឯកសារ | ០១នាក់ |
| ៧ | ការកែលំអរបរិស្ថាន ការសិក្សារបស់សិស្ស លោកគ្រូអ្នកគ្រូមិនទាន់យល់ខ្លឹមសារ | ០១នាក់ |
| ៨ | ការខ្វះបច្ចេកទេស និងសម្ភារ | ០៤នាក់ |
| ៩ | ការសិក្សាតាមអនឡាញ សាលាដាក់ចត្តាឡីស័កបញ្ហាកូវីត១៩ | ០២នាក់ |

| | | |
|---|---|---|
| ១០ | ខ្វះសម្ភារពិសោធន៍ របស់ពិតៗដែលចង់ឲ្យសិស្សស្គាល់គឺអត់មាន | ០២នាក់ |
| ១១ | ការងារច្រើនបុគ្គលិកទីចាត់ការផង បង្រៀនផង ហើយម៉ោងលើសច្រើន | ០២នាក់ |
| ១២ | បញ្ហាប្រឈមគឺទាក់ទងនឹងវិធីសាស្ត្រថ្មីៗដែលអនុវត្តមិនទាន់បានល្អ | ០១នាក់ |
| ១៣ | សាលារៀននៅឆ្ងាយពីប្រជុំជន ហើយផ្លូវឆ្ងាយទៀត | ០៥នាក់ |
| ១៤ | សិស្សខ្សោយតាមមេរៀនមិនទាន់ ហើយថាវវល់ គ្មានលុយ | ០៥នាក់ |
| ១៥ | គ្មានបញ្ហាប្រឈម | ២០នាក់ |
| **សរុប** | | **៦៦នាក់** |

*តារាងទី 8 បញ្ហាប្រឈមខ្លាំងក្នុងការអនុវត្តគោលការណ៍អធិការកិច្ចតាមកាលកំណត់*

ផ្អែកតាមទិន្នន័យក្នុងតារាងខាងលើបង្ហាញថា បញ្ហាប្រឈមខ្លាំងក្នុងការអនុវត្តគោលការណ៍អធិការកិច្ចតាមកាលកំណត់(អនុសាសន៍) មានដូចជាៈសិស្សមួយចំនួនមិនយកចិត្តទុកដាក់ចំពោះការសិក្សាអាណាព្យាបាលសិស្សប្រងើយកន្តើយមិនសហការ គ្រូខ្វះខាតសម្ភារឧបទេស មានចំនួន ០៩នាក់ស្មើនឹង១០.៥៩%។ ការបង្រៀនមានយឺតយ៉ាវដោយសារបញ្ហាជំងឺកូវីដ-១៩ មានចំនួន០៥នាក់ស្មើនឹង៥.៨៩%។ សិស្សក្នុង១ថ្នាក់ៗមានចំនួនច្រើន ខ្វះតុអង្គុយ ខ្វះអគារសម្រាប់សិក្សា មានចំនួន០៤នាក់ស្មើនឹង៤.៧១%។ ផលវិបាកទាក់ទងនឹងការធ្វើកិច្ចតែងការបង្រៀនព្រោះគ្រូបង្រៀនខ្លះត្រូវបង្រៀនពីរទៅបីមុខវិជ្ជា សរសេរដោយដៃហើយប៊ិកខៀវ មិនអោយប្រើបច្ចេកវិទ្យា មានចំនួន០៤នាក់ស្មើនឹង៤.៧១%។ កម្រិតភាសាបរទេសសិស្សនៅមានកម្រិតមានចំនួន០១នាក់ស្មើនឹង១.១៨%។ បញ្ហា សាលាគ្មានភ្លើងអគ្គសនីប្រើប្រាស់ ទើបធ្វើអោយមានការរាំងស្ទះឯកសារ មានចំនួន០១នាក់ស្មើនឹង១.១៨%។ ការកែលំអបរិស្ថាន ការសិក្សារបស់សិស្ស លោកគ្រូអ្នកគ្រូមិនទាន់យល់ខ្លឹមសារមេរៀនច្បាស់ មានចំនួន០១នាក់ស្មើនឹង១.១៨%។ ការខ្វះបច្ចេកទេស និងសម្ភារ មានចំនួន០៤នាក់ស្មើនឹង៤.៧១%។ ការសិក្សាតាមអនឡាញ សាលាដាក់ចត្តាឡីស័កបញ្ហាកូវីដ-១៩ មានចំនួន០២នាក់ស្មើនឹង២.៣៥%។ខ្វះសម្ភារពិសោធន៍របស់ពិតៗដែលចង់ឱ្យសិស្សស្គាល់គឺអត់មានអ្វីបង្ហាញ ចំនួន០២នាក់ ស្មើនឹង២.៣៥%។ ការងារច្រើន

បុគ្គលិកទីចាត់ការផង បង្រៀនផង ហើយម៉ោងលើសច្រើន មានចំនួន០២នាក់ស្មើនឹង២.៣៥% ។ បញ្ហាប្រឈមគឺទាក់ទងនឹងវិធីសាស្ត្រថ្មីៗដែលអនុវត្តមិនទាន់បានល្អ មានចំនួន០១នាក់ស្មើនឹង១.១៨%។ សាលារៀននៅឆ្ងាយពីប្រជុំជន ហើយផ្លូវឆ្ងាយទៀត មានចំនួន០៥នាក់ស្មើនឹង៥.៨៨%។ សិស្សខ្សោយតាមមេរៀនមិនទាន់ ហើយថាវល់ គ្មានលុយ មានចំនួន០៥នាក់ស្មើនឹង៥.៨៨%។ មួយផ្នែកទៀតគ្រូបង្រៀនបានឆ្លើយថា គ្មានបញ្ហាប្រឈម មានចំនួន២០នាក់ស្មើនឹង២៣.៥៣%។ លទ្ធផលខាងលើយើងសន្និដ្ឋានថា បញ្ហាប្រឈមភាគច្រើនគឺពាក់ព័ន្ធនឹង សិស្សមិនចូលចិត្តរៀន អាណាព្យាបាលមិនយកចិត្តទុកដាក់ដល់ការសិក្សាកូន ម៉ោងបំពេញការងារច្រើន វិធីសាស្ត្រនិងការស្រាវជ្រាវរបស់គ្រូ គ្មានអគ្គិសនីប្រើប្រាស់ក្នុងសាលា ចំនួនសិស្សច្រើនក្នុងមួយថ្នាក់ៗ មានចំនួន៤៦នាក់ ស្មើនឹង៥៤.១៨%។ ក្នុងនោះដែរក៏មានគ្រូបង្រៀន២៣.៥៣%ដែលផ្តល់ទិន្នន័យថា គ្មានបញ្ហាប្រឈមកើតឡើងក្នុងការអនុវត្តឡើយ។

### ៤.៣.១.៤.ផ្នែកទី៤.ការយល់ឃើញរបស់គ្រូបង្រៀន

### ខ.កម្រិតអភិវឌ្ឍការងាររដ្ឋបាលគ្រូ និងរដ្ឋបាលថ្នាក់របស់គ្រូបង្រៀន

ក្រាបខាងក្រោមនេះបង្ហាញពី កម្រិតអភិវឌ្ឍការងាររដ្ឋបាលគ្រូ និងរដ្ឋបាលថ្នាក់របស់គ្រូបង្រៀនៈ




រូបភាព 17 ក្រាបបង្ហាញពីការអភិវឌ្ឍ ការងាររដ្ឋបាលគ្រូ តាមរយៈរបាយការណ៍អធិការកិច្ច

ផ្អែកតាមក្រាបខាងលើបង្ហាញថា គ្រូបង្រៀនដែលបានផ្តល់ទិន្នន័យពី ការអភិវឌ្ឍខ្លាំងណាស់ មានចំនួន០២នាក់ស្មើនឹង២.៣៥%។ អភិវឌ្ឍល្អ មានចំនួន៤៦នាក់ស្មើនឹង៥៤.១២%។ អភិវឌ្ឍខ្លះមិនអភិវឌ្ឍខ្លះ មានចំនួន១៨នាក់ស្មើនឹង២១.១៨%។ ចំណុច គ្មានជួយដល់ការអភិវឌ្ឍទេ យើងមិនទទួលបានទិន្នន័យឡើយ។ លទ្ធផលខាងលើយើងសន្និដ្ឋានថា របាយការណ៍អធិការកិច្ចតាមកាលកំណត់បានជួយដល់ការអភិវឌ្ឍការងាររដ្ឋបាលគ្រូ និងរដ្ឋបាលថ្នាក់ស្ថិតក្នុងភាគរយចាប់ពីអភិវឌ្ឍល្អដល់ល្អណាស់ មានចំនួនច្រើន៤៨នាក់ស្មើនឹង ៥៦.៤៧% ដោយឡែកមានគ្រូបង្រៀនចំនួន១៨នាក់ស្មើនឹង២១.១៨% ដែលឆ្លើយថា អភិវឌ្ឍខ្លះមិនអភិវឌ្ឍខ្លះដោយលើកមូលហេតុថា អនុសាសន៍ខ្លះអនុវត្តមិនទាន់ដល់ ខ្វះជំនាញ ថវិកាសាលាមានកំណត់ សហគមន៍ពុំសូវចូលរួម សាលាជាច់ស្រយាល ខ្វះការសហការ សិស្សខ្សោយ តាមមេរៀនមិនទាន់ ដោយសារបញ្ហាកូវីដ និងខ្វះសម្ភារៈប្រើប្រាស់ក្នុងការបង្រៀន។

**ឃ.ភាគរយការអនុវត្តការងារគ្រូបង្រៀន តាមអនុសាសន៍អធិការកិច្ច**

ក្រាបខាងក្រោមនេះបង្ហាញពី ភាគរយការអនុវត្តការងារគ្រូបង្រៀននិងការងាររបស់សាលារៀន តាមអនុសាសន៍អធិការកិច្ចតាមរយៈរបាយការណ៍អធិការកិច្ចតាមកាលកំណត់៖




រូបភាព 18 ភាគរយការអនុវត្តការងារគ្រូបង្រៀននិងការងាររបស់សាលារៀន

ផ្អែកតាមក្រាបខាងលើនេះបង្ហាញថា ភាគរយការអនុវត្តការងារគ្រូបង្រៀននិងការងាររបស់សាលារៀនដែលបានផ្ដល់ដោយគ្រូបង្រៀនមានដូចជា អនុវត្តបាន១០០% ទិន្នន័យទទួលបានចំនួន០២នាក់ស្មើនឹង២.៣៥% ,អនុវត្តបាន៩០% ទិន្នន័យទទួលបានមានចំនួន ០៩នាក់ស្មើនឹង១០.៥៩% , អនុវត្តបាន៨០% ទិន្នន័យទទួលបានមានចំនួន ១២នាក់ស្មើនឹង១៤.១២%,អនុវត្តបាន៧០% ទិន្នន័យទទួលបានមានចំនួន ១៥នាក់ស្មើនឹង១៧.៦៥%, អនុវត្តបាន៦០% ទិន្នន័យទទួលបានមានចំនួន ១៧នាក់ស្មើនឹង២០%,អនុវត្តបាន៥០% ទិន្នន័យទទួលបានមានចំនួន ១០នាក់ស្មើនឹង១១.៧៥%, អនុវត្តបានក្រោម៥០% គ្មានទិន្នន័យ,និងមិនបានអនុវត្តទាល់តែសោះ ទិន្នន័យទទួលបានមានចំនួន០១នាក់ស្មើនឹង១.១៨%។ លទ្ធផលនេះយើងសន្និដ្ឋានថា ភាគរយនៃការអនុវត្តការងារដែលខ្ពស់ជាងគេគឺ កម្រិត៦០% មានចំនួន១៧នាក់ ស្មើនឹង២០%។ ចំណែកគ្រូបង្រៀនដែលមិនបានអនុវត្តទាល់តែសោះ មានតែម្នាក់ប៉ុណ្ណោះ ដោយលើកពីចំណុចអំណះអំណាងថា មិនឃើញក្រុមការងារអធិការកិច្ចចុះទាល់តែសោះ។ ករណីនេះអាចមកពីគ្រូបង្រៀនរូបនេះមិនមានវត្តមាន ក្នុងសាលារៀននាឱកាសដែលពេលក្រុមការងារចុះអនុវត្តការងារ ឬទើបចូលបម្រើការងារថ្មីក្នុងសាលាគោលដៅនោះ។

## វ.កម្រិតការអភិវឌ្ឍរបស់សាលារៀន

ក្រាបខាងក្រោមនេះបង្ហាញពី កម្រិតអភិវឌ្ឍរបស់សាលារៀនគោលដៅ៖




រូបភាព 19 ក្រាបបង្ហាញពីកម្រិតការអភិវឌ្ឍរបស់សាលារៀន

ផ្អែកតាមក្រាបខាងលើបង្ហាញថា ទិន្នន័យដែលលោកគ្រូ អ្នកគ្រូបានផ្តល់ចំពោះសាលាគោលដៅទាំងអស់ក្នុងចំណោមកម្រិតទាំងបួនមានតែពីរកម្រិតប៉ុណ្ណោះដែលមានទិន្នន័យគឺ កម្រិតល្អមានចំនួន ២៥នាក់ ស្មើនឹង ២៩.៤១% ,កម្រិតពេញចិត្តមានចំនួន៤១នាក់ មានចំនួន ៤៨.២៤%។ ចំណែកកម្រិតល្អឥតខ្ចោះ និងកម្រិតមិនពេញចិត្តពុំមានទិន្នន័យផ្តល់ដោយគ្រូណាម្នាក់ឡើយ។ លទ្ធផលខាងលើនេះ យើងសន្និដ្ឋានថា សាលារៀនទាំងអស់មានការអភិវឌ្ឍ គ្រូបង្រៀនពេញចិត្តក្នុងការចូលរួមការងារ។

## ៤.៣.២.ការវិភាគទិន្នន័យលើគម្រូចសំណួរនាយកសាលា

### ៤.៣.២.១.ផ្នែកទី១ ព័ត៌មានទូទៅ

គណៈគ្រប់គ្រងសាលារៀនដែលបានផ្តល់ទិន្នន័យវិញតាមរយៈការសម្ភាសន៍តាមអនឡាញទម្រង់ Google Form ត្រូវបានជ្រើសរើសចេញក្នុងចំណោមសាលាមធ្យមសិក្សាបឋមភូមិដែលបានចុះអធិការកិច្ចតាមកាលកំណត់រួចតាមបណ្តាក្រុងស្រុកទាំង៤នៃខេត្តឧត្តរមានជ័យ។ នៅក្នុងចំណុចព័ត៌មានទូទៅនេះយើងវិភាគពី ភេទ ឋានៈតួនាទី វ័យ បទពិសោធន៍ការងារ អង្គភាព ចម្ងាយធ្វើដំណើរ កម្រិតជំនាញវិជ្ជាជីវៈ ប្រកាសតែងតាំង ការបំប៉ននិងសិក្ខាសាលា ស្ថិតិបុគ្គលិក អគារ និងបង្គន់អនាម័យ។

**ក.ភេទ**

ក្រាបខាងក្រោមបង្ហាញពីភេទរបស់គណៈគ្រប់គ្រងនៅតាមសាលាគោលដៅទាំង១១៖




រូបភាព 20 បង្ហាញពីភេទរបស់នាយក នាយិកា និងនាយករង

ផ្អែកតាមក្រាបខាងលើបង្ហាញថា ភេទស្រីដែលមានក្នុងតួនាទីគណៈគ្រប់គ្រងសាលារៀនមានចំនួន០១នាក់ស្មើនឹង៦.៦៧%និងភេទប្រុសក្នុងតួនាទីគណៈគ្រប់គ្រងសាលារៀនមានចំនួន១១នាក់ស្មើនឹង៧៣.៣៣%។ ករណីនេះយើងសន្និដ្ឋានថា គណៈគ្រប់គ្រងសាលា មានសមាសភាពយេនឌ័រដែលជាផ្នែកមួយបង្ហាញពីសមភាពយេនឌ័រដែលត្រូវបានយកចិត្តទុកដាក់ក្នុងវិស័យអប់រំនាពេលបច្ចុប្បន្ន ។

**ខ.ឋានៈតួនាទី**

គណៈគ្រប់គ្រងសាលារៀន នៃសាលាគោលដៅទាំង១១ ដែលបានបំពេញក្នុងកម្រងសំណួរទាក់ទងនឹងឋានៈតួនាទីដូចក្រាបបង្ហាញខាងក្រោម៖




រូបភាព 21 ក្រាបបង្ហាញពីឋានៈតួនាទីរបស់គណៈគ្រប់គ្រង

ផ្អែកតាមទិន្នន័យក្នុងក្រាបខាងលើបង្ហាញថា ឋានៈតួនាទីរបស់គណៈគ្រប់គ្រងសាលារៀនដែលបានចូលបំពេញកម្រងសំណួរមានដូចជា៖នាយកសាលាមានចំនួន១០នាក់ នាយិកាមានចំនួន០១នាក់ នាយករងមានចំនួន០១នាក់ នាយិការងមានចំនួន០០នាក់។ ករណីនេះអាចសន្និដ្ឋានថា មនុស្សប្រុសមានភាពរឹងមាំក្នុងការធ្វើកិច្ចការនេះ ទាំងបន្ទុកការងារ បញ្ហាប្រឈម ការលះបង់ពេលវេលា ជាដើម។ ចំណែកភេទស្រីដែលមានចំនួនដ៏តិចតួចនេះជាធនធានដ៏កម្រងដែលអាចធ្វើកិច្ចការនេះបានពិតជាគួរឱ្យកោតសរសើរ។

**គ.វ័យ(អាយុ)**

ក្រាបខាងក្រោមនេះបង្ហាញពីវ័យរបស់គណៈគ្រប់គ្រងសាលារៀននៃសាលាគោលដៅទាំង១១៖




រូបភាព 22 ក្រាបបង្ហាញពីវ័យរបស់គណៈគ្រប់គ្រងសាលារៀន

ផ្អែកតាមទិន្នន័យក្រាបខាងលើបង្ហាញថា វ័យ របស់គណៈគ្រប់គ្រង ដែលមានអាយុចន្លោះ១៨ឆ្នាំដល់២៥ឆ្នាំ ០០នាក់ ពី២៦ឆ្នាំដល់៣៥ឆ្នាំមានចំនួន០២នាក់ ពី៣៦ឆ្នាំដល់៤៥ឆ្នាំមានចំនួន០៤នាក់ ពី៤៦ឆ្នាំដល់៥៥ឆ្នាំមានចំនួន០៦នាក់ និងចាប់ពី៥៦ឆ្នាំឡើង០០នាក់។ ករណីនេះយើងសន្និដ្ឋានថា ភាគរយគណៈគ្រប់គ្រងដែលមានចំនួនច្រើនគឺមានវ័យចន្លោះ ពី៤៦ឆ្នាំដល់៥៥ឆ្នាំមានចំនួន០៦នាក់ ស្មើនឹង៥០%។យើងសន្និដ្ឋានថា ពួកគាត់មានភាពអត់ធ្មត់ចាស់ចិត្តគំនិត តស៊ូបំពេញការងារជាប្រចាំ ។

**ឃ.បទពិសោធន៍**

ក្រាបបង្ហាញពីបទពិសោធន៍ក្នុងការបំពេញការងារជាគណៈគ្រប់គ្រងសាលារៀន




រូបភាព 23 ក្រាបបង្ហាញពីបទពិសោធន៍ ដឹកនាំនិងគ្រប់គ្រង

ផ្អែកតាមទិន្នន័យក្នុងក្រាបបង្ហាញថា គណៈគ្រប់គ្រងដែលមានបទពិសោធន៍ចន្លោះពី០១ឆ្នាំទៅ ១០ឆ្នាំមានចំនួន០៥នាក់ បទពិសោធន៍ចន្លោះ១១ឆ្នាំដល់២០ឆ្នាំមានចំនួន០៧នាក់ ។ ចំណែកចាប់ពី ២១ឆ្នាំដល់៣០ឆ្នាំនិងចាប់ពី៣១ឆ្នាំឡើងពុំទទួលបានទិន្នន័យ។ ករណីនេះសន្និដ្ឋានថា គណៈគ្រប់គ្រង ដែលមានភាគរយបទពិសោធន៍ច្រើនចន្លោះពី១១ឆ្នាំដល់២០ឆ្នាំមាន០៧នាក់ស្មើនឹង ៤៦,៦៧%។

**ខ.ចំនួនគណៈគ្រប់គ្រងតាមសាលារៀនដែលបានចូលបំពេញកម្រងសំណួរ**

តារាងខាងក្រោមនេះបង្ហាញពីចំនួនគណៈគ្រប់គ្រងតាមសាលារៀនគោលដៅទាំងអស់ដែលបាន ចូលបំពេញកម្រងសំណួរស្រាវជ្រាវះ

| ល.រ | ឈ្មោះសាលាគោលដៅ | ចំនួន |
|---|---|---|
| ១ | អនុវិទ្យាល័យ ហ៊ុន សែនរូតចំប៊ី | ០២ |
| ២ | អនុវិទ្យាល័យ ស៊ូវ៉ែកគុណពោធិវង្ស | ០១ |
| ៣ | អនុវិទ្យាល័យ បន្សាយរាក់ | ០១ |
| ៤ | អនុវិទ្យាល័យ កូនក្រៀល | ០១ |
| ៥ | អនុវិទ្យាល័យ បុស្បូវ | ០១ |
| ៦ | អនុវិ.សម្តេចតេជោ ហ៊ុន សែន ចុងកាល់ | ០១ |
| ៧ | អនុវិទ្យាល័យ ដើងទៀន | ០១ |
| ៨ | អនុវិទ្យាល័យ គោកឪឡោក | ០១ |
| ៩ | អនុវិទ្យាល័យ បេង | ០១ |
| ១០ | អនុវិទ្យាល័យ តេជោ អូរស្រមរ | ០១ |
| ១១ | អនុវិទ្យាល័យ ថ្លាត | ០១ |
| **សរុប** | | **១២** |

*តារាងទី ១ ចំនួនគណៈគ្រប់គ្រងតាមសាលារៀនគោលដៅដែលបានចូលបំពេញកម្រងសំណួរ*

ផ្អែកតាមតារាងខាងលើបង្ហាញថា គណៈគ្រប់គ្រងសាលាគោលដៅទាំងអស់ បានចូលបំពេញកម្រងសំណួរស្រាវជ្រាវមានចំនួនសរុប១២នាក់ក្នុងនោះអនុវិទ្យាល័យហ៊ុនសែនរួតចំប៉ីមានចំនួន០២នាក់ ,អនុវិទ្យាល័យ ស៊ូវ៉ែកគុណពោធិវង្ស មានចំនួន០១នាក់, អនុវិទ្យាល័យ បន្សាយរាក់ មានចំនួន០១នាក់, អនុវិទ្យាល័យកូនក្រៀល មានចំនួន០១នាក់, អនុវិទ្យាល័យបុស្សួរ មានចំនួន០១នាក់, អនុវិ.សម្តេចតេជោ ហ៊ុន សែនចុងកាល់ មានចំនួន០១នាក់ ,អនុវិទ្យាល័យ ជើងទៀន មានចំនួន ០១នាក់ ,អនុវិទ្យាល័យ គោកឪឡោក មានចំនួន០១នាក់ ,អនុវិទ្យាល័យ បេង មានចំនួន០១នាក់, អនុវិទ្យាល័យ តេជោ អូរស្រមរ មានចំនួន០១នាក់,អនុវិទ្យាល័យ ថ្លាត មានចំនួន០១នាក់។ តាមទិន្នន័យនេះបញ្ជាក់ថា គណៈគ្រប់គ្រងដែលបានចូលបំពេញមានចំនួន៨០%។ យើងសន្និដ្ឋានថា គណៈគ្រប់គ្រងបានលះបង់ពេលវេលាក្នុងការជួយផ្តល់ទិន្នន័យស្រាវជ្រាវប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ បើទោះបីជាមានការរវល់ក៏ដោយ។

### ច. ចម្ងាយធ្វើដំណើរពីផ្ទះឬកន្លែងស្នាក់នៅរបស់នាយក ទៅសាលារៀន

តារាងខាងក្រោមនេះបង្ហាញពីចម្ងាយធ្វើដំណើរពីផ្ទះឬកន្លែងស្នាក់នៅរបស់គណៈគ្រប់គ្រង ទៅសាលារៀន ក្នុងការបំពេញការងារប្រចាំថ្ងៃ

| ល.រ | ប្រភេទចម្ងាយ | ចំនួន |
|---|---|---|
| ១ | ក.0គីឡូម៉ែត្រ ដល់៥គីឡូម៉ែត្រ | 0៦នាក់ |
| ២ | ខ.៦គីឡូម៉ែត្រ ដល់១0គីឡូម៉ែត្រ | 0៣នាក់ |
| ៣ | គ.១១គីឡូម៉ែត្រ ដល់២0គីឡូម៉ែត្រ | 0៣នាក់ |
| ៤ | ឃ.២១គីឡូម៉ែត្រ ដល់២៥គីឡូម៉ែត្រ | 00នាក់ |
| ៥ | ង.២៦គីឡូម៉ែត្រ ដល់៣0គីឡូម៉ែត្រ | 00នាក់ |
| ៦ | ច.៣១គីឡូម៉ែត្រឡើង | 00នាក់ |
| សរុប | | ១២នាក់ |

*តារាងទី 10 បង្ហាញពីចម្ងាយធ្វើដំណើររបស់នាយកពីផ្ទះឬកន្លែងស្នាក់នៅ ទៅសាលារៀន*

ផ្អែកតាមទិន្នន័យក្នុងតារាងខាងលើបង្ហាញថា គណៈគ្រប់គ្រងដែលបានផ្តល់ព័ត៌មានត្រឡប់ក្នុងការសម្ភាសន៍របស់អ្នកស្រាវជ្រាវតាមទម្រង់ Google Form ចំនួនសរុប ១២នាក់ ស្មើនឹង ៨០%នៃគណៈគ្រប់គ្រងសរុបក្នុងសាលាគោលដៅទាំង១១។ ម្យ៉ាងទៀត គណៈគ្រប់គ្រងដែលមានទីលំនៅជិតបំផុតធៀបនឹងសាលារៀនចម្ងាយចន្លោះពី០គីឡូម៉ែត្រ ដល់០៥គីឡូម៉ែត្រមានចំនួន០៦នាក់ ស្មើនឹង៤០%, ពី០៦គីឡូម៉ែត្រ ដល់១០គីឡូម៉ែត្រមានចំនួន០៣នាក់ស្មើនឹង ២០%, ពី១១គីឡូម៉ែត្រ ដល់២០គីឡូម៉ែត្រមានចំនួន០៣នាក់ ស្មើនឹង ២០%,ចំណែកពីពី២១គីឡូម៉ែត្រ ដល់២៥គីឡូម៉ែត្រ និង ពី២៦គីឡូម៉ែត្រដល់៣០គីឡូម៉ែត្រគ្មានទិន្នន័យ។ យើងសន្និដ្ឋានថា គណៈគ្រប់គ្រងដែលមានលំនៅដ្ឋាន ឬកន្លែងស្នាក់នៅជិតសាលារៀនមាន៤០%។ ករណីនេះបង្កលក្ខណៈងាយស្រួលក្នុងការទៅបំពេញការងារការគ្រប់គ្រងនិងដឹកនាំរួមក្នុងសាលារៀន ប៉ុន្តែបើគណៈគ្រប់គ្រងណាម្នាក់ពុំមានឆន្ទៈក្នុងការងាររបស់ខ្លួនអាចនឹងមិនបំពេញការងារបានល្អឡើយបើទៅជាលំនៅដ្ឋានជិតសាលារៀនក៏ដោយ។ រីឯគណៈគ្រប់គ្រងដែលមានទីលំនៅឆ្ងាយជាងគេពី១១គីឡូម៉ែត្រ ដល់២០គីឡូម៉ែត្រមានចំនួន០៣នាក់ ស្មើនឹង ២០% ។

**ឆ.កម្រិតជំនាញវិជ្ជាជីវៈ**

ក្រាបខាងក្រោមនេះបង្ហាញកម្រិតជំនាញវិជ្ជាជីវៈរបស់គណៈគ្រប់គ្រង ដែលបានផ្តល់ទិន្នន័យ៖




*រូបភាព 24 ក្រាបបង្ហាញពីកម្រិតជំនាញវិជ្ជាជីវៈរបស់គណៈគ្រប់គ្រង*

ផ្អែកតាមក្រាបខាងលើបានបង្ហាញថា គណៈគ្រប់គ្រងដែលមានកម្រិតជំនាញវិជ្ជាជីវៈនៅមធ្យមសិក្សាបឋមភូមិមានដូចជា៖ ក្រោមបរិញ្ញាបត្រចំនួន១០នាក់ស្មើនឹង៦៦.៦៧%នៃចំនួនគណៈគ្រប់គ្រងសរុប១៥នាក់, បរិញ្ញាបត្រមានចំនួន០២នាក់ ស្មើនឹង១៣.៣៣%,បរិញ្ញាបត្រជាន់ខ្ពស់និងបណ្ឌិតគ្មានទិន្នន័យឡើយ។ ករណីនេះយើងសន្និដ្ឋានថា គណៈគ្រប់គ្រង១៣.៣៣%បានបង្កឱកាលក្នុងការសិក្សាស្រាវជ្រាវបន្ថែមចំណេះដឹង សមត្ថភាព លើមុខវិជ្ជាក៏ដូចជាជំនាញគ្រប់គ្រង និងដឹកនាំរបស់ខ្លួន។ យើងលើកបែបនេះ ប្រសិនណាគណៈគ្រប់គ្រងទាំងនោះចេះប្រើប្រាស់ចំណេះដែលទទួលបានថ្មីៗរបស់ខ្លួនប្រកបដោយមនសិការ និងឆន្ទៈខ្ពស់។ ផ្ទុយទៅវិញបើគណៈគ្រប់គ្រងដែលទទួលបានវិជ្ជាជីវៈខ្ពស់ហើយប៉ុន្តែមិនមានឆន្ទៈនិងមនសិការក្នុងការងាររបស់ខ្លួនទេ ការមានវិជ្ជាជីវៈខ្ពស់ក៏គ្មានបានផលប្រយោជន៍អ្វីដែរ។ ចំណែកគណៈគ្រប់គ្រងដែលមានវិជ្ជាជីវៈក្រោមបរិញ្ញាបត្រមាន៦៦.៦៧%នេះជាចំនួនមួយដែលបង្ហាញថា គណៈគ្រប់គ្រងជាងពាក់កណ្ដាលនៃសាលាគោលដៅមិនបានបន្តការសិក្សាបន្ថែមចំណេះដឹងសមត្ថភាព គ្រប់គ្រងនិងដឹកនាំរបស់ខ្លួនឡើយ។ ចំណុចនេះយើងសន្និដ្ឋានថា គណៈគ្រប់គ្រង ប្រើប្រាស់ចំណេះដឹង បទពិសោធន៍ការងារមានស្រាប់ក្នុងការដឹកនាំនិងគ្រប់គ្រងសាលារៀនតាមវ័យរបស់ខ្លួន។ គណៈគ្រប់គ្រងក៏មានក្របខណ្ឌជាគ្រូបង្រៀនដែរ ករណីនេះផ្ទុយនឹងអនុក្រឹត្យស្ដីពីក្រមសីធម៌វិជ្ជាជីវៈគ្រូបង្រៀនត្រង់មាត្រា៩បានលើកឡើងថា គ្រូបង្រៀនត្រូវស្វ័យសិក្សា និងស្រាវជ្រាវសម្រិតសម្រាំងបង្កើនចំណេះដឹងរបស់ខ្លួន និងចូលរួមក្នុងគ្រប់សកម្មភាពបណ្ដុះបណ្ដាលជាប្រចាំ។ គ្រូបង្រៀនត្រូវធ្វើការស្វ័យវាយតម្លៃ និងវាយតម្លៃលើការប្រិបត្តិវិជ្ជាជីវៈបង្រៀន។ ប៉ុន្តែបើករណីគណៈគ្រប់គ្រង រូបណាមួយមានការសិក្សាស្រាវជ្រាវបន្ថែមចំពោះវិជ្ជាជីវៈរបស់ខ្លួនគណៈគ្រប់គ្រងរូបនោះនឹងមានវិធីសាស្ត្រថ្មីក្នុងការគ្រប់គ្រងនិងដឹកនាំបានល្អផងដែរ។ ការវិភាគខាងលើនេះ យើងធ្វើឡើងចំពោះតែគណៈគ្រប់គ្រង សាលាគោលដៅដែលបានផ្ដល់ទិន្នន័យតែប៉ុណ្ណោះ។

### ជ.ការចូលរួមក្នុងវគ្គបំប៉ន ឬសិក្ខាសាលា

តារាងខាងក្រោមនេះបង្ហាញពីការចូលរួមក្នុងវគ្គបំប៉ន ឬសិក្ខាសាលានានារបស់គណៈគ្រប់គ្រងដែលបានផ្ដល់ទិន្នន័យតាមរយៈកម្រងសំណួរ Google Form ៖

| ល.រ | ចម្លើយរបស់គ្រូបង្រៀន | ចំនួន | ភាគរយ |
|---|---|---|---|
| ១ | ធ្លាប់បានចូលរួមសិក្ខាសាលា | ០៨នាក់ | ៥៣.៣៣% |
| ២ | ធ្លាប់បានចូលរួមម្ដងគត់ | ០០នាក់ | ០% |
| ៣ | ចូលរួមបានតិចតួច | ០០នាក់ | ០% |
| ៤ | មិនធ្លាប់បានចូលរួម | ០០នាក់ | ០% |
| ៥ | មិនដែលធ្លាប់បានចូលរួមសោះ | ០៤នាក់ | ២៦.២៧% |
| សរុប | | ១២នាក់ | ៨០% |

*តារាងទី 11 ការចូលរួមក្នុងវគ្គបំប៉ន ឬសិក្ខាសាលានានារបស់គណៈគ្រប់គ្រង*

ផ្អែកតាមទិន្នន័យក្នុងតារាងខាងលើបានបង្ហាញថា គណៈគ្រប់គ្រងដែបានឆ្លើយថាធ្លាប់បានចូលរួមសិក្ខាសាលាមានចំនួន០៨នាក់ស្មើនឹង៥៣.៣៣%, គណៈគ្រប់គ្រងដែលបានឆ្លើយថា មិនធ្លាប់បានចូលរួមទាល់តែសោះមានចំនួន០៤នាក់ ស្មើនឹង២៦.២៧% ។ ជារួមយើងបូកសរុបបានថា៖ គណៈគ្រប់គ្រងដែលធ្លាប់បានចូលរួមសិក្ខាសាលាមានភាគរយច្រើនជាង គណៈគ្រប់គ្រងដែលមិនបានចូលរួមសិក្ខាសាលា ។ ចំណុចនេះសន្និដ្ឋានថា៖ សាលារៀនដែលមានគណៈគ្រប់គ្រងធ្លាប់បានចូលរួមសិក្ខាសាលា អាចនឹងមានឱកាសអភិវឌ្ឍរីកចម្រើនល្អជាងសាលារៀនដែលពុំទាន់មានគណៈគ្រប់គ្រងបានឆ្លងកាត់វគ្គសិក្ខាសាលាឬបំប៉ននានា នៃសាលារៀនគោលដៅទាំងអស់។ ហើយគណៈគ្រប់គ្រងចំនួន២៦.២៧% មិនធ្លាប់បានចូលរួមវគ្គបំប៉នឬសិក្ខាសាលាពាក់ព័ន្ធនឹងការងារគ្រប់គ្រងរបស់ខ្លួនឡើយ។ ការវាយតម្លៃនេះគិតតែទិន្នន័យដែលអ្នកស្រាវជ្រាវទទួលបានប៉ុណ្ណោះ ចំណែកទិន្នន័យដែលមិនបានទទួល យើងមិនបានយកមបញ្ចូលក្នុងការបកស្រាយនេះទេ។

### ឈ.ចំនួនបុគ្គលិកតាមសាលាគោលដៅ

តារាងខាងក្រោមនេះបង្ហាញពីចំនួនបុគ្គលិកតាមសាលាគោលដៅនីមួយៗដែលកំពុងបម្រើការងារ

នាពេលបច្ចុប្បន្ន៖

| ល.រ | ឈ្មោះសាលារៀន | ចំនួនគណៈគ្រប់គ្រងដែលបានផ្តល់ចម្លើយ | ចំនួនបុគ្គលិកក្នុងសាលា | |
|---|---|---|---|---|
| | | | សរុប | ស្រី |
| ១ | អនុវិទ្យាល័យ ហ៊ុន សែនរួតចំប៉ី | ០២នាក់ | ១១នាក់ | ០២នាក់ |
| ២ | អនុវិទ្យាល័យ ស៊ូរ៉ែកគុណពោធិវង្ស | ០១នាក់ | ០៩នាក់ | ០៤នាក់ |
| ៣ | អនុវិទ្យាល័យ បន្សាយរាក់ | ០១នាក់ | ០៩នាក់ | ០៣នាក់ |
| ៤ | អនុវិទ្យាល័យ កូនក្រៀល | ០១នាក់ | ១០នាក់ | ០១នាក់ |
| ៥ | អនុវិទ្យាល័យ បុស្សូរ | ០១នាក់ | ១១នាក់ | ០៥នាក់ |
| ៦ | អនុវិ.សម្តេចតេជោហ៊ុនសែនចុងកាល់ | ០១នាក់ | ១០នាក់ | ០៤នាក់ |
| ៧ | អនុវិទ្យាល័យ ជើងទៀន | ០១នាក់ | ១៣នាក់ | ០៤នាក់ |
| ៨ | អនុវិទ្យាល័យ គោកឪឡោក | ០១នាក់ | ០៨នាក់ | ០១នាក់ |
| ៩ | អនុវិទ្យាល័យ បេង | ០១នាក់ | ០៧នាក់ | ០៦នាក់ |
| ១០ | អនុវិទ្យាល័យ តេជោ អូរស្រមរ | ០១នាក់ | ០៥នាក់ | ០៣នាក់ |
| ១១ | អនុវិទ្យាល័យ ថ្លាត | ០១នាក់ | ០៧នាក់ | ០៣នាក់ |
| សរុប | | ១២នាក់ | ១០០នាក់ | ៣៦នាក់ |

*តារាងទី 12 បង្ហាញពីចំនួនបុគ្គលិកតាមសាលាគោលដៅនីមួយៗ*

តាមតារាងខាងលើបានបង្ហាញពីចំនួនបុគ្គលិក ក្នុងសាលារៀននីមួយៗដែលបានផ្តល់ស្ថិតិឱ្យតាមកម្រងសំណួរឃើញថា ក្រុងសំរោង៖ អនុវិទ្យាល័យហ៊ុនសែនរួតចំប៉ី មានគណៈគ្រប់គ្រងចំនួន០២នាក់ ស្មើនឹង១៣.៣៣% នៃគណៈគ្រប់គ្រងក្នុងសាលាបានផ្តល់ទិន្នន័យ ។ អនុវិទ្យាល័យ ស៊ូរ៉ែកគុណពោធិវង្ស អនុវិទ្យាល័យ បន្សាយរាក់ អនុវិទ្យាល័យ កូនក្រៀល អនុវិទ្យាល័យ បុស្សូរ អនុវិទ្យាល័យសម្តេចតេជោហ៊ុន

សែនចុងកាល់ អនុវិទ្យាល័យជើងទៀន អនុវិទ្យាល័យ គោកឪឡោក អនុវិទ្យាល័យ បេង អនុវិទ្យាល័យ តេជោអូរស្រមរ និងអនុវិទ្យាល័យ ថ្លាត មានចំនួននាយក នាយិកាបានផ្តល់ទិន្នន័យ០១នាក់ៗ ស្មើនឹង ៦.៦៧%ដូចៗគ្នា។ តាមលទ្ធផលខាងលើនេះយើងសន្និដ្ឋានថា គណៈគ្រប់គ្រងនៃគោលដៅសុទ្ធតែក្តាប់ បានទិន្នន័យបុគ្គលិករបស់ខ្លួនទាំងអស់ ។

## ញ.ចំនួនអគារ និងចំនួនបន្ទប់តាមសាលារៀន

តារាងខាងក្រោមនេះ បង្ហាញពីចំនួនអគារ និងចំនួនបន្ទប់តាមសាលារៀនគោលដៅទាំងអស់៖

| ល.រ | ឈ្មោះសាលារៀន | ចំនួនគណៈគ្រប់គ្រងដែលបានផ្តល់ចម្លើយ | ចំនួនអគារ និងចំនួនបន្ទប់ | |
|---|---|---|---|---|
| | | | ចំនួនខ្នង | ចំនួនបន្ទប់ |
| ១ | អនុវិទ្យាល័យ ហ៊ុន សែនរួតចំប៉ី | ០២នាក់ | ០២ខ្នង | ១១បន្ទប់ |
| ២ | អនុវិទ្យាល័យ ស៊ូវ៉ែកគុណពោធិវង្ស | ០១នាក់ | ០១ខ្នង | ០៤បន្ទប់ |
| ៣ | អនុវិទ្យាល័យ បន្សាយរាក់ | ០១នាក់ | ០១ខ្នង | ០៥បន្ទប់ |
| ៤ | អនុវិទ្យាល័យ កូនក្រៀល | ០១នាក់ | ០២ខ្នង | ០៩បន្ទប់ |
| ៥ | អនុវិទ្យាល័យ បុស្បូវ | ០១នាក់ | ០១ខ្នង | ០៦បន្ទប់ |
| ៦ | អនុវិ.សម្តេចតេជោហ៊ុនសែនចុងកាល់ | ០១នាក់ | ០១ខ្នង | ១២បន្ទប់ |
| ៧ | អនុវិទ្យាល័យ ជើងទៀន | ០១នាក់ | ០១ខ្នង | ០៥បន្ទប់ |
| ៨ | អនុវិទ្យាល័យ គោកឪឡោក | ០១នាក់ | ០១ខ្នង | ០៥បន្ទប់ |
| ៩ | អនុវិទ្យាល័យ បេង | ០១នាក់ | ០១ខ្នង | ០៥បន្ទប់ |
| ១០ | អនុវិទ្យាល័យ តេជោ អូរស្រមរ | ០១នាក់ | ០១ខ្នង | ១២បន្ទប់ |
| ១១ | អនុវិទ្យាល័យ ថ្លាត | ០១នាក់ | ០១ខ្នង | ០៥បន្ទប់ |
| សរុប | | ១២នាក់ | ១៣ខ្នង | ៧៩បន្ទប់ |

*តារាងទី 13 បង្ហាញពីចំនួនអគារ និងចំនួនបន្ទប់តាមសាលារៀន*

ផ្អែកតាមតារាងខាងលើបានបង្ហាញថា គណៈគ្រប់គ្រងក្តាប់បានច្បាស់លាស់ពីចំនួនអគារ និងចំនួនបន្ទប់នៅសាលារៀនសាម៉ីទើបអាចផ្តល់ទិន្នន័យបានត្រឹមត្រូវទាំងអស់គ្នាគ្រប់សាលាគោលដៅ។

## ង.ចំនួនបង្គន់ និងចំនួនបន្ទប់តាមសាលារៀន

តារាងខាងក្រោមនេះ បង្ហាញពីចំនួនបង្គន់ និងចំនួនបន្ទប់តាមសាលារៀនគោលដៅទាំងអស់៖

| ល.រ | ឈ្មោះសាលារៀន | ចំនួននាយកតាមសាលាដែលបានផ្តល់ចម្លើយ | ចំនួនបង្គន់ និងចំនួនបន្ទប់ | |
|---|---|---|---|---|
| | | | ចំនួនខ្ទង | ចំនួនបន្ទប់ |
| ១ | អនុវិទ្យាល័យ ហ៊ុន សែនរួតចំប៉ី | ០២នាក់ | ០២ខ្ទង | ០៦បន្ទប់ |
| ២ | អនុវិទ្យាល័យ ស៊ូវ៉ែកគុណពោធិវង្ស | ០១នាក់ | ០១ខ្ទង | ០៦បន្ទប់ |
| ៣ | អនុវិទ្យាល័យ បន្សាយរាក់ | ០១នាក់ | ០២ខ្ទង | ០៩បន្ទប់ |
| ៤ | អនុវិទ្យាល័យ កូនក្រៀល | ០១នាក់ | ០២ខ្ទង | ០៦បន្ទប់ |
| ៥ | អនុវិទ្យាល័យ បុស្សរ | ០១នាក់ | ០១ខ្ទង | ០៤បន្ទប់ |
| ៦ | អនុវិ.សម្តេចតេជោហ៊ុនសែនចុងកាល់ | ០១នាក់ | ០១ខ្ទង | ០៨បន្ទប់ |
| ៧ | អនុវិទ្យាល័យ ជើងទៀន | ០១នាក់ | ០១ខ្ទង | ០២បន្ទប់ |
| ៨ | អនុវិទ្យាល័យ គោកឱឡោក | ០១នាក់ | ០១ខ្ទង | ០៥បន្ទប់ |
| ៩ | អនុវិទ្យាល័យ បេង | ០១នាក់ | ០១ខ្ទង | ០៤បន្ទប់ |
| ១០ | អនុវិទ្យាល័យ តេជោ អូរស្រមរ | ០១នាក់ | ០១ខ្ទង | ០៨បន្ទប់ |
| ១១ | អនុវិទ្យាល័យ ថ្លាត | ០១នាក់ | ០១ខ្ទង | ០៥បន្ទប់ |
| សរុប | | ១២នាក់ | ១៦ខ្ទង | ៦៩បន្ទប់ |

*តារាងទី 14 បង្ហាញពីចំនួនបង្គន់ និងចំនួនបន្ទប់តាមសាលារៀន*

ផ្អែកតាមតារាងខាងលើបង្ហាញថា គណៈគ្រប់គ្រងក្តាប់បានច្បាស់លាស់ពីចំនួនបង្គន់ និងចំនួនបន្ទប់នៅសាលារៀនសាម៉ីទើបអាចផ្តល់ទិន្នន័យបានត្រឹមត្រូវទាំងអស់គ្នាគ្រប់សាលាគោលដៅ។

### ៤.៣.២.២.ផ្នែកទី២ការគ្រប់គ្រងនិងដឹកនាំ

### ឋ.ការរៀបចំតុបតែងទីចាត់ការ និងហេដ្ឋារចនាសម្ព័ន្ធនានារបស់សាលារៀន

ក្រាបខាងក្រោមនេះបង្ហាញពីការកម្រិតនៃការរៀបចំតុបតែងទីចាត់ការ និងហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀនគោលដៅទាំងអស់៖




តារាងទី 15 ក្រាបបង្ហាញពីកម្រិតរៀបចំទីចាត់ការសាលារៀន

ផ្អែកតាមទិន្នន័យក្នុងក្រាបខាងលើបានបង្ហាញថា គ្មានគណៈគ្រប់គ្រងសាលារៀនណាមួយបានរៀបចំតុបតែងទីចាត់ការចាប់ពី១០០% ទៅលើសពី១០០% និងរៀបចំបានក្រោម៥០%ឡើយ ប៉ុន្តែមានគណៈគ្រប់គ្រងចំនួន០៥នាក់ស្មើនឹង៣៣.៣៣% បានផ្តល់ទិន្នន័យថា សាលារៀនបានរៀបចំទីចាក់ការ៨០% ទៅ៩៩%។ គណៈគ្រប់គ្រងចំនួន០៥នាក់ស្មើនឹង៣៣.៣៣% បានផ្តល់ ទិន្នន័យថា សាលារៀនបានរៀបចំទីចាក់ការ៦០% ទៅ៧៩%។ គណៈគ្រប់គ្រងចំនួន០២នាក់ស្មើនឹង១៣.៣៣% បានផ្តល់ទិន្នន័យថា សាលារៀនបានរៀបចំទីចាក់ការ៥០%-៥៩%។ ជារួមយើងសន្និដ្ឋានថា សាលារៀនគោលដៅទាំងអស់សុទ្ធតែបានរៀបចំតុបតែងទីចាត់ការ និងហេដ្ឋារចនាសម្ព័ន្ធនានាក្នុងអង្គភាពរបស់ខ្លួន។ ការរៀបចំតុបតែងទីចាត់ការមានដូចជា រចនាសម្ព័ន្ធ គណៈកម្មការគ្រប់គ្រង ក្រុមប្រឹក្សាកុមារ ឬ យុវជន ក្រុម

កាកបាតក្រហម- អន្លូចន្ទក្រហម ស្ថិតិ បុគ្គលិក សិស្ស ចក្ខុវិស័យ ពាក្យស្លោក រូបភាព តុធ្វើការតាមជំនាញ ទូដាក់ឯកសារ ក្រូណូ និងរៀបចំជារចនាសម្ព័ន្ធ គ្រប់គ្រង តាមតួនាទីនិងភារកិច្ចរបស់ នាយក លេខាធិការ គណនេយ្យករ ប្រធានក្រុមបច្ចេកទេសពិត និងសង្គម ចំពោះសិស្សមានប្រធានថ្នាក់ អនុប្រធានថ្នាក់ និងក្រុមប្រឹក្សា ទទួលខុសត្រូវតាមមុខសញ្ញារៀងៗខ្លួន។

**ឌ.ការរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនរបស់នាយក**

ក្រាបខាងក្រោមនេះបង្ហាញពី ការរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនរបស់លោកនាយក នាយិកាសាលារៀនបន្ទាប់ពីក្រុមការងារអធិការកិច្ចចុះត្រួតពិនិត្យ និងផ្តល់អនុសាសន៍ ៖




*រូបភាព 25 ក្រាបបង្ហាញពីការរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍របស់នាយក*

ផ្អែកតាមក្រាបខាងលើនេះ គណៈគ្រប់គ្រងចំនួន០២នាក់ស្មើនឹង១៣.៣៣%បានផ្តល់ទិន្នន័យថា បានរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍ជា រៀងរាល់២សប្តាហ៍ម្តង។ គណៈគ្រប់គ្រងចំនួន០៦នាក់ស្មើនឹង៤០%បានផ្តល់ទិន្នន័យថា បានរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍ជា រៀងរាល់១ខែម្តង។ គណៈគ្រប់គ្រងចំនួន០៤នាក់ស្មើនឹង២៦.៦៧%បានផ្តល់ទិន្នន័យថា មិនបានរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍ទាល់តែសោះ។ ជារួមយើងសន្និដ្ឋានថា នាយកសាលាបានយកចិត្តទុកដាក់ក្នុងការអនុវត្តតាម

អនុសាសន៍អធិការកិច្ចតាមកាលកំណត់ ដែលក្រុមការងារអធិការកិច្ចបានរកឃើញចំណុចត្រូវធ្វើការកែលម្អនៅសាលារៀន។ ហើយការអនុវត្តនេះ នាយកសាលាបានរៀបចំផែនការជាពីរផ្នែកគឺផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍រៀងរាល់២សប្តាហ៍ម្តង និងរៀងរាល់១ខែម្តង។ ចំណែកគណៈគ្រប់គ្រងប្រមាណជា ២៦.៦៧%បានផ្តល់ព័ត៌មានត្រឡប់ថា មិនបានរៀបចំផែនការចុះទាល់តែសោះពីព្រោះដោយសារបញ្ហាកូវីដ-១៩ សាលាត្រូវបានដាក់ជាមណ្ឌលចត្តាឡីស័កកម្រិតហានិភ័យខ្ពស់ តាំងពីដើមឆ្នាំសិក្សាមក។

## ៧.ការចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនរបស់នាយកសាលា

ក្រាបខាងក្រោមនេះបង្ហាញពីការកម្រិតសកម្មភាពនៃការចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនពីនាយកសាលាចំពោះគ្រូបង្រៀន៖




រូបភាព 26 ក្រាបបង្ហាញពីការការចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនរបស់នាយក

ផ្អែកតាមក្រាបខាងលើបានបង្ហាញថា គណៈគ្រប់គ្រងអនុវត្តការចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនតាមផែនការមានចំនួន ០៥នាក់ ស្មើនឹង ៣៣.៣៣% នៃសាលាគោលដៅ។ ម្យ៉ាងទៀតចម្លើយពីនាយកបានបញ្ជាក់ផ្អែកបានចុះដែរប៉ុន្តែមិនបានតាមផែនការមានចំនួន ០៣នាក់ស្មើនឹង២០%។ ដោយឡែក

គណៈគ្រប់គ្រងមួយភាគទៀតបានផ្ដល់ទិន្នន័យថា មិនបានទទួលការចុះទាល់តែសោះចំនួន០៣នាក់ ស្មើនឹង២០%។ យើងសន្និដានថា សាលារៀន៥៣.៣៣%បានគោរពតាមអនុសាសន៍ក្នុងរបាយកាណ៍អធិការកិច្ចតាមកាលកំណត់ ប៉ុន្តែមួយផ្នែកទៀតគណៈគ្រប់គ្រងស្មើនឹង២៦.៦៧% មិនបានចុះទាល់តែសោះដោយបញ្ជាក់ថា មកពីរវល់ក្នុងការងារ ម្យ៉ាងទៀតនាយកជាប់បង្រៀនសិស្សដូចគ្រូបង្រៀនដែរ រវល់តែកែលម្អផ្នែកបរិស្ថាន និងបណ្ដាលមកពីវិបត្តិកូវីដ-១៩ដោយសាលាត្រូវបានយកធ្វើជាកន្លែងចត្តាឡីស័ក។

**ឈ.កម្រិតកែលម្អបរិស្ថានសាលារៀនរបស់នាយក**

ក្រាបខាងក្រោមនេះបង្ហាញពីកម្រិតកែលម្អបរិស្ថានសាលារៀនរបស់លោកគ្រូនាយក នាយិកា ៖




រូបភាព 27 ក្រាបបង្ហាញពីកម្រិតកែលម្អបរិស្ថានសាលារៀនរបស់នាយក

ផ្អែកលើទិន្នន័យតាមក្រាបខាងលើបង្ហាញថា នាយក នាយិកា និងនាយករងបានផ្ដល់ទិន្នន័យអំពីកម្រិតកែលម្អបរិស្ថានសាលារៀន បានពី៨០ទៅ៩០%មានចំនួន០៦នាក់ស្មើនឹង៤០%។ បានពី៦០ទៅ៧០%មានចំនួន០៥នាក់ស្មើនឹង៣៣.៣៣%។ កម្រិត៥០%មានចំនួន០១នាក់ ស្មើនឹង៦.៦៧%។ ចំណែកកម្រិតបានលើសពី១០០% កម្រិតបាន១០០% កម្រិតបានតិចជាង៥០% និងមិនបានកែលម្អទាល់តែសោះគ្មានទិន្នន័យឡើយ។ លទ្ធផលនេះយើងសន្និដ្ឋានថា នាយកសាលា១២នាក់ស្មើនឹង៨០%

នៃសាលាគោលដៅបានកែលម្អបរិស្ថានសាលារៀន។ ដែលក្នុងនោះលោកនាយក នាយិកា បានរៀបចំសួនច្បារ របងសាលា ដាំកូនឈើ រៀបចំកន្លែងលាងសម្អាតដៃ បិទរូបភាព រូបមន្តក្នុងថ្នាក់ និងរៀបចំទីធ្លាហាត់កីឡាបានសមស្របទៀតផង។

## គ.កម្រិតបានធ្វើកិច្ចតែងការ និងបានយកមកឱ្យនាយក

ក្រាបខាងក្រោមនេះបង្ហាញពីកម្រិតបានធ្វើកិច្ចតែងការ និងបានយកមកឱ្យនាយក ត្រួតពិនិត្យដោយចុះហត្ថលេខា គ្រប់គ្រាន់មុននឹងបង្រៀនរបស់គ្រូបង្រៀននៅតាមសាលារៀនគោលដៅទាំងអស់៖




រូបភាព 28 ក្រាបបង្ហាញពីកម្រិតនៃការធ្វើកិច្ចតែងការរបស់គ្រូបង្រៀន

ផ្អែកតាមក្រាបខាងលើបង្ហាញថា កម្រិតបានធ្វើកិច្ចតែងការបង្រៀន និងបានយកមកឱ្យនាយក ត្រួតពិនិត្យ ចុះហត្ថលេខា មុននឹងយកទៅបង្រៀនរបស់គ្រូបង្រៀនមានដូចជា៖ បានអនុវត្តពី៨០ទៅ៩០%មានចំនួន០៤នាក់ស្មើនឹង២៦.៦៧%។ បានអនុវត្តពី៦០ទៅ៧០%បានចំនួន០៣នាក់ស្មើនឹង២០%។ បានអនុវត្តត្រឹម៥០%មានចំនួន០២នាក់ស្មើនឹង១៣.៣៣%។ បានអនុវត្តតិចជាង៥០%មានចំនួន០២នាក់ស្មើនឹង១៣.៣៣%។ មិនបានអនុវត្តទាល់តែសោះមានចំនួន០១នាក់ស្មើនឹង៦.៦៧%។ ចំណែកកម្រិតបាន១០០% គ្មានទិន្នន័យឡើយ។ តាមលទ្ធផលខាងលើនេះយើងសន្និដ្ឋានថា គ្រូបង្រៀន

ភាគច្រើន ចំនួន៦៦នាក់ ស្មើនឹង៧៧.៦៥% បានធ្វើកិច្ចតែងការបង្រៀន និងបានយកមកឱ្យនាយកត្រួតពិនិត្យ ចុះហត្ថលេខា មុននឹងយកទៅបង្រៀន។ ក្នុងលទ្ធផលនេះផងដែរក៏មានគ្រូបង្រៀនខ្លះអនុវត្តបានតិចជា៥០% និងមិនបានអនុវត្តទាល់តែសោះ ដោយបានផ្តល់ទិន្នន័យថា បណ្តាលមកពី បញ្ហាការរីករាលដាលនៃជំងឺកូវីដ១៩ ដែលបង្វែរការបង្រៀននៅក្នុងថ្នាក់ទៅបង្រៀនតាមផ្ទះ និងតាមអនឡាញ។

## ៨. កម្រិតបានតុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់របស់គ្រូបង្រៀន

ក្រាបខាងក្រោមនេះបង្ហាញពីកម្រិតបានតុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់របស់គ្រូបង្រៀន របស់គ្រូបង្រៀននៅតាមសាលារៀនគោលដៅដែលផ្តល់ទិន្នន័យដោយនាយក នាយិកា និងនាយករង៖




រូបភាព 29 កម្រិតបានតុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់របស់គ្រូបង្រៀន

ផ្អែកតាមទិន្នន័យក្នុងក្រាបខាងលើបង្ហាញថា កម្រិតបានតុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់របស់គ្រូបង្រៀនដូចជា៖ បានអនុវត្តពី៨០ទៅ៩០%មានចំនួន០២នាក់ស្មើនឹង១៣.៣៣%។ បានអនុវត្តពី៦០ទៅ៧០% មានចំនួន០៧នាក់ស្មើនឹង៤៦.៦៧%។ បានអនុវត្តត្រឹម៥០%មានចំនួន០២នាក់ស្មើនឹង១៣.៣៣%។បានអនុវត្តតិចជាង៥០%មានចំនួន០១នាក់ស្មើនឹង៦.៦៧%។ ចំណែកកម្រិត១០០% និងកម្រិតមិនបានអនុវត្តទាល់តែសោះគ្មានទិន្នន័យឡើយ។ លទ្ធផលខាងលើនេះយើងសន្និដ្ឋានថា គ្រូបង្រៀន៦៦នាក់ស្មើនឹង៧៧.៦៥% បានតុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់នៅតាមសាលារៀនគោល

ដៅ។ ប៉ុន្តែការរៀបចំតុបតែងស្ថិតនៅក្នុងកម្រិតមួយដែលដោយឡែកៗពីគ្នាចន្លោះពីអនុវត្តបានកម្រិតតិចជាង៥០%និងឡើងទៅដល់៩០%។ភាគរយកអនុវត្តខ្ពស់ជាងគេគឺ៦០%-៧០% ស្មើនឹង ៤៦.៦៧%។

**ខ. ការរៀបចំឱ្យមានសៀវភៅនានាតាមបែបបទរដ្ឋបាលគ្រូរបស់គ្រូបង្រៀន**

ក្រាបខាងក្រោមនេះបង្ហាញពីកម្រិតបានរៀបចំឱ្យមានសៀវភៅនានាតាមបែបបទរដ្ឋបាលគ្រូរបស់គ្រូបង្រៀននៅតាមសាលារៀនគោលដៅដែលផ្តល់ទិន្នន័យដោយគណៈគ្រប់គ្រងសាលារៀន ៖




រូបភាព 30 ក្រាបបង្ហាញពីកម្រិតបានរៀបចំសៀវភៅនានាតាមបែបបទរដ្ឋបាលគ្រូ

ផ្អែកតាមក្រាបខាងលើបង្ហាញ កម្រិតបានរៀបចំសៀវភៅនានាតាមបែបបទរដ្ឋបាលគ្រូមានទិន្នន័យដូចជា៖ បានអនុវត្ត១០០%ចំនួន ០១នាក់ ស្មើនឹង៦.៦៧%។ បានអនុវត្តបានអនុវត្តពី៨០ទៅ៩០%មានចំនួន០៣នាក់ស្មើនឹង២០%។ បានអនុវត្តពី៦០-៧០%បានចំនួន០៥នាក់ស្មើនឹង៣៣.៣៣%។ បានអនុវត្តត្រឹម៥០%មានចំនួន០២នាក់ស្មើនឹង១៣.៣៣%។ បានអនុវត្តតិចជាង៥០គ្មានទិន្នន័យ។ និងមិនបានអនុវត្តទាល់តែសោះមានចំនួន០១នាក់ស្មើនឹង៦.៦៧%។ លទ្ធផលខាងលើនេះអ្នកស្រាវជ្រាវអាចសន្និដ្ឋានបានថា គណៈគ្រប់គ្រងភាគច្រើនបាន១១នាក់ ស្មើនឹង៧៣.៣៣% បានគាំទ្រថាគ្រូបង្រៀនបានរៀបចំសៀវភៅនានាតាមបែបបទរដ្ឋបាលគ្រូដូចជា សៀវភៅពិន្ទុសិស្ស បញ្ជីហៅឈ្មោះ សេវាប្រចាំថ្ងៃ

គ្រូនិងសិស្ស សៀវភៅសម្រង់អត្តបទ សៀវភៅអវត្តមានថ្នាក់រៀនសិស្ស សៀវភៅតាមដាន សៀវភៅសិក្ខាគារិក សៀវភៅអនុសាសន៍អធិការកិច្ច សៀវភៅប្រជុំ កិច្ចតែការបង្រៀន សៀវភៅទំនាក់ទំនងអាណាព្យាបាលសិស្ស សៀវភៅរបាយការណ៍បរិបទកូវីដ-១៩ ។ ដោយឡែកលទ្ធផលចំនួន០១នាក់ ស្មើនឹង ៦.៦៧%បង្ហាញថាមិនបានអនុវត្តទាន់តែសោះដោយលើកជាយោបល់ថា គ្រូបង្រៀនតាមអនឡាញ។ ករណីនេះយើងសន្និដ្ឋានថានាយកសាលាផ្តោតលើតែឆ្នាំចុងក្រោយ មិនបានគិតឆ្នាំអនុវត្តទូទៅរយៈពេលគ្រូអនុវត្តបន្ទាប់ពីក្រុមអធិការកិច្ចបានចុះអធិការរួចរហូតមកដល់ពេលបច្ចុប្បន្ននេះ។

### ឆ.គុណភាពនិងលទ្ធផលសិក្សារបស់សិស្សកើនជាបន្តបន្ទាប់ មួយឆ្នាំៗ

ក្រាបខាងក្រោមនេះបង្ហាញពីគុណភាព និងលទ្ធផលសិក្សារបស់សិស្សមានការកើនឡើងជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ នៅតាមសាលារៀនគោលដៅ ៖




*រូបភាព 31 ក្រាបបង្ហាញពីគុណភាព និងលទ្ធផលសិក្សារបស់សិស្សកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ*

ផ្អែកតាមក្រាបខាងលើបង្ហាញថា សាលារៀនភាគច្រើន១០សាលាស្មើនឹង ៩០.៩១%។ ទិន្នន័យពីលទ្ធផលសិក្សារបស់សិស្សមានការកើនឡើងពី ១ដល់៥% មានចំនួន០៣សាលាស្មើនឹង២៧.២៧%។

កើនពី៦ដល់១០%ជារៀងរាល់ឆ្នាំមានចំនួន០៣សាលាស្មើនឹង៣៦.៣៦%។ កើនពី១១ដល់១៥%ជារៀងរាល់ឆ្នាំ ០២សាលា ស្មើនឹង ១៨.១៨%។ កើនពី១៦ដល់២០%ជារៀងរាល់ឆ្នាំមានចំនួន០១សាលាស្មើនឹង៩.០៩%។ កើនលើសពី២១%ជារៀងរាល់ឆ្នាំ គ្មានទិន្នន័យ។ ចំណែកសាលាដែលលទ្ធផលសិក្សារបស់សិស្សមិនកើនទាល់តែសោះមានចំនួន០២សាលា ស្មើនឹង១៨.១៨%។ ករណីនេះយើងសន្និដ្ឋានថា គុណភាព និងលទ្ធផលសិក្សារបស់សិស្សមានទិន្នន័យខ្ពស់ជាងគេគឺ ចំណុចកើនពី៦ដល់១០%ជារៀងរាល់ឆ្នាំ ស្មើនឹង៣៦.៣៦%។

### ន.កម្រិតការចូលរួមពីសហគមន៍ជាមួយសាលារៀន

ក្រាបខាងក្រោមនេះបង្ហាញពីកម្រិតការចូលរួមពីសហគមន៍ជាមួយសាលារៀនគោលដៅ ៖




រូបភាព 32 កម្រិតការចូលរួមពីសហគមន៍ជាមួយសាលារៀន

ផ្អែកតាមទិន្នន័យក្នុងក្រាបខាងលើបង្ហាញថា គ្មានគណៈគ្រប់គ្រងរូបណាម្នាក់បានផ្តល់ទិន្នន័យអំពីការចូលរួមរបស់សហគមន៍ស្ថិតក្នុងកម្រិតល្អណាស់ កម្រិតក្រោមមធ្យម និងកម្រិតខ្សោយឡើយ ប៉ុន្តែមានគណៈគ្រប់គ្រងចំនួន០១នាក់ស្មើនឹង៦.៦៧% បានផ្តល់ព័ត៌មានត្រឡប់ស្ថិតក្នុង កម្រិតល្អ។ ហើយ

កម្រិតល្អបង្គួរ មានចំនួន០៦នាក់ស្មើនឹង៤០% ។ កម្រិតមធ្យមមានចំនួន ០៥នាក់ស្មើនឹង ៣៣.៣៣%។ តាមលទ្ធផលខាងលើនេះ យើងសន្និដ្ឋានថា គណៈគ្រប់គ្រងចំនួន១២នាក់ស្មើនឹង៨០%បានផ្តល់ទិន្នន័យពីកម្រិតចូលរួមរបស់សហគមន៍ជាវិជ្ជមាន ។ ក្នុងនោះ កម្រិតល្អ និងល្អបង្គួរលោកបង្ហាញថា សាលារៀនបានប្រជុំជាមួយសហគមន៍ បង្ហាញលទ្ធផលការអភិវឌ្ឍន៍សាលារៀន លទ្ធផលសិក្សារបស់សិស្ស ចំណូល-ចំណាយថវិកាក្នុងសាលា និងកម្មវិធីនានា។ ករណីនេះធ្វើឱ្យសហគមន៍បានចូលរួមមកវិញនូវកម្លាំងពលកម្មធ្វើរោងដាក់កង់ ថវិកាកសាងសាលា និងសម្ភារនានា ។

## ២.ការអភិវឌ្ឍរីកចម្រើនសាលារៀនបន្ទាប់ពីចុះធ្វើអធិការកិច្ច

ក្រាបខាងក្រោមនេះបង្ហាញពីកម្រិតនៃការអភិវឌ្ឍរីកចម្រើនរបស់សាលារៀនបន្ទាប់ពីក្រុមការងារកិច្ចបានចុះធ្វើអធិការតាមសាលាគោលដៅទាំងអស់ ៖




*រូបភាព 33 ក្រាបបង្ហាញពីកម្រិតរីកចម្រើនរបស់សាលារៀនបន្ទាប់ពីក្រុមការងារអធិការកិច្ចចុះ*

ផ្អែកតាមក្រាបខាងលើបង្ហាញថា កម្រិតនៃការអភិវឌ្ឍរីកចម្រើនរបស់សាលារៀនបន្ទាប់ពីក្រុមការងារកិច្ចបានចុះអធិការតាមសាលាគោលដៅរួចមក គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យមានដូចជា៖ បានអនុវត្តពី៨០-៩៩%មានចំនួន០២នាក់ស្មើនឹង១៣.៣៣%។ បានអនុវត្តី៦០- ៧៩%មានចំនួន០៨នាក់

ស្មើនឹង៥៣.៣៣%។ បានអនុវត្តពី៥០-ទៅ៦០%មានចំនួន០១នាក់ស្មើនឹង៦.៦៧%។ បានអនុវត្តក្រោម៥០%មានចំនួន០១នាក់ស្មើនឹង៦.៦៧%។ ចំណែកកម្រិតបានអនុវត្ត ១០០% និងកម្រិតមិនបានអនុវត្តទាល់តែសោះ គ្មានទិន្នន័យឡើយ។ លទ្ធផលខាងលើនេះអ្នកស្រាវជ្រាវអាចសន្និដ្ឋានបានថា កម្រិតនៃការអភិវឌ្ឍរីកចម្រើនរបស់សាលារៀន បន្ទាប់ពីក្រុមការងារកិច្ចបានចុះធ្វើអធិការសាលាគោលដៅរួចមកសុទ្ធតែមានដំណើរការអភិវឌ្ឍចាប់ពីក្រោម៥០% ទៅ៨០ដល់៩៩% ហើយភាគរយដែលមានគណៈគ្រប់គ្រង ផ្តល់ទិន្នន័យច្រើនជាងគេគឺ៦០-៧៩%មានរហូតដល់៥៣,៣៣%។ ករណីនេះគណៈគ្រប់គ្រងបញ្ជាក់ពីចំណុចគោលដែលបានអភិវឌ្ឍរួមមាន ផ្នែកគ្រប់គ្រងវត្តមាន ផ្នែកកិច្ចតែងការបង្រៀន ផ្នែកបរិស្ថាន ការបង្រៀននិងរៀនប្រកដោយសិទ្ធភាព ផ្នែកការសិក្សារបស់សិស្ស ផ្នែកគ្រប់គ្រង , ផ្នែកចូលរួមរបស់សហគមន៍ ផ្នែកអនាម័យ ផ្នែកក្រុមប្រឹក្សាកុមារ ផ្នែកតុបតែងទីចាត់ការ និងថ្នាក់រៀនជាដើម។

### ផ.ការវាយតម្លៃចុងក្រោយជាប្រចាំខែនៃដំណើរការសិក្សារបស់សាលារៀន

ក្រាបខាងក្រោមបង្ហាញពី កម្រិតនៃការវាយតម្លៃចុងក្រោយ (របាយការណស្វ័យវាយតម្លៃដំណើរការសិក្សាគន្លងជីវិតថ្មី)តាមសាលាគោលដៅទាំងអស់ ដែលគណៈគ្រប់គ្រងបានផ្តល់ទិន្នន័យ៖




*រូបភាព 34 កម្រិតនៃការវាយតម្លៃចុងក្រោយប្រចាំខែនៃដំណើរការសិក្សារបស់សាលារៀន*

ផ្អែកតាមក្រាបខាងលើបង្ហាញថា កម្រិតនៃការវាយតម្លៃចុងក្រោយជាប្រចាំខែនៃ ដំណើរការសិក្សារបស់សាលារៀនក្នុងពេលបច្ចុប្បន្ន (របាយការណ៍ស្វ័យវាយតម្លៃដំណើរការសិក្សាគន្លងជីវិតថ្មី)តាមសាលាគោលដៅទាំងអស់ ដែលគណៈគ្រប់គ្រងបានផ្តល់ព័ត៌មានត្រឡប់ កម្រិតមធ្យម(៣.០០-៣.៩៩) មានចំនួន០៦នាក់ស្មើនឹង៤០%,កម្រិតបង្គួរ(៤.០០-៤.៩៩) ។ ចំណែកកម្រិតទាប(១.០០-១.៩៩), កម្រិតក្រោមមធ្យម(២.០០-២.៩៩),កម្រិតល្អ(៥.០០)មិនបានទទួលបានទិន្នន័យ។ លទ្ធផលនេះយើងសន្និដ្ឋានថា សាលារៀនមានដំណើរការអភិវឌ្ឍពីរកម្រិតធំៗ ដែលមានកម្រិតមធ្យម និងកម្រិតបង្គួរ ចំនួន៤០%ដូចគ្នា។ ជារួម៨០%សាលារៀនមានការអភិវឌ្ឍពីកម្រិតមធ្យមរហូតដល់កម្រិតបង្គួរ។

**៣.ការទទួលចំណាត់ថ្នាក់ ថ្នាក់សាលារៀនល្អ ,នាយកល្អ ,ទទួលប័ណ្ណសរសើរ**

ក្រាបខាងក្រោមនេះបង្ហាញពី កម្រិតទទួលចំណាត់ថ្នាក់ សាលារៀនល្អ ,នាយកល្អ ,ទទួលប័ណ្ណសរសើរពីថ្នាក់ដឹកនាំរបស់សាលាគោលដៅទាំងអស់ ដែលគណៈគ្រប់គ្រងបានផ្តល់ទិន្នន័យ៖




*រូបភាព 35 ក្រាបបង្ហាញពីការទទួលចំណាត់ថ្នាក់ សាលារៀនល្អ នាយកល្អ និងប័ណ្ណសរសើរ*

ផ្អែកតាមក្រាបខាងលើបង្ហាញថា គណៈគ្រប់គ្រងទទួលបានមេដាយសំរិទ្ធិមានចំនួន ០១នាក់ ស្មើនឹង ៦.៦៧% ។ ទទួលប័ណ្ណសរសើរមានចំនួន ០៣នាក់ស្មើនឹង ២០% ។ មិនធ្លាប់ទទួលបាន រួមទាំងប័ណ្ណសរសើរ ឬមេដាយការងារមានចំនួន ០៨នាក់ ស្មើនឹង៥៣.៣៣%។ លទ្ធផលខាងលើយើងនិង្ឋានថា គណៈគ្រប់គ្រងភាគតិចទទួលបានមេដាយ និងប័ណ្ណសរសើរការងារ ប៉ុន្តែបែរជាមានគណៈគ្រប់គ្រងភាគច្រើនទៅវិញដែលមិនធ្លាប់ទទួលបានមេដាយ ឬប័ណ្ណសរសើរលើការងារ។

### ៤.៣.២.៣.ផ្នែកទី៣ បញ្ហាប្រឈមក្នុងការអនុវត្តរបាយការណ៍អធិការកិច្ច

### ក.ការផ្ញើរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់ក្រុមអធិការកិច្ច

ក្រាបខាងក្រោមនេះបង្ហាញពី ការផ្ញើរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់ក្រុមអធិការកិច្ចបន្ទាប់ពីបញ្ចប់ការងាររបស់ខ្លួនដល់សាលារៀន តាមសាលាគោលដៅទាំងអស់ ៖




*រូបភាព 36 ក្រាបបង្ហាញពីការផ្ញើរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់ក្រុមអធិការកិច្ច*

ផ្អែកតាមក្រាបខាងលើបង្ហាញថា ការផ្ញើរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់ក្រុមអធិការកិច្ចបន្ទាប់ពីបញ្ចប់ការងាររបស់ខ្លួនដល់សាលារៀន តាមសាលាគោលដៅទាំងអស់ ដែលលោកនាយក នាយិកា បានផ្តល់ទិន្នន័យមានដូចជា ចំណុចបានផ្ញើដល់ក្រោយ២សប្តាហ៍ ទទួលបានទិន្នន័យចំនួន០៨នាក់ស្មើនឹង៥៣.៣៣%, បានផ្ញើដល់ក្រោយ៣សប្តាហ៍ ទទួលបានទិន្នន័យចំនួន០២នាក់ស្មើនឹង១៣.៣៣%, បានផ្ញើដល់ក្រោយ៤សប្តាហ៍ ទទួលបានទិន្នន័យចំនួន០១នាក់ស្មើនឹង៦.៦៧%, បានផ្ញើដល់ក្រោយ៥សប្តាហ៍ ទទួលបានទិន្នន័យចំនួន០១នាក់ស្មើនឹង៦.៦៧%,។ ចំណែក ចំណុច មិនបានទទួលទាល់តែសោះ គ្មានទិន្នន័យឡើយ។ លទ្ធផលខាងលើនេះយើងសន្និដ្ឋានថា លោកនាយក នាយិកាបានផ្តល់ទិន្នន័យពីសាលារៀនគោលដៅនីមួយៗគឺស្ថិតនូវជាល្បាយតាមចំណុចចំនួន០៤ក្នុងចំណោម ០៥។ ចំណុចដែលមានទិន្នន័យខ្ពស់ជាងគឺ បានផ្ញើដល់ក្រោយ២សប្តាហ៍មានរហូតដល់៥៣.៣៣% ចំណែកចំណុចជម្រើស បានផ្ញើដល់ក្រោយ៤សប្តាហ៍ និងបានផ្ញើដល់ក្រោយ៥សប្តាហ៍មានទិន្នន័យស្មើគ្នាគឺ៦.៦៧% ។ ករណីនេះយើងយល់ថា អាចមកពីក្រុមការងារអធិការកិច្ចផ្ញើរបាយការណ៍មានការយឺតយ៉ាវ ឬការិយាល័យក្រុង/ស្រុក ផ្ញើបន្តមានការយឺតយ៉ាវដោយប្រការផ្សេងៗ។ ទោះជាយ៉ាងនេះក្តីសាលាភាគច្រើនបានទទួលរបាយការណ៍អធិការកិច្ចតាមកាលកំណត់ទាំងអស់ លើកលែងតែសាលាមួយប៉ុណ្ណោះដែលផ្តល់ព័ត៌មានថា មិនបានទទួល ប៉ុន្តែក្នុងចម្លើយនៃកម្រងសំណួរផ្សេងទៀតដែលមានខ្លឹមសារថា (តើការបញ្ជូនរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់ការិ.អធិការកិច្ច តាមរយៈការិ.អយកក្រុងស្រុក ហើយការិ.អយកក្រុងស្រុកបានបញ្ជូនបន្តដល់សាលារៀនទាន់ពេលវេលាដែរឬទេ?)លោកបានផ្តល់ព័ត៌មានត្រឡប់ថា បានផ្ញើដល់ក្រោយ២សប្តាហ៍ ទៅវិញ។ ចំណុចនេះយើងយល់ថា អាចមកពីសាលាទុកដាក់មិនត្រឹមត្រូវធ្វើឱ្យបាត់បង់ ដូចសាលាចំនួនពីរផ្សេងទៀតដែលទុករបាយការណ៍អធិការកិច្ចតាមកាលកំណត់មិនបានត្រឹមត្រូវធ្វើឱ្យបាត់ដែរ ។

### ម.បញ្ហាប្រឈមខ្លាំងរាំងស្ទះដល់ការអនុវត្តរបាយការណ៍អធិការកិច្ច

តារាងខាងក្រោមនេះបង្ហាញពី បញ្ហាប្រឈមខ្លាំងរាំងស្ទះដល់ការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់(អនុសាសន៍) ដែលក្រុមការងារអធិការកិច្ចបានដាក់ឱ្យកែលម្អទាក់ទងនឹង

ការងារគ្រប់គ្រងនិងដឹកនាំ នៅតាមសាលាគោលដៅទាំងអស់ ដែលលោកនាយក នាយិកាបានផ្តល់ទិន្នន័យៈ

| ល.រ | បញ្ហាប្រឈម/ងាយស្រួល | ចំនួននាយកផ្តល់ចម្លើយ |
|---|---|---|
| ១ | គ្មានភ្លើងអគ្គីសនីសម្រាប់ប្រើប្រាស់កុំព្យូទ័រ | ០១នាក់ |
| ២ | ទីចាត់ការនៅជាប់បន្ទប់រៀន ហើយមានលិចទឹកនៅពេលមេឃភ្លៀងម្តងៗ បន្ទប់រៀនក៏លិចធ្វើឱ្យខូចខាតសម្ភារៈមួយចំនួន ខ្វះឃ្លាំងឬបន្ទប់ដាក់សម្ភារៈ | ០១នាក់ |
| ៣ | ការរៀន និងបង្រៀនតាមអនឡាញ ព្រមទាំងការបញ្ជូនរបាយការណ៍មានការលំបាក សេវាអិនធឺណែតដែលបង្កឱ្យមានការរាំងស្ទះជាកត្តាប្រឈមខ្លាំង | ០១នាក់ |
| ៤ | សិស្សបោះបង់ច្រើន បញ្ហាវិន័យរបស់សិស្ស | ០១នាក់ |
| ៥ | គ្មានបញ្ហាប្រឈម(ងាយស្រួល) | ០៨នាក់ |
| **សរុប** | | **១២នាក់** |

*តារាងទី 16 បញ្ហាប្រឈមខ្លាំងរាំងស្ទះដល់ការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់*

ផ្អែកតាមទិន្នន័យក្នុងតារាងខាងលើបង្ហាញថា បញ្ហាប្រឈមខ្លាំងរាំងស្ទះដល់ការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់(អនុសាសន៍)ដែលក្រុមការងារអធិការកិច្ចបានដាក់ឱ្យកែលម្អទាក់ទងនឹងការងារគ្រប់គ្រងនិងដឹកនាំនៅសាលារៀនមានដូចជា៖ សាលាគ្មានភ្លើងអគ្គីសនីសម្រាប់ប្រើប្រាស់កុំព្យូទ័រទទួលបានទិន្នន័យចំនួន០១នាក់នៃ១៥នាក់ ស្មើនឹង ៦.៦៧%។ ទីចាត់ការនៅជាប់បន្ទប់រៀន ហើយមានលិចទឹកនៅពេលមេឃភ្លៀងម្តងៗ បន្ទប់រៀនក៏លិចធ្វើឱ្យខូចខាតសម្ភារៈមួយចំនួន ខ្វះឃ្លាំងឬបន្ទប់ដាក់សម្ភារៈ ខ្វះថវិកា ទទួលបានទិន្នន័យចំនួន០១នាក់ ស្មើនឹង ៦.៦៧%។ ការរៀននិងបង្រៀនតាមអនឡាញ ព្រមទាំងការបញ្ជូនរបាយការណ៍មានការលំបាក ផ្នែកសេវាអិនធឺណែតដែលបង្កឱ្យមានការរាំងស្ទះជាកត្តាប្រឈមខ្លាំង ទទួលបានទិន្នន័យចំនួន០១នាក់ ស្មើនឹង ៦.៦៧%។ សិស្សបោះបង់

ច្រើន បញ្ហាវិន័យរបស់សិស្ស ទទួលបានទិន្នន័យ ចំនួន០១នាក់ ស្មើនឹង ៦.៦៧%។ គ្មានបញ្ហាប្រឈម (ងាយស្រួល) ទទួលបានទិន្នន័យចំនួន០៨នាក់ស្មើនឹង៥៣.៣៣%។ លទ្ធផលខាងលើយើងសន្និដ្ឋានថា សាលារៀនភាគច្រើន៥៣.៣៣% អាចអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់ បានដោយងាយស្រួលពុំមានការលំបាកដែលជាបញ្ហាប្រឈមខ្លាំងនៅសាលារៀនឡើយ។ ដោយឡែកសាលារៀនចំនួន ០៤ ស្មើនឹង ៣៦.៣៦% មានបញ្ហាប្រឈមក្នុងការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់ដោយលើកថា សាលាជួបបញ្ហាគ្មានភ្លើងអគ្គីសនីសម្រាប់ប្រើប្រាស់កុំព្យូទ័រ សាលារៀនមានទីចាត់ការ(បន្ទប់រៀន)នៅជាប់បន្ទប់រៀន មានលិចទឹកនៅពេលមេឃភ្លៀងម្តងៗ បន្ទប់រៀនក៏លិចធ្វើឱ្យខូចខាតសម្ភារៈមួយចំនួន ខ្វះឃ្លាំងឬបន្ទប់ដាក់សម្ភារៈ ខ្វះថវិកា។

### ៤.៣.២.៤.ផ្នែកទី៤.ការយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន

### ឃ.ការអភិវឌ្ឍការងារគ្រប់គ្រងនិងដឹកនាំនៅសាលារៀន

ក្រាបខាងក្រោមនេះបង្ហាញពី កម្រិតអភិវឌ្ឍការងារគ្រប់គ្រង និងដឹកនាំនៅសាលារៀន៖




*រូបភាព 37 ក្រាបបង្ហាញពីការអភិវឌ្ឍ ការងាររដ្ឋបាលគ្រូ តាមរយៈរបាយការណ៍អធិការកិច្ច*

ផ្អែកតាមក្រាបខាងលើបង្ហាញថា នាយកសាលាដែលបានផ្តល់ទិន្នន័យពី ការអភិវឌ្ឍខ្លាំងណាស់ របស់សាលារៀនមានចំនួន០១នាក់ស្មើនឹង៦.៦៧%។ នាយកសាលាដែលបានផ្តល់ទិន្នន័យពី ការអភិវឌ្ឍ ល្អ មានចំនួន១១នាក់ស្មើនឹង៧៣.៣៣%។ ចំណែកកម្រិត អភិវឌ្ឍខ្លះ មិនអភិវឌ្ឍខ្លះ និង ចំណុចគ្មាន ជួយដល់ការអភិវឌ្ឍទេ យើងមិនបានទទួលទិន្នន័យឡើយ។ លទ្ធផលខាងលើយើងសន្និដ្ឋានថា សាលារៀនដែលឆ្លងកាត់ការចុះអធិការកិច្ចសុទ្ធតែមានការអភិវឌ្ឍល្អទាំងអស់ ដោយសាលាបានលើកឡើងថា របាយការណ៍អធិការកិច្ចតាមកាលកំណត់ជួយដល់លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សមានការរីកចម្រើន ការបង្រៀននិងរៀន (គ្រូខំបង្រៀន) ។ ធ្វើឱ្យសាលារៀនមានបរិស្ថានស្អាត ទីចាត់ការនិងបន្ទប់រៀនស្អាត បានមួយចំនួនធំ គ្រូបង្រៀនមានការរៀបចំកិច្ចតែងការបង្រៀន ការងារគ្រប់គ្រងរបស់នាយកល្អ ធ្វើឱ្យលោកគ្រូអ្នកគ្រូខិតខំប្រឹងប្រែងពង្រឹងសមត្ថភាពចំណេះដឹងរបស់ខ្លួនបានកាន់តែប្រសើរឡើង។

** វ.ភាគរយការអនុវត្តការងាររបស់នាយកនៅតាមសាលារៀនតាមអនុសាសន៍**

ក្រាបខាងក្រោមបង្ហាញពី ភាគរយការអនុវត្តការងាររបស់នាយកនៅសាលារៀនតាមអនុសាសន៍អធិការកិច្ចតាមរយៈរបាយការណ៍អធិការកិច្ចតាមកាលកំណត់៖




*រូបភាព 38 ក្រាបបង្ហាញពីភាគរយការអនុវត្តការងាររបស់នាយកនៅសាលារៀន*

ផ្អែកតាមក្រាបខាងលើបង្ហាញថា ភាគរយការអនុវត្តការងាររបស់នាយកនៅតាមសាលារៀនតាមអនុសាសន៍អធិការកិច្ចមានដូចជា កម្រិតភាគរយអនុវត្តបាន៩០% មានចំនួន ០៣នាក់ស្មើនឹង២០% , អនុវត្តបាន៨០% មានចំនួន ០៥នាក់ស្មើនឹង៣៣.៣៣%,អនុវត្តបាន៧០% មានចំនួន ០១នាក់ស្មើនឹង ៦.៦៧%, អនុវត្តបាន៦០% មានចំនួន ០១នាក់ស្មើនឹង៦.៦៧%,អនុវត្តបាន៥០% មានចំនួន ០២នាក់ស្មើនឹង១៣.៣៣។ ចំណែកកម្រិតអនុវត្តបាន១០០% ,ក្រោម៥០% និងមិនបានអនុវត្តទាល់តែសោះយើងមិនបានទទួលទិន្នន័យឡើយ។ លទ្ធផលនេះយើងចសន្និដ្ឋានថា ភាគរយការអនុវត្តការងារគ្រប់គ្រងរបស់នាយក នាយិកានៅសាលារៀនមានចាប់ពី៥០%រហូតដល់៩០% ដែលក្នុងនោះភាគរយនៃការអនុវត្តការងារដែលខ្ពស់ជាងគេគឺ កម្រិត៨០% មានចំនួន០៥នាក់ ស្មើនឹង៣៣.៣៣%។

**ឍ.ការវិភាគ កម្រិតការអភិវឌ្ឍរបស់សាលារៀន**

ក្រាបខាងក្រោមនេះបង្ហាញពី កម្រិតការអភិវឌ្ឍរបស់សាលារៀនដែលផ្តល់ដោយនាយក នាយិកា នាយករងនៃសាលាគោលដៅទាំងអស់៖




*រូបភាព 39 ក្រាបបង្ហាញពីកម្រិតការអភិវឌ្ឍរបស់សាលារៀន*

ផ្អែកតាមក្រាបខាងលើបង្ហាញថា ទិន្នន័យដែលលោកនាយក នាយិកា បានផ្តល់ពីតាមសាលាគោលដៅទាំងអស់ក្នុងចំណោមកម្រិតទាំងបួនមានតែពីរកម្រិតប៉ុណ្ណោះដែលមានទិន្នន័យគឺ កម្រិតល្អ មានចំនួន ០៩នាក់ ស្មើនឹង ៦០% ,កម្រិតពេញចិត្តមានចំនួន០៣នាក់ មានចំនួន ២០% ។ ចំណែកកម្រិតល្អឥតខ្ចោះ និងកម្រិតមិនពេញចិត្តអ្នកស្រាវជ្រាវមិនបានទទួលទិន្នន័យឡើយ។ លទ្ធផលខាងលើនេះ យើងសន្និដ្ឋានថា សាលារៀនមានការអភិវឌ្ឍ ធ្វើឱ្យនាយក នាយិកាពេញចិត្តបំពេញការងារជាបន្ត ។

## ៤.៤.ការសំយោគទិន្នន័យកម្រងសំណួរ

### ៤.៤.១.កម្រិតវាយតម្លៃលើចំណុចគោលនៃអនុសាសន៍អធិការកិច្ច

ដើម្បីជានាថា សាលារៀនមានប្រសិទ្ធភាព ឬគ្មានប្រសិទ្ធភាពក្នុងការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់ យើងធ្វើការវិភាពឆ្លងកម្រងសំណួរផ្ទៀងផ្ទាត់រវាងនាយកសាលា និងគ្រូបង្រៀនទៅតាមចំណុចគោលសំខាន់ៗទាំង០៧នៃអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់ដែលមានជាបន្តបន្ទាប់ដូចជា៖

#### ៤.៣.៣.១.ការរៀបចំទីចាត់ការ

ក្រាបខាងក្រោមនេះបង្ហាញពីការផ្ទៀងផ្ទាត់គ្នារវាងការផ្តល់ទិន្នន័យពីគ្រូបង្រៀន និងនាយកសាលាដើម្បីរកឱ្យឃើញពីចំណុចប្រសិទ្ធភាពនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់៖




*តារាងទី 17 ក្រាបបង្ហាញពីកម្រិតរៀបចំទីចាត់ការសាលារៀន*

ផ្អែកលើទិន្នន័យក្នុងក្រាបខាងលើបង្ហាញថា កម្រិតរៀបចំតុបតែងទីចាត់ការលើសពី១០០% អ្នកស្រាវជ្រាវមិនបានទទួលទិន្នន័យពីគ្រូបង្រៀន និងនាយកសាលាឡើយ។ កម្រិតរៀបចំតុបតែងទីចាក់ការ ១០០% យើងបានទទួលទិន្នន័យពីគ្រូបង្រៀន មានចំនួន០១នាក់ស្មើនឹង១.១៨% ចំណែកពីនាយកសាលាយើងមិនបានទទួលទិន្នន័យឡើយ។ កម្រិតរៀបចំទីចាក់ការពី៨០-៩៩%យើងបានទទួលទិន្នន័យពីគ្រូបង្រៀនមានចំនួន១៨នាក់ស្មើនឹង២១.១៨% ពីនាយក នាយិកាសាលាមានចំនួន០៥នាក់ស្មើនឹង ៣៣.៣៣%។ បើតាមទិន្នន័យប្រៀបធៀបភាគរយជាមធ្យមឃើញថា២៧.២៦%។ កម្រិតរៀបចំទីចាក់ការពី៦០-៧៩% យើងបានទទួលទិន្នន័យពីគ្រូបង្រៀនមានចំនួន២៧នាក់ស្មើនឹង៣១.៧៦% ពីនាយកនាយិកាសាលា មានចំនួន០៥នាក់ស្មើនឹង៣៣.៣៣%។ បើតាមទិន្នន័យប្រៀបធៀបភាគរយជាមធ្យមឃើញថា ៣២.៥៥%។ កម្រិតរៀបចំទីចាក់ការពី៥០-៥៩% យើងបានទទួលទិន្នន័យពីគ្រូបង្រៀន មានចំនួន១៨នាក់ស្មើនឹង២១.១៨%ពីនាយក នាយិកាសាលាមានចំនួន០២នាក់ស្មើនឹង១៣.៣៣%។ បើតាមទិន្នន័យប្រៀបធៀបភាគរយជាមធ្យមឃើញថា ១៧.២៦%។ កម្រិតរៀបចំទីចាក់ការក្រោម ៥០% យើងបានទទួលទិន្នន័យពីគ្រូបង្រៀន មានចំនួន០២នាក់ស្មើនឹង២.៣៥% ចំណែកផ្នែកនាយក នាយិកាសាលា យើងមិនបានទទួលទិន្នន័យឡើយ។ តាមរយៈលទ្ធផលខាងលើនេះ យើងសន្និដ្ឋានថា តម្លៃសរុបមធ្យមភាគជាមធ្យមនៃកម្រិតអនុវត្តបានគឺ៧៧.០៧%។ ជារួមយើងយល់ថា សាលារៀនគោលដៅទាំងអស់សុទ្ធតែបានរៀបចំតុបតែងទីចាត់ការ និងហេដ្ឋារចនាសម្ព័ន្ធនានាក្នុងអង្គភាពរបស់ខ្លួន។ ការរៀបចំតុបតែងមានដូចជា រចនាសម្ព័ន្ធ គណៈកម្មការគ្រប់គ្រង ក្រុមប្រឹក្សាកុមារឬ យុវជន ក្រុមកាកបាតក្រហម-អឌ្ឍចន្ទក្រហម ស្ថិតិ បុគ្គលិក សិស្ស ចក្ខុវិស័យ ពាក្យស្លោក រូបភាព តុធ្វើការតាមជំនាញ ទូដាក់ឯកសារ ក្រូណូ និងរៀបចំជារចនាសម្ព័ន្ធ គ្រប់គ្រង តាមតួនាទីនិងភារកិច្ចរបស់ នាយក លេខាធិការ គណនេយ្យករ ប្រធានក្រុមបច្ចេកទេសពិត និងសង្គម ចំពោះសិស្សមានប្រធានថ្នាក់ អនុប្រធានថ្នាក់ និងក្រុមប្រឹក្សា ទទួលខុសត្រូវតាមមុខសញ្ញា រៀងៗខ្លួនក្នុងសាលារៀន។

**៤.៣.៣.២.ការធ្វើផែនការ និងការចុះអធិការកិច្ចថ្នាក់រៀន**

**ក.ការរៀបចំផែនការ**

ក្រាបខាងក្រោមនេះបង្ហាញពីការរៀបចំផែនការរបស់នាយកសាលាដើម្បីចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀននៅតាមសាលារៀនគោលដៅដែលផ្តល់ទិន្នន័យដោយគ្រូបង្រៀន និងនាយកសាលា ៖




*រូបភាព 40 ក្រាបបង្ហាញពីការរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍របស់នាយក*

ផ្អែកលើទិន្នន័យក្នុងក្រាបខាងលើបង្ហាញថា គ្រូបង្រៀនចំនួន០៣នាក់ស្មើនឹង៣.៥៣%បានផ្តល់ទិន្នន័យថា នាយកសាលាបានរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍ជារៀងរាល់សប្តាហ៍។ ចំណែកផ្នែកនាយកវិញ យើងមិនបានទទួលទិន្នន័យត្រឡប់វិញឡើយ។ បើតាមទិន្នន័យប្រៀបធៀបភាគរយជាមធ្យមឃើញថា ១.៧៧ %។ គ្រូបង្រៀនចំនួន០២នាក់ស្មើនឹង២.៣៥%បានផ្តល់ទិន្នន័យថា នាយកសាលាបានរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍រៀងរាល់២សប្តាហ៍ម្តង។ ចំណែកគណៈគ្រប់គ្រងចំនួន០២នាក់ស្មើនឹង១៣.៣៣%ក៏បានផ្តល់ទិន្នន័យដូចគ្នានេះដែរ។ បើតាមទិន្នន័យប្រៀបធៀបភាគរយជាមធ្យមឃើញថា៧.៨៤%។ គ្រូបង្រៀនចំនួន៥០នាក់ស្មើនឹង៥៨.៨២%បានផ្តល់ទិន្នន័យថា នាយកសាលាបានរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍ជា ០១ខែម្តង។ ចំណែកនាយកសាលាចំនួន០៦នាក់ស្មើនឹង៤០% បានផ្តល់ទិន្នន័យថា ក្នុងផែនការនេះដូចគ្នាដែរ។ បើតាមទិន្នន័យប្រៀបធៀបភាគរយជាមធ្យមឃើញថា ៤៩.៤១%។ គ្រូបង្រៀនចំនួន០៤នាក់ស្មើនឹង៤.៧១% បានផ្តល់ទិន្នន័យថា នាយកសាលាមិនបានរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍ទាល់តែសោះ។ ចំណែកនាយកសាលាចំនួន០៤នាក់ស្មើនឹង

២៦.៦៧% ក៏បានផ្តល់ទិន្នន័យក្នុងផែនការដូចគ្នានេះដែរ។ បើតាមទិន្នន័យប្រៀបធៀបភាគរយជាមធ្យម ឃើញថា១៥.៦៩%។ ផ្អែកលើលទ្ធផលនៃការផ្ទៀងផ្ទាត់ចម្លើយរបស់គ្រូបង្រៀន និងនាយកសាលាបង្ហាញថា កម្រិតមធ្យមនៃការរៀបចំ៦០.៧៩% យើងសន្និដ្ឋានថា នាយកសាលានៃសាលាគោលដៅទាំងអស់ភាគច្រើនបានរៀបចំផែនការចុះអធិការកិច្ច១ខែម្តង។ ចំណែកការរៀបចំផែនការចុះអធិការកិច្ចអមវិជ្ជា ២សប្តាហ៍មានទិន្នន័យតិច។ ម្យ៉ាងទៀតសាលាដែលមិនបានធ្វើផែនការចុះអធិការកិច្ចអមវិជ្ជាក៏មានទិន្នន័យផងដែរ។ ករណីនេះ មកពីការសិក្សាតាមអនឡាញទើបមិនបានរៀបចំផែនការចុះថ្នាក់ផ្ទាល់។

### ខ.ការចុះអធិការកិច្ចថ្នាក់រៀន

ក្រាបបន្ទាត់ខាងក្រោមនេះបង្ហាញពីការចុះអធិការកិច្ចអមវិជ្ជាថ្នាក់រៀនរបស់នាយក និងការទទួលការចុះអធិការកិច្ចអមវិជ្ជារបស់គ្រូបង្រៀន៖




*រូបភាព 41 ខ្សែបន្ទាត់បង្ហាញពីការចុះអធិការកិច្ច និងទទួលការចុះអធិការកិច្ចអមវិជ្ជារបស់នាយក*

ផ្អែកតាមគំនូសខ្សែបន្ទាត់ខាងលើបង្ហាញថា គ្រូបង្រៀនបាទទួលការចុះអធិការកិច្ចអមវិជ្ជាថ្នាក់រៀនពីនាយក បានតាមផែនការ មានចំនួន៤៣នាក់ ស្មើនឹង៥០.៥៩% នៃសាលាគោលដៅ។ រីឯ

នាយកសាលាវិញបានផ្តល់ទិន្នន័យក្នុងចំណុចនេះដែរមានចំនួន ០៥នាក់ ស្មើនឹង ៣៣.៣៣% នៃសាលាគោលដៅ។ បើតាមទិន្នន័យប្រៀបធៀបភាគរយជាមធ្យមឃើញថាមាន ៤១.៩៦%។ ចម្លើយពីគ្រូបង្រៀនបានបញ្ជាក់ ផ្នែកបានចុះដែរប៉ុន្តែមិនបានតាមផែនការ មានចំនួន១២នាក់ស្មើនឹង១៤.១២%។ រីឯនាយកសាលាវិញបានផ្តល់ទិន្នន័យក្នុងចំណុចនេះដែរមានចំនួន០៣នាក់ស្មើនឹង២០%។ បើតាមទិន្នន័យប្រៀបធៀបភាគរយជាមធ្យមឃើញថាមាន១៧.១៦%។ ដោយឡែកគ្រូបង្រៀនមួយភាគទៀតបានផ្តល់ចម្លើយមកថា មិនបានទទួលការចុះទាល់តែសោះ មានចំនួន ១១នាក់ ស្មើនឹង១២.៩៤% ។ រីឯនាយកសាលាវិញបានផ្តល់ទិន្នន័យក្នុងចំណុចនេះដែរមានចំនួន ០៣នាក់ ស្មើនឹង២០% ។ បើតាមទិន្នន័យប្រៀបធៀបភាគរយជាមធ្យមឃើញថាមាន១៦.៤៧%។

លទ្ធផលវិភាគខាងលើយើងសន្និដ្ឋានថា នាយកសាលាបានអនុវត្តតាមអនុសាសន៍របាយការណ៍អធិការកិច្ច ដោយបានអនុវត្តចុះអធិការកិច្ច អចិន្ត្រៃយ៍ថ្នាក់រៀនរបស់ខ្លួនលើគ្រូបង្រៀនក្នុងផ្នែក បានចុះតាមផែនការ មានភាគរយជាមធ្យម ប្រមាណ៤១.៩៦។ រីឯមួយភាគផ្សេងទៀតផ្នែក បានចុះដែរតែមិនបានតាមផែនការ មានភាគរយជាមធ្យមប្រមាណ ១៧.១៦%។ មធ្យមភាគជារួមនៃការចុះអធិការកិច្ចអចិន្ត្រៃយ៍៥៩.១៥%(កម្រិតមធ្យម)។ ដោយឡែកផ្នែក មិនបានចុះទាល់តែសោះ មានភាគរយជាមធ្យមប្រមាណ ១៦.៤៧%។ ករណីភាគរយបង្ហាញពីចំណុច បានចុះដែរតែមិនបានតាមផែនការ និង មិនបានចុះទាល់តែសោះ ពីសំណាកគោលដៅទាំងពីផ្នែកបានបង្ហាញដូច្នេះថា មកពីនាយករវល់ពេកក្នុងការងារម្យ៉ាងទៀតនាយកគាត់ជាប់បង្រៀនសិស្សដូចគ្រូបង្រៀនដែរ ខ្លះទៀតរវល់តែកែលម្អបរិស្ថាន និងមួយចំណុចទៀតគឺបណ្តាលមកពីវិបត្តិកូវីដ-១៩ដោយសាលាត្រូវបានយកធ្វើជាកន្លែងចត្តាឡីស័ក។

### ៤.៣.៣.៣.ការកែលម្អបរិស្ថានសាលារៀន

ក្រាបខាងក្រោមបង្ហាញពីការប្រៀបធៀបវិភាគទិន្នន័យដែលផ្តល់ដោយគ្រូបង្រៀន និងនាយកសាលាដើម្បីរកឱ្យឃើញពីចំណុចប្រសិទ្ធភាព និងគ្មានប្រសិទ្ធភាពនៃការអនុវត្តអនុសាសន៍ក្នុងរបាយការណ៍អធិការកិច្ចតាមកាលកំណត់នៅសាលាគោលដៅទាក់ទងជាមួយនឹងការកែលម្អបរិស្ថានសាលារៀន




*រូបភាព 42 ក្រាបបង្ហាញពីកម្រិតកែលម្អបរិស្ថានសាលារៀន*

ផ្អែកលើទិន្នន័យតាមក្រាបប្រៀបធៀបខាងលើបង្ហាញថា គ្រូបង្រៀនបានផ្តល់ទិន្នន័យអំពីកម្រិតចូលរួមកែលម្អបរិស្ថានសាលារៀន បានលើសពី១០០%មានចំនួន០១នាក់ស្មើនឹង១.១៨%។ ចំណែកនាយកសាលាមិនបានផ្តល់ទិន្នន័យក្នុងផ្នែកនេះទេ។ គ្រូបង្រៀនបានផ្តល់ទិន្នន័យផ្នែកអនុវត្ត បាន ១០០% មានចំនួន០៥នាក់ស្មើនឹង៥.៨៨%។ រីឯនាយកសាលាវិញមិនបានផ្តល់ទិន្នន័យក្នុងផ្នែកនេះទេ។ គ្រូបង្រៀនបានផ្តល់ទិន្នន័យផ្នែកអនុវត្ត បានពី៨០ទៅ៩០% មានចំនួន១៩នាក់ស្មើនឹង២២.៣៥%។ ចំណែកឯនាយកសាលាមានចំនួន០៦នាក់ស្មើ ៤០%។ បើតាមទិន្នន័យប្រៀបធៀបភាគរយជាមធ្យមឃើញថាមាន ៣១.១៨%។ គ្រូបង្រៀនបានផ្តល់ទិន្នន័យផ្នែក អនុវត្តបានពី៦០ទៅ៧០% មានចំនួន៣១នាក់ស្មើនឹង៣៦.៤៧%។ ចំណែកឯនាយកសាលាមានចំនួន០៥នាក់ស្មើនឹង៣៣.៣៣%។ បើតាមទិន្នន័យប្រៀបធៀបភាគរយជាមធ្យមឃើញថាមាន ៣៤.៩៩%។ គ្រូបង្រៀនបានផ្តល់ទិន្នន័យផ្នែកអនុវត្តបានក្នុងកម្រិត៥០% មានចំនួន០៨នាក់ ស្មើនឹង៩.៤៧%។ ចំណែកឯនាយកសាលាមានចំនួន ០១នាក់ស្មើនឹង៦.៦៧%។ បើតាមទិន្នន័យប្រៀបធៀបភាគរយជាមធ្យមឃើញថាមាន ៨.០៧%។ គ្រូបង្រៀនបានផ្តល់ទិន្នន័យផ្នែកអនុវត្ត បានតិចជាង៥០%មានចំនួន០១នាក់ស្មើ១.១៨%។ ចំណែកឯនាយកសាលាមិនបានផ្តល់ទិន្នន័យក្នុងចំណុចនេះឡើយ។ គ្រូបង្រៀនបានផ្តល់ព័ត៌មានត្រឡប់ផ្នែក មិនបានកែលម្អទាល់តែសោះ មានចំនួន០១នាក់ស្មើ១.១៨%។ ចំណែកឯនាយកមិនបានផ្តល់ទិន្នន័យឡើយ។

តាមលទ្ធផលប្រៀបធៀបខាងលើនេះយើងសន្និដ្ឋាន និងវិភាគតម្លៃមធ្យមនៃតម្លៃមធ្យមតាមកម្រិតគុណភាពឃើញថា កម្រិតកែលម្អបរិស្ថានសាលាមានទិន្នន័យ ៧៣.៧៤%។ ក្នុងនោះកម្រិតអនុវត្តពី៦០ទៅ៧០% មានកម្រិតមធ្យមស្មើនឹង ៣៤.៤៩% ហើយកម្រិតអនុវត្តពី៨០ទៅ៩០% មានកម្រិតមធ្យមស្មើនឹង ៣១.១៨% ដែលលេចធ្លោជាងគេ។ ពោលនាយកសាលាភាគច្រើនបានគោរពតាមអនុសាសន៍ក្នុងរបាយកាណ៍អធិការកិច្ច ដោយបានអនុវត្តលើការ រៀបចំសួនច្បារ ដាំផ្កា ធ្វើរបងសាលា និងជួសជុលរបង ដាំកូនឈើ រៀបចំកន្លែងលាងសម្អាតដៃ បិទរូបភាព រូបមន្តក្នុងថ្នាក់ និងការរៀបចំទីធ្លាហាត់កីឡាជាដើម។ ជារួមការអនុវត្តអនុសាសន៍ក្នុងរបាយកាណ៍អធិការកិច្ចមានប្រសិទ្ធភាព។ អ្នកស្រាវជ្រាវលើកមកនេះទៅតាមទិន្នន័យដែលសំណាកគោលដៅបានផ្តល់និងលទ្ធផលវិភាគតែប៉ុណ្ណោះ ។ ហើយក្រែងការផ្តល់មកនេះមិនទាន់គ្រប់គ្រាន់ឬមិនច្បាស់លាស់អ្នកស្រាវជ្រាវជំនាន់ក្រោយអាចបន្តស្រាវជ្រាវបន្ថែមបាន។ ដោយឡែកការ មិនបានកែលម្អទាល់តែសោះស្ថិតក្នុងភាគរយតិច អ្នកស្រាវជ្រាវបានទទួលព័ត៌មានបញ្ជាក់ថា មកពីបញ្ហាកូវីដ១៩ហើយសាលារៀនត្រូវបានដាក់ជាបណ្ឌលចត្តាឡីស័ក។

**៤.៣.៣.៤.ការធ្វើកិច្ចតែការបង្រៀន**

ក្រាបខាងក្រោមបង្ហាញពីការប្រៀបធៀបទិន្នន័យរបស់គ្រូបង្រៀន និងនាយកសាលាដើម្បីរកឱ្យឃើញពីចំណុចប្រសិទ្ធភាព និងគ្មានប្រសិទ្ធភាពនៃការអនុវត្តអនុសាសន៍ក្នុងរបាយការណ៍អធិការកិច្ចតាមកាលកំណត់ ៖




*រូបភាព 43 ក្រាបបង្ហាញពីកម្រិតនៃការធ្វើកិច្ចតែងការរបស់គ្រូបង្រៀន*

ផ្អែកលើទិន្នន័យតាមក្រាបប្រៀបធៀបខាងលើបង្ហាញថា គ្រូបង្រៀនបានផ្តល់ព័ត៌មានត្រឡប់អំពីកម្រិតបានធ្វើកិច្ចតែងការ និងបានយកមកឱ្យនាយក ត្រួតពិនិត្យដោយចុះហត្ថលេខា គ្រប់គ្រាន់មុននឹងយកទៅបង្រៀនរបស់គ្រូបង្រៀនមានដូចជា៖ កម្រិតអនុវត្តបាន១០០% អ្នកស្រាវជ្រាវមិនបានទទួលទិន្នន័យពីសំណាកគោលដៅទាំងពីរឡើយ។ កម្រិតអនុវត្តបានពី៨០ទៅ៩០%អ្នកស្រាវជ្រាវទទួលបានការផ្តល់ព័ត៌មានត្រឡប់ពីគ្រូបង្រៀនមានចំនួន១២នាក់ស្មើនឹង១៤.១២%។ ចំណែកនាយកសាលាបានផ្តល់ទិន្នន័យមានចំនួន០៤នាក់ស្មើនឹង២៦.៦៧%។ បើតាមការប្រៀបធៀបភាគរយនៃកម្រិតលទ្ធផលសំណាកទាំងពីផលគឺជាភាគរយជាមធ្យមស្មើនឹង២០.៤%។ កម្រិតបានអនុវត្តពី៦០ទៅ៧០% អ្នកស្រាវជ្រាវទទួលបានការផ្តល់ទិន្នន័យពីគ្រូបង្រៀនបានចំនួន២០នាក់ស្មើនឹង២៣.៥៣%។ ចំណែកនាយកសាលាបានផ្តល់ទិន្នន័យចំនួន០៣នាក់ស្មើនឹង២០%។ បើតាមការប្រៀបធៀបភាគរយនៃកម្រិតលទ្ធផលសំណាកទាំងពីផលគឺជាភាគរយជាមធ្យមស្មើនឹង ២១.៧៧%។ កម្រិតបានអនុវត្តត្រឹម៥០% អ្នកស្រាវជ្រាវទទួលបានការផ្តល់ទិន្នន័យមានចំនួន១៤នាក់ស្មើនឹង១៦.៤៧%។ ចំណែកនាយកសាលាបានផ្តល់ទិន្នន័យមានចំនួន០២នាក់ស្មើនឹង១៣.៣៣%។ បើតាមការប្រៀបធៀបភាគរយនៃកម្រិតលទ្ធផលសំណាកទាំងពីផលគឺជាភាគរយជាមធ្យមស្មើនឹង១៤.៩០%។ កម្រិតបានអនុវត្តតិចជាង៥០%អ្នកស្រាវជ្រាវទទួលបានការផ្តល់ទិន្នន័យមានចំនួន២០នាក់ស្មើនឹង២៣.៥៣%។ ចំណែកផ្នែកនាយកវិញយើងទទួលបានការផ្តល់ទិន្នន័យមានចំនួន០២នាក់ ស្មើនឹង១៣.៣៣%។ បើតាមការប្រៀបធៀបភាគរយនៃកម្រិតលទ្ធផលសំណាកទាំងពីផលគឺជាភាគរយជាមធ្យមស្មើនឹង១៨.៤៣%។ នៅក្នុង កម្រិតមិនបានអនុវត្តទាល់តែសោះ យើងមិនបានទទួលទិន្នន័យពីគ្រូបង្រៀនឡើយ។ ចំណែកឯសំណាកនាយកសាលាវិញ អ្នកស្រាវជ្រាវទទួលបានការផ្តល់ទិន្នន័យមានចំនួន០២នាក់ស្មើនឹង១៣.៣៣%។

តាមលទ្ធផលប្រៀបធៀបខាងលើនេះយើងចសន្និដ្ឋាន និងវិភាគតម្លៃរួមនៃតម្លៃមធ្យមតាមកម្រិតគុណភាពឃើញថា ការធ្វើកិច្ចតែងការរបស់គ្រូបង្រៀនមានត្រឹម ៦0-70% (ល្អបង្គួរ)ប៉ុណ្ណោះ។ ដូច្នេះការអនុវត្តស្ថិតនៅមានកម្រិតមួយដែលគ្រូបង្រៀន ត្រូវអនុវត្តការធ្វើកិច្ចតែងការបង្រៀន និងនាយកត្រួតពិនិត្យ ដោយចុះហត្ថលេខា គ្រប់គ្រាន់មុននឹងឱ្យគ្រូយកទៅបង្រៀន។

### ៤.៣.៣.៥.ការងាររដ្ឋបាលថ្នាក់ និងរដ្ឋបាលគ្រូ

### ក.ការអនុវត្តការងារបែបរដ្ឋបាលថ្នាក់

ក្រាបខាងក្រោមបង្ហាញពីការប្រៀបធៀបវិភាគទិន្នន័យដែលផ្តល់ដោយគ្រូបង្រៀន និងនាយក ទាក់ទងជាមួយនឹងកម្រិតបានតុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់របស់គ្រូបង្រៀន៖




*រូបភាព 44កម្រិតបានតុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់របស់គ្រូបង្រៀន*

ផ្អែកលើទិន្នន័យតាមក្រាបប្រៀបធៀបខាងលើបង្ហាញថា គ្រូបង្រៀនបានផ្តល់ព័ត៌មានត្រឡប់អំពីកម្រិតបានតុបតែងថ្នាក់ តាមបែបបទរដ្ឋបាលថ្នាក់របស់គ្រូបង្រៀន មានទិន្នន័យដូចជា៖ បានអនុវត្ត ១០០%ចំនួន ០១នាក់ ស្មើនឹង១.១៨%។ ចំណែកទិន្នន័យពីសំណាកនាយកអ្នកស្រាវជ្រាវមិនបានទទួលព័ត៌មានត្រឡប់ឡើយ។ ដូច្នេះតម្លៃជាមធ្យមស្មើនឹង ០.៥៩%។ កម្រិតអនុវត្តពី៨០ទៅ៩០% អ្នកស្រាវជ្រាវបានទទួលព័ត៌មានត្រឡប់ពីគ្រូបង្រៀនមានចំនួន១៦នាក់ស្មើនឹង១៨.៨២%។ ចំណែកទិន្នន័យពីសំណាកនាយក អ្នកស្រាវជ្រាវទទួលបានចំនួន០២នាក់ស្មើនឹង១៣.៣៣%។ បើតាមការប្រៀបធៀបភាគរយនៃកម្រិតលទ្ធផលដែលទទួលបានពីសំណាកទាំងពីរ ភាគរយជាមធ្យមស្មើនឹង១៦.០៨%។ កម្រិតបានអនុវត្តពី៦០ទៅ៧០%អ្នកស្រាវជ្រាវបានទទួលព័ត៌មានត្រឡប់ពីគ្រូបង្រៀនមានចំនួន២៩នាក់

ស្មើនឹង៣៤.១២%។ ចំណែកទិន្នន័យពីសំណាកនាយក អ្នកស្រាវជ្រាវបានទទួលចំនួន០៧នាក់ស្មើនឹង ៤៦.៦៧%។ បើតាមការប្រៀបធៀបភាគរយនៃកម្រិតលទ្ធផលដែលទទួលបានពីសំណាកទាំងពីរ ភាគរយជាមធ្យមស្មើនឹង ៤០.៤០%។ កម្រិតបានអនុវត្តត្រឹម៥០% យើងបានទទួលទិន្នន័យពីគ្រូបង្រៀនមានចំនួន១៥នាក់ស្មើនឹង១៧.៦៥%។ ចំណែកទិន្នន័យពីសំណាកនាយក អ្នកស្រាវជ្រាវបានទទួលចំនួន ០២នាក់ស្មើនឹង១៣.៣៣%។ បើតាមការប្រៀបធៀបភាគរយ នៃកម្រិតលទ្ធផលដែលទទួលបានពីសំណាកទាំងពីរ ភាគរយជាមធ្យមស្មើនឹង១៥.៤៩%។ កម្រិតបានអនុវត្តតិចជាង៥០% អ្នកស្រាវជ្រាវបានទទួលព័ត៌មានត្រឡប់ពីគ្រូបង្រៀនមានចំនួន០២នាក់ស្មើនឹង២.៣៥%។ ចំណែកទិន្នន័យពីសំណាកនាយក អ្នកស្រាវជ្រាវបានទទួលចំនួន០១នាក់ស្មើនឹង៦.៦៧%។ បើតាមការប្រៀបធៀបភាគរយនៃកម្រិតលទ្ធផលដែលទទួលបានពីសំណាកទាំងពីរ ភាគរយជាមធ្យមស្មើនឹង ៤.៥១%។ កម្រិត មិនបានអនុវត្តទាល់តែសោះអ្នកស្រាវជ្រាវបានទទួលព័ត៌មានត្រឡប់ពីគ្រូបង្រៀន មានចំនួន០៣នាក់ស្មើនឹង ៣.៥៣%ចំណែកទិន្នន័យពីសំណាកនាយកអ្នកស្រាវជ្រាវមិនបានទទួលព័ត៌មានត្រឡប់ពីនាយកឡើយ។

តាមលទ្ធផលប្រៀបធៀបខាងលើនេះអ្នកស្រាវជ្រាវអាចសន្និដ្ឋាន និងវិភាគតម្លៃរួមនៃតម្លៃមធ្យមតាមកម្រិតគុណភាពឃើញថា កម្រិតបានតុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់របស់គ្រូបង្រៀនមានតម្លៃមធ្យមភាគរួមទិន្នន័យស្មើនឹង៧២.៥៦%។ តម្លៃនេះមានន័យថា គ្រូបង្រៀនបានតុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់នៅតាមសាលារៀនគោលដៅមានប្រសិទ្ធភាព។ ដោយឡែកលទ្ធផល កម្រិតមិនបានអនុវត្តទាន់តែសោះគឺបណ្ដាលមកពី ការងារច្រើន បង្រៀនផង កាន់ការងារគណនេយ្យសាលាផង ជួនកាលបង្រៀនក្រៅថ្នាក់ ហើយមួយផ្នែកទៀតមកពីសាលារៀនទើបទទួលបានអគារថ្មី មិនទាន់បានតុបតែងជាដើម។

### ខ.ការអនុវត្តការងារបែបរដ្ឋបាលគ្រូ

ក្រាបខាងក្រោមបង្ហាញពីការប្រៀបធៀបវិភាគទិន្នន័យដែលផ្ដល់ដោយគ្រូបង្រៀន និងនាយកសាលាដើម្បីរកឱ្យឃើញពីចំណុចប្រសិទ្ធភាព និងគ្មានប្រសិទ្ធភាពនៃការអនុវត្តអនុសាសន៍ក្នុងរបាយ

ការណ៍អធិការកិច្ចតាមកាលកំណត់នៅសាលាគោលដៅទាក់ទងជាមួយនឹងកម្រិតការអនុវត្តការងារបែបរដ្ឋបាលគ្រូ៖




*រូបភាព 45 ក្រាបបង្ហាញពីកម្រិតបានរៀបចំសៀវភៅនានាតាមបែបបទរដ្ឋបាលគ្រូ*

ផ្អែកលើទិន្នន័យតាមក្រាបប្រៀបធៀបខាងលើបង្ហាញថា គ្រូបង្រៀនបានផ្តល់ព័ត៌មានត្រឡប់អំពីកម្រិតបានតុបតែងថ្នាក់តាមបែបបទរដ្ឋបាលគ្រូមានទិន្នន័យដូចជា៖ កម្រិតបានរៀបចំអនុវត្ត១០០%អ្នកស្រាវជ្រាវបានទទួលព័ត៌មានត្រឡប់ពីគ្រូបង្រៀនចំនួន ០៥នាក់ ស្មើនឹង៥.៨៨%។ ចំណែកទិន្នន័យពីសំណាកនាយក យើងបានទទួលចំនួន ០១នាក់ ស្មើនឹង៦.៦៧%។ បើតាមការប្រៀបធៀបភាគរយនៃកម្រិតលទ្ធផលដែលទទួលបានពីសំណាកទាំងពីរ ភាគរយជាមធ្យមស្មើនឹង ៦.២៨%។ កម្រិតអនុវត្តបានអនុវត្តពី៨០ទៅ៩០%អ្នកស្រាវជ្រាវបានទទួលព័ត៌មានត្រឡប់ពីគ្រូបង្រៀនចំនួន ១៨នាក់ស្មើនឹង២១.១៨%។ ចំណែកទិន្នន័យពីសំណាកនាយក អ្នកស្រាវជ្រាវបានទទួលចំនួន ០៣នាក់ស្មើនឹង២០%។ បើតាមការប្រៀបធៀបភាគរយនៃកម្រិតលទ្ធផលដែលទទួលបានពីសំណាកទាំងពីរ ភាគរយជាមធ្យមស្មើនឹង ២០.៥៩%។ កម្រិតបានអនុវត្តពី៦០ទៅ៧០%អ្នកស្រាវជ្រាវបានទទួលទិន្នន័យពីគ្រូបង្រៀនមានចំនួន២៤នាក់ស្មើនឹង២៨.២៤%។ ចំណែកទិន្នន័យពីសំណាកនាយក អ្នកស្រាវជ្រាវបានទទួលចំនួន០៥

នាក់ស្មើនឹង៣៣.៣៣%។ បើតាមការប្រៀបធៀបភាគរយនៃកម្រិតលទ្ធផលដែលទទួលបានពីសំណាកទាំងពីរ ភាគរយជាមធ្យមស្មើនឹង៣០.៧៨%។ កម្រិតបានអនុវត្តត្រឹម៥០% អ្នកស្រាវជ្រាវបានទទួលទិន្នន័យពីគ្រូបង្រៀនមានចំនួន១៦នាក់ស្មើនឹង១៨.៨២%។ ចំណែកទិន្នន័យពីសំណាកនាយក យើងបានទទួលមានចំនួន០២នាក់ស្មើនឹង១៣.៣៣%។ បើតាមការប្រៀបធៀបភាគរយនៃកម្រិតលទ្ធផលដែលទទួលបានពីសំណាកទាំងពីរ ភាគរយជាមធ្យមស្មើនឹង១៦.០៨%។ កម្រិតបានអនុវត្តតិចជាង ៥០%អ្នកស្រាវជ្រាវបានទទួលទិន្នន័យពីគ្រូបង្រៀនមានចំនួន០២នាក់ស្មើនឹង២.៣៥%។ ចំណែកទិន្នន័យពីសំណាកនាយក យើងមិនបានទទួលឡើយ។ កម្រិតមិនបានអនុវត្តទាល់តែសោះ អ្នកស្រាវជ្រាវបានទទួលទិន្នន័យពីគ្រូបង្រៀនមានចំនួន០១នាក់ស្មើនឹង១.១៨%។ ចំណែកទិន្នន័យពីសំណាកនាយក យើងបានទទួលចំនួន ០១នាក់ស្មើនឹង៦.៦៧%។ បើតាមការប្រៀបធៀបភាគរយនៃកម្រិតលទ្ធផលដែលទទួលបានពីសំណាកទាំងពីរ ភាគរយជាមធ្យមស្មើនឹង ៣.៩៣%។

តាមលទ្ធផលប្រៀបធៀបខាងលើនេះយើងសន្និដ្ឋាន និងវិភាគតម្លៃរួមនៃតម្លៃមធ្យមតាមកម្រិតគុណភាពឃើញថាទិន្នន័យ ៧៣.៧៣% ។ តម្លៃនេះមានន័យថា គ្រូបង្រៀនបានរៀបចំឯកសារ សៀវភៅតាមបែបបទរដ្ឋបាលគ្រូនៅតាមសាលារៀនគោលដៅមានប្រសិទ្ធភាព។ ដោយឡែកលទ្ធផលយកម្រិតមិនបានអនុវត្តទាល់តែសោះ ភាគរយជាមធ្យមស្មើនឹង ៣.៩៣%។ ករណីនេះអ្នកស្រាវជ្រាវបានទទួលព័ត៌មានត្រឡប់ថា គ្រូបង្រៀនតាមអនឡាញ ហើយការរៀបចំសៀវភៅរដ្ឋបាលគ្រូពីគ្រូបងៀនហាក់មិនចាប់អារម្មណ៍ក្នុងការរៀបចំសៀវភៅរដ្ឋបាលគ្រូឱ្យបានគ្រប់គ្រាន់។

**៤.៣.៣.៦.ការលើកកម្ពស់គុណភាព និងលទ្ធផលសិក្សារបស់សិស្សឱ្យមានការកើនឡើង**

ក្រាបខាងក្រោមបង្ហាញពីការប្រៀបធៀបវិភាគទិន្នន័យដែលផ្តល់ដោយគ្រូបង្រៀន និងនាយកសាលាដើម្បីរកឱ្យឃើញពីចំណុចប្រសិទ្ធភាព និងគ្មានប្រសិទ្ធភាពនៃការអនុវត្តអនុសាសន៍ក្នុងរបាយការណ៍អធិការកិច្ចតាមកាលកំណត់ ៖




*រូបភាព 46 ក្រាបបង្ហាញពីគុណភាព និងលទ្ធផលសិក្សារបស់សិស្សកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ*

ផ្អែកលើទិន្នន័យតាមក្រាបប្រៀបធៀបខាងលើបង្ហាញថា គ្រូបង្រៀននិងនាយកសាលាបានផ្តល់ព័ត៌មានត្រឡប់អំពី កម្រិតកើនឡើងនៃគុណភាព និងលទ្ធផលសិក្សារបស់សិស្សពីមួយឆ្នាំទៅមួយឆ្នាំ ដូចជាៈ កម្រិតរីកចម្រើនកើនពី១ដល់៥%ជារៀងរាល់ឆ្នាំ ផ្នែកគ្រូ ១៥.២៩% និងនាយក២៧.២៧%ជាមធ្យមស្មើនឹង ២១.២៨%។ កម្រិតកើនពី៦ដល់១០%ជារៀងរាល់ឆ្នាំ ផ្នែកគ្រូបង្រៀន១៨.៨២% និងនាយកសាលា៣៦.៣៦% ជាមធ្យមស្មើនឹង២៧.៥៩%។ កម្រិតកើនពី១១ដល់១៥%ជារៀងរាល់ឆ្នាំ ផ្នែកគ្រូបង្រៀន២០% និងនាយក១៨.១៨% ជាមធ្យមស្មើនឹង ១៩.០៩%។ កម្រិតកើនពី១៦ដល់២០%ជារៀងរាល់ឆ្នាំ ផ្នែកគ្រូបង្រៀន១១.៧៦% និងនាយក ៩.០៩% ជាមធ្យមស្មើនឹង១០.៤៣%។ កម្រិតកើនលើសពី២១%ជារៀងរាល់ឆ្នាំ គ្មានទិន្នន័យទាំងពីរផ្នែក។ កម្រិតមិនកើនទាល់តែសោះ ផ្នែកគ្រូបង្រៀន ១១.៧៦% និងនាយក១១.១៨% ជាមធ្យមស្មើនឹង ១៤.៩៧%។ តាមលទ្ធផលប្រៀបធៀបខាងលើនេះ អ្នកស្រាវជ្រាវអាចសន្និដ្ឋាន និងវិភាគតម្លៃទិន្នន័យរួមមធ្យម ឃើញថា ៨១.៣៩% កើនឡើងពី ៦ទៅ ១០% កើនឡើងមធ្យម។ តម្លៃនេះមានន័យថា កម្រិតកើនឡើងនៃគុណភាព និងលទ្ធផលសិក្សារបស់

សិស្សពីមួយឆ្នាំទៅមួយឆ្នាំ នៃសាលារៀនគោលដៅនៅមានកម្រិត។ ដោយឡែកលទ្ធផលយកម្រិតមិនកើនឡើងទាល់តែសោះ ភាគរយជាមធ្យមស្មើនឹង ១៤.៩៧%។

### ៤.៣.៣.៧.ការចូលរួមគាំទ្ររបស់សហគមន៍

ក្រាបខាងក្រោមបង្ហាញពីការប្រៀបធៀបវិភាគទិន្នន័យដែលផ្តល់ដោយគ្រូបង្រៀន និងនាយកសាលាដើម្បីរកឱ្យឃើញពីចំណុចប្រសិទ្ធភាព និងគ្មានប្រសិទ្ធភាពនៃការអនុវត្តអនុសាសន៍ក្នុងរបាយការណ៍អធិការកិច្ចតាមកាលកំណត់ ៖




*រូបភាព 47 ក្រាបបង្ហាញការចូលរួមគាំទ្រពីសហគមន៍នៃសាលាគោលដៅ*

ផ្អែកលើទិន្នន័យតាមក្រាបប្រៀបធៀបខាងលើបង្ហាញថា កម្រិតចូលរួមរបស់សហគមន៍នៃសាលាគោលដៅមានចូចជា៖ កម្រិតល្អ ផ្នែកគ្រូបង្រៀន១៤.១២% និងនាយក៦.៦៧% ជាមធ្យម១០.៤%។ កម្រិតល្អបង្គួរ ផ្នែកគ្រូបង្រៀន ២២.៣៥% និងនាយក៤០% ជាមធ្យម ៣១.១៨%។ **កម្រិតមធ្យម** ផ្នែកគ្រូ៣៦.៤៧% និងនាយក៣៣.៣៣% ជាមធ្យម ៣៤.៩០% ។ ចំណែកផ្នែកកម្រិតក្រោមធ្យម និងខ្សោយ ទិន្នន័យបានតែគ្រូបង្រៀនប៉ុណ្ណោះដែលមានភាគរយតិចបំផុត ពីនាយកគ្មានទិន្នន័យ។ តាមលទ្ធផលប្រៀបធៀបខាងលើនេះអ្នកស្រាវជ្រាវអាចសន្និដ្ឋាន និងវិភាគតម្លៃរួមនៃតម្លៃមធ្យមតាមកម្រិតគុណ

ភាពឃើញថាទិន្នន័យទទួលបាន ៧៨.២៤% ដែលកម្រិតភាគរយខ្ពស់គឺ ៥០%-៦៤% (មធ្យម) ។ តម្លៃនេះមានន័យថា កម្រិតចូលរួមគាំទ្រពីសហគមន៍ នៃសាលារៀនគោលដៅមានប្រសិទ្ធភាពស្ថិតក្នុងកម្រិតមធ្យម ដែលបានជួយគ្រាំផ្ទែកថវិកា ដាំដើមឈើ ធ្វើរោងដាក់កង់ម៉ូតូ ជួសជុលរបបជាដើម។

## ៤.៤.២.លទ្ធផលនៃការពិភាក្សាលើសំណួរស្រាវជ្រាវទី១

### ៤.៤.២.១.ប្រសិទ្ធភាពនៃការអនុវត្តអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀនដោយសាលារៀន

តារាងខាងក្រោមបង្ហាញពីចំណុចគោលអាទិភាពដែលក្រុមការងារអធិការកិច្ច បានដាក់ឱ្យសាលាអនុវត្ត បន្ទាប់ពីបានចុះអធិការកិច្ចតាមកាលកំណត់រួចមកនៃសាលាគោលដៅ ហើយវាក៏ជាចំណុចប្រសិទ្ធភាពគោលដែលអ្នកស្រាវជ្រាវលើកមកធ្វើការសិក្សាស្រាវជ្រាវ និងវិភាគផ្ទៀងផ្ទាត់ជារួមអំពីការប្រសិទ្ធភាពក្នុងការអនុវត្តរបស់សាលារៀនផងដែរ។

| ល.រ | ចំណុចប្រសិទ្ធភាព | ចំនួនគោល (%) | ទិន្នន័យ (%) | អនុវត្តបាន% | កម្រិត |
|---|---|---|---|---|---|
| 01 | ការរៀបចំទីចាត់ការ | 100 | 78.82 | 60-79 | ល្អបង្គួរ |
| 02 | ផែនការនិងការចុះអធិការកិច្ចថ្នាក់រៀន | 100 | 59.02 | 41.56 | ខ្សោយ |
| 03 | ការកែលម្អបរិស្ថានសាលារៀន | 100 | 78.24 | 60-70 | ល្អបង្គួរ |
| 04 | ការធ្វើកិច្ចតែការបង្រៀន | 100 | 75.49 | 60-70 | ល្អបង្គួរ |
| 05 | រដ្ឋបាលថ្នាក់និងរដ្ឋបាលគ្រូ | 100 | 76.00 | 60-70 | ល្អបង្គួរ |
| 06 | គុណភាពនិងលទ្ធផលសិក្សារបស់សិស្សមានការកើនឡើងជាបន្តបន្ទាប់ | 100 | 81.39 | 6-10 | មធ្យម |
| 07 | ការចូលរួមគាំទ្ររបស់សហគមន៍ | 100 | 78.24 | 50-64 | មធ្យម |
| សរុបរួម | | | 75.31 | 60-70 | ល្អបង្គួរ |

*តារាងទី 18 ទិន្នន័យលទ្ធផលសរុបនៃ ចំណុចគោលអនុសាសន៍អធិការកិច្ច*

ផ្អែកលើទិន្នន័យក្នុងតារាងខាងលើបង្ហាញថា ១.កម្រិតអនុវត្ត ការរៀបចំទីចាត់ការ នៃសាលារៀនគោលដៅទាំងអស់បានអនុវត្តមាន៦០-៧៩%(ល្អបង្គួរ)។ ២.កម្រិតអនុវត្ត ផែនការនិងការចុះអធិការកិច្ចថ្នាក់រៀន៤១.៥៦%(ខ្សោយ)។ ៣.កម្រិតអនុវត្ត ការកែលម្អបរិស្ថានសាលារៀន មាន ៦០-៧០%(ល្អបង្គួរ)។ ៤.កម្រិតអនុវត្ត ការធ្វើកិច្ចតែការបង្រៀន ៦០-៧០%(ល្អបង្គួរ)។ ៥.កម្រិតអនុវត្ត រដ្ឋបាលថ្នាក់និងរដ្ឋបាលគ្រូ ៦០%-៧០% (ល្អបង្គួរ)។ ៦.កម្រិតអនុវត្តផ្នែកគុណភាពនិងលទ្ធផលសិក្សារបស់សិស្សមានការកើនឡើងជាបន្តបន្ទាប់ មានភាគរយកំណើនពី ៦%-១០% រៀងរាល់ឆ្នាំ (មធ្យម)។ ៧.កម្រិតអណុវត្តការចូលរួមគាំទ្ររបស់សហគមន៍មាន ៥០-៦៤% (មធ្យម) ។ លទ្ធផលមធ្យមភាគសរុបរួមនៃចំណុចគោលអាទិភាព ប្រសិទ្ធភាពមាន ៦០-៧០% (ល្អបង្គួរ)។ ក្នុងនោះកម្រិត ល្អបង្គួរ មាន០៤ចំណុចគោលអាទិភាព គឺចំណុចទី១.ចំណុចទី៣.ចំណុចទី៤.និងចំណុចទី៥។ កម្រិតខ្សោយ និងមធ្យមមាន០៣ចំណុចគឺចំណុចទី២ ចំណុចទី៦ និងចំណុចទី៧។

យោងលទ្ធផលខាងលើយើងសន្និដ្ឋានថា ការចុះអធិការកិច្ចតាមកាលកំណត់ជាសកម្មភាពល្អ ក្នុងនោះសាលារៀនពិតមានការកិវឌ្ឍជាបន្តបន្ទាប់ ដោយចាំបាច់នៅតែបន្តអនុវត្តកិច្ចការនេះបន្ថែមទៀតដល់សាលានានាឱ្យបានគ្រប់គ្រាន់ទាំងអស់។ ពិសេសធ្វើឱ្យនាយកសាលា គ្រូបង្រៀន សិស្សានុសិស្ស សហគមន៍មានបម្រុងប្រយ័ត្នក្នុងការចូលរួម ការគ្រប់គ្រងដឹកនាំ ការបង្រៀន និងរៀន ការអភិវឌ្ឍសាលារៀន។

## ៤.៤.៣.ស្ថានភាពនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់

ផ្អែកតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថា សាលារៀនចំនួន០៧ ស្មើនឹង៦៣.៦៤%

សាលាគោលដៅទាំង១១ រក្សាទុករបាយការណ៍អធិការកិច្ចតាមកាលកំណត់បានល្អ មានការទុកដាក់បានសុវត្ថិភាពងាយក្នុងការយកមកប្រើប្រាស់មិនបាត់បង់។ ចំណែកឯសាលារៀនចំនួន ០៤ស្មើនឹង៣៦.៣៦% មិនបានរក្សាទុករបាយការណ៍អធិការកិច្ចបានល្អឡើយ ពោលគឺមិនចាប់អារម្មណ៍ទុកមិនបានត្រឹមត្រូវធ្វើឱ្យបាត់រកមិនឃើញ ហើយសាលាមួយចំនួនលើកឡើងថា ខ្លួនមិនចាំថាបានទទួលឬក៏អត់ឡើយ។ សាលារៀនគោលដៅទាំងអស់បានអនុវត្តអនុសាសន៍អធិការកិច្ចបាន៧៥.៣១% នៅសល់

២៤.៦៩% ដោយបានបញ្ជាក់ឱ្យដឹងថាមកពីសាលារៀនជាប់ជាមណ្ឌលចត្តាឡីស័ក ម្យ៉ាងទៀតអនុវត្តមិនទាន់ចប់វដ្តនៃអធិការកិច្ចតាមកាលកំណត់។

### ៤.៤.៤.លទ្ធផលនៃការពិភាក្សាសំណួរស្រាវជ្រាវទី២

#### ៤.៤.៤.១.បញ្ហាប្រឈម ក្នុងការអនុវត្តអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់នៅសាលារៀន

ក្នុងការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់នៅតាមសាលារៀន មានដំណើរជាបន្តបន្ទាប់ដូចលទ្ធផលបញ្ជាក់នៅខាងលើ ក្នុងនោះយើងបានរកឃើញពីបញ្ហាប្រឈមនានារបស់សាលារៀនក្នុងការអនុវត្តអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់ ដែលក្រុមអធិការកិច្ចដាក់ឱ្យសាលាគោលដៅអនុវត្តដូចជា៖

- ការអនុវត្តអនុសាសន៍ទី២ ៖ ផែនការនិងការចុះអធិការកិច្ចថ្នាក់រៀន ទទួលទិន្នន័យ ១៩.៨១% (សាលារៀនមិនបានអនុវត្តទាល់តែសោះ) ។ ចំណុចនេះបណ្តាលមកពី នាយកមានការរវល់ច្រើន (បង្រៀនផង ការប្រជុំ ធ្វើរបាយការណ៍ផង)។
- ការអនុវត្តអនុសាសន៍ទី៦ ៖ គុណភាពនិងលទ្ធផលសិក្សារបស់សិស្ស តាមលទ្ធផលវិភាគបង្ហាញថា សិស្សមិនកើនឡើងទាល់តែសោះ យើងទទួលបានទិន្នន័យ ១៤.៩៧%។ ចំណុចនេះបណ្តាលមកពីសិស្សខ្សោយអំណាន និងបោះបង់ច្រើន ការបង្រៀនមិនបានជិតដល់ ។
- ការអនុវត្តអនុសាសន៍ទី៧ ៖ ការចូលរួមគាំទ្ររបស់សហគមន៍ ស្ថិតក្នុងកម្រិតមធ្យម (ទិន្នន័យខ្ពស់ ៣៤.៩០%) ចំណុចនេះមកពីសាលាខ្សោយទំនាក់ទំនង ហើយសហគមន៍រវល់នឹងការងារផ្ទាល់ខ្លួន (កសិកម្ម)។
- សាលារៀនទុកដាក់របាយការណ៍អធិការកិច្ចតាមកាលកំណត់មិនបានត្រឹមត្រូវ សាលាខ្លះបាត់រកមិនឃើញ ពិបាកក្នុងការយកមកប្រើប្រាស់មិនបានទាន់ពេលវេលា។
- គ្រូបង្រៀនជាង៥០% មិនដែលបានឆ្លងកាត់ការបំប៉ន ឬសិក្ខាសាលាទាក់ទងមុខវិជ្ជាឯកទេស

វិធីសាស្ត្របង្រៀន។

- នាយកសាលាមិនបានឆ្លងកាត់ការប្រជុំរួមបង្ហាញពីលទ្ធផលអធិការកិច្ចតាមកាលកំណត់ក្នុងក្រុង/ស្រុកនីមួយៗដើម្បីទទួលរបាយការណ៍ជាក់លាក់ និងលើកទិសដៅអនុវត្តបន្តពីក្រុមអធិការកិច្ច ការធ្វើកិច្ចតែងការបង្រៀនចំពោះគ្រូបង្រៀនដែលត្រូវបង្រៀនពីរទៅបីមុខវិជ្ជា ហើយសរសេរដោយដៃហើយប៊ិកខៀវមិនអោយប្រើបច្ចេកវិទ្យា។

## ៤.៤.៥.ការយល់ឃើញចំពោះការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់

យោងទៅតាមការចូលរួម និងផ្តល់មតិយោបល់របស់លោកគ្រូ អ្នកគ្រូ គណៈគ្រប់គ្រងសាលារៀន បានបង្ហាញឱ្យឃើញថា របាយការណ៍អធិការកិច្ចតាមកាលកំណត់ពិតជាជួយឱ្យសាលារៀនមានការអភិវឌ្ឍទៅបានមែនព្រោះថា ៖

១.បានជួយឱ្យនាយក នាយិកា បង្កើនការគ្រប់គ្រងសាលារៀន និងមានភាពម្ចាស់ការចំពោះតួនាទីរបស់ខ្លួនបានកាន់តែល្អជាងមុន។

២.បានជួយឱ្យគ្រូបង្រៀនកាន់តែយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងការងាររដ្ឋបាលគ្រូ និងការងាររដ្ឋបាលថ្នាក់បានកាន់តែល្អជាងមុន។

៣.បានធ្វើឱ្យសាលារៀនមានបរិស្ថានស្អាត ដោយមានការដាំផ្កាអមផ្លូវចូលសាលា ដាំកូនឈើ និងការធ្វើរបង អមទាំងការជួសជុលបន្ថែមទៀតដែរ។

៤.លោកគ្រូអ្នកគ្រូខិតខំប្រឹងប្រែងពង្រឹងសមត្ថភាពចំណេះដឹងរបស់ខ្លួនបានកាន់តែប្រសើរឡើង ដូចជាការបង្រៀនតាមប្រើបច្ចេកវិទ្យា ទូរស័ព្ទដៃទំនើប កុំព្យូទ័រ ។

៥.ធ្វើឱ្យនាយកនិងគ្រូបង្រៀនកាន់តែមានទំនាក់ទំនងល្អជាមួយសហគមន៍និងអ្នកពាក់ព័ន្ធ។

# ជំពូកទី៥

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១. សេចក្តីសន្និដ្ឋាន

របាយការណ៍អធិការកិច្ចតាមកាលកំណត់ មានសារៈសំខាន់ណាស់ចំពោះសាលារៀនដែលជាអាទិភាពមួយសម្រាប់ធ្វើជាមូលដ្ឋានក្នុងការកែលម្អគ្រប់ជ្រុងជ្រោយ ដែលសាលារៀនទាំងឡាយមិនអាចខ្វះបាន។ អ្នកពាក់ព័ន្ធទាំងអស់រួមមាន គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន សិស្ស សហគមន៍ មាតាបិតា អាជ្ញាធរមូលដ្ឋាន សុទ្ធសឹងតែជាសមាសភាពសំខាន់ដែលត្រូវយល់ឱ្យបានច្បាស់ អំពីតួនាទីក្នុងការអនុវត្តអនុសាសន៍នៃរបាយការណ៍អធិការកិច្ចតាមកាលកំណត់ ដែលក្រុមអធិការកិច្ចដាក់ឱ្យកែលម្អសាលារៀនក្នុងរយៈពេល៥ឆ្នាំក្រោយពីការចុះអធិការកិច្ចរួចរាល់។ ការយកចិត្តទុកដាក់អនុវត្តអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់ពីមួយឆ្នាំទៅមួយឆ្នាំក្នុងសាលារៀន នឹងធ្វើឱ្យសាលារៀនមានការអភិវឌ្ឍរីកចម្រើនលឿន ហើយសមស្របទៅតាមសេចក្តីត្រូវការរបស់សង្គមអប់រំ ព្រមទាំងក្លាយជាប្រសិទ្ធភាពមួយមិនអាចកាត់ថ្លៃបានឡើយ។ ដោយមើលឃើញពីចំណុចទាំងនេះហើយទើបយើងសម្រេចជ្រើសរើសយកប្រធានបទមួយស្តីពី «ប្រសិទ្ធភាពនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀនក្នុងខេត្តឧត្តរមានជ័យ» ក្នុងគោលបំណងពីរគឺ៖ ១.វាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀនដោយសាលារៀន ២.កំណត់បញ្ហាប្រឈមក្នុងការអនុវត្តរបាយការណ៍អធិការកិច្ច និងដាក់ចេញនូវអនុសាសន៍ដើម្បីកែលម្អការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់ដល់សាលារៀន។

ផ្អែកលើលទ្ធផលនៃការវិភាគចេញពីចម្លើយដែលបានផ្តល់ជូន ពីសំណាកគោលដៅស្របតាមកម្រងសំណួរដែលយើងបានដាក់ចេញសម្រាប់ប្រមូលទិន្នន័យទាក់ទងនឹងគោលបំណងខាងលើ យើងសន្និដ្ឋានថា ការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀន ស្ថិតក្នុងកម្រិតល្អបង្គួរ ព្រោះលទ្ធផលរួមនៃសូចនាករគោលខ្ពស់ជាង ៣.៥ នៃចំណុចគោល ពោលគឺលើសពី៥០%ឡើងរហូតដល់កម្រិតពី៦០-៧០%។ វាជាប្រសិទ្ធភាពនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់។

### ៥.១.១.សេចក្តីសន្និដ្ឋានលើសំណួរស្រាវជ្រាវទី១

ស្ថានភាពនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់មានលក្ខណៈដូចជា៖ សាលារៀនចំនួន០៧ ស្មើនឹង៦៣.៦៤% សាលាគោលដៅទាំង១១ រក្សាទុករបាយការណ៍អធិការកិច្ចតាមកាលកំណត់បានល្អ មានការទុកដាក់បានសុវត្ថិភាពងាយក្នុងការយកមកប្រើប្រាស់។ ចំណែកឯសាលារៀនចំនួន០៤ ស្មើនឹង៣៦.៣៦% រក្សាទុករបាយការណ៍អធិការកិច្ចមិនបានល្អឡើយ ពោលគឺមិនចាប់អារម្មណ៍ទុកមិនបានត្រឹមត្រូវធ្វើឱ្យបាត់រកមិនឃើញ ហើយសាលាមួយចំនួនមិនចាំថាបានទទួលរបាយការណ៍ឬក៏អត់ឡើយ។ ទោះជាយ៉ាងនេះក្តីការអនុវត្តអនុសាសន៍អធិការកិច្ចរបស់សាលារៀនគោលដៅទាំងអស់បានពី៦០-៧០%(ល្អបង្គួរ) ដែលជារួមយើងឃើញលើអនុសាសន៍ចំនួន០៤គឺ៖

**១.ការរៀបចំទីចាត់ការ** ៖ ទិន្នន័យទទួលបាន ៧៨.៨២% ហើយការអនុវត្តបាន៦០-៧០%ស្ថិតក្នុងកម្រិត ល្អបង្គួរ ។ (ចំណុចទី១នៃអនុសាសន៍)

**២.ការកែលម្អបរិស្ថានសាលារៀន** ទិន្នន័យទទួលបាន ៧៨.២៤% ហើយការអនុវត្តបាន ៦០-៧០%ស្ថិតក្នុងកម្រិត ល្អបង្គួរ ។ (ចំណុចទី៣នៃអនុសាសន៍)

**៣.ការធ្វើកិច្ចតែការបង្រៀន** ទិន្នន័យទទួលបាន ៧៥.៤៩% ហើយការអនុវត្តបាន៦០-៧០%ស្ថិតក្នុងកម្រិត ល្អបង្គួរ ។ (ចំណុចទី៤នៃអនុសាសន៍)

**៤.រដ្ឋបាលថ្នាក់និងរដ្ឋបាលគ្រូ** ទិន្នន័យទទួលបាន៧៦% ហើយការអនុវត្តបាន *៦០%-៧០%* ស្ថិតក្នុងកម្រិត ល្អបង្គួរ ។ (ចំណុចទី៥នៃអនុសាសន៍)

ជារួមយើងសន្និដ្ឋានថា ការអនុវត្តអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់បានត្រឹម ០៤ចំណុចស្មើនឹង ៥៧.១៤% ដែលទទួលបានកម្រិតអនុវត្តពី៦០ទៅ៧០% ល្អបង្គួរ។

### ៥.១.២.សេចក្តីសន្និដ្ឋានលើសំណួរស្រាវជ្រាវទី២

ទន្ទឹមនឹងនេះការស្រាវជ្រាវក៏បានរកឃើញពីបញ្ហាប្រឈមរបស់សាលារៀន ក្នុងការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់ទៅលើចំណុច០៣នៃអនុសាសន៍ដូចជា៖

**១.ផែនការនិងការចុះអធិការកិច្ចថ្នាក់រៀន៖** ទិន្នន័យទទួលបាន ៥៩.០២% ហើយការអនុវត្តបាន ៤១-៥៦%ស្ថិតក្នុងកម្រិត ខ្សោយ ។ (ចំណុចទី២នៃអនុសាសន៍)

**២.គុណភាពនិងលទ្ធផលសិក្សារបស់សិស្សមានការកើនឡើងជាបន្តបន្ទាប់៖** ទិន្នន័យភាគរយដែលទទួលបានខ្ពស់ជាងគេគឺ ២៧.៥៩% ស្ថិតក្នុងកម្រិត មធ្យម កើនពី៦%ទៅ១០%។ (ចំណុចទី០៦នៃអនុសាសន៍)

**៣.ការចូលរួមគាំទ្ររបស់សហគមន៍៖** ទិន្នន័យទទួលបាន ៧៨.២៤% ហើយការអនុវត្តបាន ៥០-៦៤%ស្ថិតក្នុងកម្រិត មធ្យម ។ (ចំណុចទី៧នៃអនុសាសន៍)

ផ្អែកលើលទ្ធផលខាងលើនេះ យើងអាចសន្និដ្ឋានបានថា ការអនុវត្តអនុសាសន៍ទទួលបានភាគរយតិចមាន០៣ចំណុច ស្មើនឹង ៤២.៨៦%។ ករណីនេះបណ្តាលមកពីការរក្សាទុកដាក់របាយការណ៍អធិការកិច្ចតាមកាលកំណត់មិនបានត្រឹមត្រូវ ដែលជាហេតុធ្វើឱ្យបាត់បង់រកមិនឃើញ នូវអ្វីដែលក្រុមអធិការកិច្ចបានដាក់ជូនដើម្បីកែលម្អសាលារៀន។ វាជាបញ្ហាប្រឈមមួយដល់សាលារៀន មានន័យថាបើនាយកមិនបានចុះត្រួតពិនិត្យគ្រូបង្រៀន ដូច្នេះការបង្រៀនរបស់គ្រូក៏មិនបានល្អ ហើយបើខ្សោយទំនាក់ទំនងល្អជាមួយសហគមន៍ទៀតក៏ជាហេតុធ្វើឱ្យ លទ្ធផលសិក្សារបស់សិស្សមិនកើនឡើងខ្ពស់ និងការអភិវឌ្ឍសាលារៀនក៏ស្ថិតនៅមានកម្រិតដែរ។ ករណីនេះទាមទារឱ្យនាយកសាលាខិតខំប្រឹងប្រែង អនុវត្តអនុសាសន៍អធិការកិច្ចឱ្យបានខ្ជាប់ខ្ជួនខានមិនបាន។ ក្រៅពីនេះយើងឃើញមានបញ្ហាប្រឈមមួយចំនួនផងដែរដូចជា៖ គ្រូបង្រៀនជាង៥០% មិនដែលបានឆ្លងកាត់ការបំប៉នសមត្ថភាពលើមុខវិជ្ជាឯកទេសរបស់ខ្លួន និងវិធីសាស្ត្របង្រៀនឡើយ។

## ៥.២. សំណូមពរ

យោងលទ្ធផលវិភាគក្នុងការស្រាវជ្រាវ យើងសូមលើកជាសំណូមពរដល់អ្នកពាក់ព័ន្ធដូចជា៖ ៖

### *៥.២.១.សាលារៀន*

- គួរទុកដាក់ អនុវត្តធ្វើផែនការ និងចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនឱ្យបានច្បាស់លាស់ តាមផែនការស្របតាម អនុសាសន៍របស់ក្រុមអធិការកិច្ចដោយចុះ៖ ១.ក្នុងសប្តាហ៍ទី៤ ខែដំបូងបន្ទាប់ពីថ្ងៃបើក

បរវេសនកាល ២.ក្នុងសប្តាហ៍ទី៤នៃខែដែលចេញលទ្ធផលប្រចាំខែដំបូង។ ៣.ក្នុងសប្តាហ៍ទី៤នៃខែដែលចេញលទ្ធផលឆមាសទី១រួច ៤.ក្នុងសប្តាហ៍ទី៤នៃខែដែលចេញលទ្ធផលឆមាសទី២រួច។ ម្យ៉ាងទៀតកំណត់លទ្ធផលសិក្សារបស់សិស្សឱ្យបានខ្ពស់ តាមរយៈប្រជុំបច្ចេកទេសជួយគ្រូបង្រៀនឱ្យជាប់ជាប្រចាំតាមផែនការ។ ព្រមទាំងបង្កើនទំនាក់ទំនងជាមួយសហគមន៍ឱ្យបានច្រើនឡើងបន្ថែមទៀត ។

### ៥.២.២.ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក

- គួរពង្រឹងប្រព័ន្ធចុះអធិការកិច្ចអចិន្ត្រៃយ៍សាលារៀនឱ្យបានច្បាស់លាស់និងទៀងទាត់តាមផែនការ និងពិនិត្យពេលវេលាការផ្ញើរបាយការណ៍អធិការកិច្ចតាមកាលកំណត់បន្តទៅសាលារៀន ដោយប្រាកដថាសាលារៀនពិតជាបានទទួល និងទុកដាក់បានត្រឹមត្រូវ។

### ៥.២.៣.មន្ទីរអប់រំ យុវជន និងកីឡាខេត្ត

- គួរបញ្ចូល៣០%នៃសាលារៀនដែលបានចុះអធិការកិច្ចតាមកាលកំណត់រួច ក្នុងធ្វើផែនការចុះអធិការកិច្ចតាមកាលកំណត់ឆ្នាំអនុវត្ត ដើម្បីបន្តជួយសាលារៀន។ ហើយការិយាល័យពាក់ព័ន្ធគួរសហការចូលរួមអនុវត្តអនុសាសន៍អធិការកិច្ច ជួយសាលារៀន បំប៉នសមត្ថភាពគ្រូ និងវិធីសាស្ត្របង្រៀន។

### ៥.២.៤.ក្រសួងអប់រំ យុវជន និងកីឡា

- គួររៀបប្រព័ន្ធជ្រើសរើសសាលាស្អាត នាយកល្អ គ្រូល្អ ដោយផ្តល់អាទិភាពពីសាលារៀនដែលបានចុះអធិការកិច្ចតាមកាលកំណត់រួចរាល់ ដែលបានអនុវត្តអនុសាសន៍ចាប់ពី៣ឆ្នាំឡើង ដល់៥ឆ្នាំ ឬច្រើនឆ្នាំជាបន្តបន្ទាប់។
- គួរបង្កើតប្រព័ន្ធលើកទឹកចិត្តក្រុមការងារអធិការកិច្ចថ្នាក់ខេត្ត ករណីដែលមានសាលារៀន នាយកគ្រូបង្រៀន ទទួលបានជ័យលាភី ជាសាលារៀនស្អាតឬគំរូ នាយកល្អ គ្រូឆ្នើម ដែលកើតចេញពីសាលារៀនដែលបានចុះអធិការកិច្ចតាមកាលកំណត់រួចរាល់ ។
- គួរដាក់ឱ្យអនុវត្តប្រព័ន្ធបំប៉នសមត្ថភាពមន្ត្រីរាជការនៅថ្នាក់ខេត្ត ដើម្បីឱ្យថ្នាក់ខេត្តមានមូលដ្ឋានបង្កើតក្រុមបច្ចេកទេសជាក់លាក់មួយដែលមានវិសាលភាពជួយដល់វិស័យអប់រំក្នុងខេត្ត ក៏ដូចជានាយក

គ្រូបង្រៀនតាមសាលារៀនបានទាន់ពេលវេលាយ៉ាងតិចនាយក ឬគ្រូបង្រៀនម្នាក់បានចូលរួមវគ្គបំប៉ន ឬសិក្ខាសាលាលើមុខវិជ្ជាឯកទេសរបស់ខ្លួន និងវិធីសាស្រ្តបង្រៀនថ្មីៗស្របតាមកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡាហោចណាស់ក្នុងមួយឆ្នាំម្តងដែរ។ មានន័យថាបើកន្លងមកសាលារៀនមានក្រុមបច្ចេកទេសប្រចាំសាលាដើម្បីជួយគ្រូ និងសាលារៀន ដូច្នេះថ្នាក់ខេត្តក៏មានក្រុមបច្ចេកទេសប្រចាំខេត្តដើម្បីជួយសាលា និងវិស័យអប់រំខេត្តដូចគ្នាដែរ។

## ៥.២.៥.អ្នកសិក្សាស្រាវជ្រាវក្រោយៗ

- ការសិក្សាស្រាវជ្រាវលើប្រធានបទ «ប្រសិទ្ធភាពនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀន ក្នុងខេត្តឧត្តរមានជ័យ» គឺធ្វើឡើងតែទៅលើសាលាគោលដៅផ្នែកមធ្យមសិក្សាបឋមភូមិចំនួន១១ ដែលបានធ្វើអធិការកិច្ចតាមកាលកំណត់រួចរាល់ប៉ុណ្ណោះ។ ម្យ៉ាងទៀតការសិក្សាស្រាវជ្រាវនេះស្របនឹងការរីករាលដាល់នៃវិបត្តិកូវីដ-១៩ផង។ ដូច្នេះការសិក្សានេះមិនទាន់គ្រប់ជ្រុងជ្រោយនោះឡើយ ពីព្រោះការសិក្សាស្រាវជ្រាវតាមអនឡាញ យើងទទួលបានតែលទ្ធផលពីនាយក និងគ្រូបង្រៀនសាលាគោលដៅប៉ុណ្ណោះ ខ្វះសំណាកពាក់ព័ន្ធដូចជាសិស្សានុសិស្ស និងសហគមន៍។ នៅថ្ងៃអនាគតសំណូមពរអ្នកស្រាវជ្រាវជំនាន់ក្រោយៗ អាចធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទនេះបានដើម្បីពង្រីកវិសាលភាពឱ្យបានទូលំទូលាយលើទំហំសំណាក និងការវិភាគឱ្យបានស៊ីជម្រៅបន្ថែមទៀត។ ពិសេសរកគន្លឹះទាក់ទាញការចូលរួម ពីអ្នកពាក់ព័ន្ធឱ្យមានការចាប់អារម្មណ៍អនុវត្តអនុសាសន៍របាយការណ៍អធិការកិច្ចតាមកាលកំណត់ឱ្យបានកាន់តែល្អប្រសើរឡើងបន្ថែមទៀត។

-

# ឯកសារយោង

# ឯកសារយោង

Wiktionary. (2021, March 24). *ប្រសិទ្ធភាព*. យកមកវិញពី google Chrome: km.m.wiktionary.org

ការិយាល័យ អធិការកិច្ច នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ. (ឆ្នាំ២០២០). *របាយការណ៍ត្រួតពិនិត្យលទ្ធផលអនុវត្តអនុសាសន៍អធិការកិច្ច*. ក្រុងសំរោង: ការិ.អធក.

ក្រសួងអប់រំ យុវជន និងកីឡា . (២០១៩). *ផែនទីបង្ហាញផ្លូវ ការអប់រំ កម្ពុជាឆ្នាំ២០៣០ (គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤)*. រាជធានីភ្នំពេញ: MOEYS.

ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ). (២០១៦). *បំណិនវិជ្ជាជីវៈ (សម្រាប់បំប៉ននាយកបឋម និងមធ្យមសិក្សា)*. រាជធានីភ្នំពេញ: MOEYS.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៥). *បញ្ញត្តិនៃការធានាគុណភាពអប់រំ(កម្រិតមត្តេយ្យសិក្សា និងអប់រំចំណោះទូទៅនៅកម្ពុជា)*. រាជធានីភ្នំពេញ: MOEYS.

ក្រសួងអប់រំ យុវជន និងកីឡា. (ខែវិច្ឆិកា ឆ្នាំ២០១៨). *យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា២០១៨-២០២៣*. រាជធានីភ្នំពេញ: MOEYS.

ក្រសួងអប់រំ យុវជន និងកីឡា. (ឆ្នាំ២០១៨). *ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល*. រាជធានីភ្នំពេញ: MOEYS.

ក្រសួងអប់រំ យុវជន និងកីឡា. (ឆ្នាំ២០១៨). *ផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ស្តីពីការអប់រំនៅកម្ពុជា*. រាជធានីភ្នំពេញ: MOEYS.

ក្រសួងអប់រំ យុវជន និងកីឡា. (ឆ្នាំ២០២១). *សេចក្តីណែនាំលេខ១១អយក ស្តីពីការរៀបចំបញ្ជីពិន្ទុ និងបញ្ជីហៅឈ្មោះសិស្សបឋមសិក្សា* . រាជធានីភ្នំពេញ: MOEYS.

ក្រសួងអប់រំ យុវជន និងកីឡា(នាយកដ្ឋានធានាគុណភាពអប់រំ). (ឆ្នាំ២០២០). *សៀវភៅជំនួយស្មារតីស្តីពីអធិការកិច្ចសាលារៀន*. រាជធានីភ្នំពេញ: MOEYS.

ក្រសួងអប់រំ យុវជន និងកីឡា(នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ). (ឆ្នាំ២០១៤). *ស្វ័យវាយតម្លៃសាលារៀន សម្រាប់បំប៉ននាយកសាលាបឋមសិក្សា និងមធ្យមសិក្សា*. រាជធានីភ្នំពេញ: MOEYS.

ក្រសួងអប់រំ យុវជន និងកីឡា(នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ). (ឆ្នាំ២០១៦ ). *ការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ*. រាជធានីភ្នំពេញ: MOEYS.

ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានធានាគុណភាពអប់រំ). (២០២១). *ទម្រង់របាយការណ៍ស្វ័យវាយតម្លៃដំណើរការសិក្សាគន្លងជីវិតថ្មី* . Phnom Penh: MOEYS.

នាយកដ្ឋានធានាគុណភាពអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា. (មករា ២០២១). *សៀវភៅជំនួយស្មារតី អធិការកិច្ចតាមកាលកំណត់* . រាជធានីភ្នំពេញ: EQAD of MOEYS.

ព្រះមហាក្សត្រខ្មែរ. (ឆ្នាំ២០០៥). *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា.* រាជធានីភ្នំពេញ: អង្គការស្មោរកម្ពុជា.

មន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ. (ឆ្នាំ២០២០). *សន្និបាតបូកសរុប វាយតម្លៃការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០១៨-២០១៩ និងលើកទិសដៅការងារឆ្នាំសិក្សា២០១៩-២០២០.* ក្រុងសំរោង: POE OMC.

រាជរដ្ឋាភិបាលកម្ពុជា. (២០១៥). *យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ អាណត្តិទី៦* . រាជធានីភ្នំពេញ.

រាជរដ្ឋាភិបាលកម្ពុជា. (ខែកញ្ញា ឆ្នាំ២០០៨). *អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន.* រាជធានីភ្នំពេញ: MOEYS.

រាជរដ្ឋាភិបាលកម្ពុជា. (ឆ្នាំ២០១៩). *គោលនយោបាយស្តីពីការសិក្សាពេញមួយជីវិត.* រាជធានីភ្នំពេញ: MOEYS.

លោក សុខ ផល្លា. (ឆ្នាំ២០១៨). *សារណា ស្ថានភាពនៃការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំ ក្នុងខេត្តឧត្តរមានជ័យ.* រាជធានីភ្នំពេញ: សាម៉ីខ្លួន.

លោក សុខ មករា . (២០២០). *ស្ថានភាពនៃការគ្រប់គ្រង និងការប្រើប្រាស់ធនធានអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តស្វាយរៀង.* រាជធានីភ្នំពេញ: សាមីខ្លួន.

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ. (ឆ្នាំ ២០០៨). *វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត.* រាជធានីភ្នំពេញ: BIC .

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ « ក » កម្រងសំណួរស្រាវជ្រាវនាយក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

វិទ្យាស្ថានជាតិអប់រំ

## កម្រងសំណួរសម្រាប់សម្ភាសន៍នាយកសាលា

ខ្ញុំបាទឈ្មោះ អ៊ឹម សានី ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ នឹងធ្វើការសិក្សាស្រាវជ្រាវសរសេរនិក្ខេបបទទាក់ទងនឹងប្រធានបទ«ប្រសិទ្ធភាពនៃការអនុវត្តគោលការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀនក្នុងខេត្តឧត្តរមានជ័យ» ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រប់អប់រំនៅវិទ្យាស្ថានជាតិអប់រំ។

ខ្ញុំបាទសូមអនុញ្ញាត លោកនាយក នាយករង នាយិកា នាយិការង មេត្តាផ្តល់ទិន្នន័យទៅតាមកម្រងសំណួរជាលំដាប់លំដោយដោយសេចក្តីអនុគ្រោះ។ គ្រប់ទិន្នន័យនឹងត្រូវរក្សាការសម្ងាត់ជូនលោកលោកស្រី។ សូមអរគុណចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកនាយក នាយករង នាយិកា នាយិការង ក្នុងការជួយបំពេញកម្រងសំណួរនេះ។

**ផ្នែកទី១៖ ព័ត៌មានទូទៅ**

សូមលោក លោកស្រី ផ្តល់ទិន្នន័យទូទៅតាមកម្រងសំណួរជាលំដាប់លំដោយដូចខាងក្រោម៖

១.ភេទ

- □ ក.ប្រុស
- □ ខ.ស្រី

២.ឋានៈតួនាទី៖

- □ ក.នាយក/នាយិកា
- □ ខ.នាយករង/នាយិការង

៣.តើលោក លោកស្រីមានវ័យប៉ុន្មានឆ្នាំហើយ?

- □ ក.១៨ឆ្នាំដល់២៥ឆ្នាំ
- □ ខ.២៦ឆ្នាំដល់៣៥ឆ្នាំ
- □ គ.៣៦ឆ្នាំដល់៤៥ឆ្នាំ

□ ឃ.៤៦ឆ្នាំដល់៥៥ឆ្នាំ
□ ង.៥៦ឆ្នាំឡើង

៤.តើលោក លោកស្រីមានបទពិសោធន៍ដឹកនាំនិងគ្រប់គ្រងជានាយក នាយិកា នាយិការង ប៉ុន្មានឆ្នាំ?

□ ក.០១ឆ្នាំដល់១០ឆ្នាំ
□ ខ.១១ឆ្នាំដល់២០ឆ្នាំ
□ គ.២១ឆ្នាំដល់៣០ឆ្នាំ
□ ឃ.៣១ឆ្នាំដល់៤០ឆ្នាំ
□ ង.៤១ឆ្នាំឡើង

៥.តើសាលារៀនរបស់លោក លោកស្រីមានឈ្មោះដូចម្តេច?

□ ក.អនុវិទ្យាល័យ ហ៊ុន សែនរួតចំប៊ី
□ ខ.អនុវិទ្យាល័យ ស៊ូរ៉ែកគុណាពោធិវង្ស
□ គ.អនុវិទ្យាល័យ បន្សាយរាក់
□ ឃ.អនុវិទ្យាល័យ កូនក្រៀល
□ ង.អនុវិទ្យាល័យ បុស្សួវ
□ ច.អនុវិ.សម្តេចតេជោ ហ៊ុន សែន ចុងកាល់
□ ឆ.អនុវិទ្យាល័យ ជើងទៀន
□ ជ.អនុវិទ្យាល័យ គោកឪឡោក
□ ឈ.អនុវិទ្យាល័យ បេង
□ ញ.អនុវិទ្យាល័យ តេជោ អូរស្រមរ
□ ត.អនុវិទ្យាល័យ ថ្លាត

៦.តើពីផ្ទះឬកន្លែងស្នាក់នៅទៅសាលារៀនរបស់លោក លោកស្រីមានចម្ងាយប៉ុន្មានគីឡូម៉ែត្រ

□ ក.០គីឡូម៉ែត្រ ដល់៥គីឡូម៉ែត្រ
□ ខ.៦គីឡូម៉ែត្រ ដល់១០គីឡូម៉ែត្រ
□ គ.១១គីឡូម៉ែត្រ ដល់២០គីឡូម៉ែត្រ
□ ឃ.២១គីឡូម៉ែត្រ ដល់២៥គីឡូម៉ែត្រ
□ ង.២៦គីឡូម៉ែត្រ ដល់៣០គីឡូម៉ែត្រ
□ ច.៣១គីឡូម៉ែត្រឡើង

៦.១.ការធ្វើដំណើរបំពេញការងាររបស់លោក លោកស្រីជួបការលំបាក ឬងាយស្រួលយ៉ាងដូចម្តេច?

.................................................................................................................................................

៧.កម្រិតជំនាញវិជ្ជាជីវៈ

- □ ក.ក្រោមបរិញ្ញាបត្រ
- □ ខ.បរិញ្ញាបត្រ
- □ គ.បរិញ្ញាបត្រជាន់ខ្ពស់
- □ ឃ.បណ្ឌិត
- □ ង.ផ្សេងៗ

៨.តើលោក លោកស្រី បានទទួលការប្រកាសតែងតាំង ជានាយក នាយិកា នាយករង នាយិការងក្នុងការគ្រប់គ្រងជាផ្លូវការហើយឬនៅ? (បើមិនទាន់បានប្រកាសតែងតាំងសូមបញ្ជាក់មូលហេតុផង)

..................................................................................................................................................................

៩.តើលោក លោកស្រីមានបានទទួលវគ្គបំប៉នអ្វីខ្លះលើការងារដឹកនាំ និងគ្រប់គ្រង ឬការងារអេធិការកិច្ច?

..................................................................................................................................................................

១០.តើសាលារៀន លោក លោកស្រី មានចំនួនបុគ្គលិកសរុបប៉ុន្មាននាក់?ស្រីប៉ុន្មាននាក់?( *សូមបំពេញតាមតាមទម្រង់ឧទាហរណ៍៖* ***១២នាក់ស្រី០៥នាក់*** )

..................................................................................................................................................................

១១.តើសាលារៀន លោក លោកស្រីមានសិស្សសរុបចំនួនប៉ុន្មាននាក់?ស្រីប៉ុន្មាននាក់? ( *សូមបំពេញតាមតាមទម្រង់ឧទាហរណ៍៖* ***១០០នាក់ស្រី៥០នាក់*** )

..................................................................................................................................................................

១២.តើមានអគារសិក្សាប៉ុន្មានខ្នង?ស្មើនឹងប៉ុន្មានបន្ទប់? (សូមបំពេញតាមតាមទម្រង់ឧទាហរណ៍៖ ***០១ខ្នងស្មើនឹង២០បន្ទប់*** )

..................................................................................................................................................................

១៣.តើមានបង្គន់អនាម័យប៉ុន្មានខ្នង និងប៉ុន្មានបន្ទប់? (សូមបំពេញតាមតាមទម្រង់ឧទាហរណ៍៖ ***០២ខ្នងស្មើនឹង១០បន្ទប់*** )

..................................................................................................................................................................

**ផ្នែកទី២៖ការគ្រប់គ្រងនិងដឹកនាំ**

ដើម្បីឆ្លើយតបនឹងប្រសិទ្ធភាពនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀនសូមលោក លោកស្រីផ្ដល់ព័ត៌មានត្រឡប់តាមរយៈកម្រងសំណួរជាបន្តបន្ទាប់នៅខាងក្រោម៖

១៤តើលោក លោកស្រីបានរៀបចំតុបតែងទីចាត់ការ បានសមរម្យគ្រប់គ្រាន់កម្រិតណាដែរ ដូចជារចនាសម្ព័ន្ធគ្រប់គ្រង ស្ថិតិ ថ្នាក់រៀន គ្រូ សិស្ស ...?

- □ ក.រៀបចំបានលើស១០០%
- □ ខ.រៀបចំបាន១០០%
- □ គ.រៀបចំបាន៨០-99%
- □ ឃ.រៀបចំបាន៦០-79%
- □ ង.រៀបចំបាន៥០-៥៩%
- □ ច.រៀបចំបានក្រោម៥០%
- □ ឆ.មិនបានរៀបចំសោះ

១៤.១.បើរៀបចំបានក្រោម៥០% ឬមិនបានរៀបចំសោះសូមបញ្ជាក់អំណះអំណាងបន្ថែមផង ហើយបើបានរៀបចំពី៥០%ឡើងលើសូមបញ្ជាក់ផ្នែកដែលបានរៀបចំគោលៗផង

..........................................................................................................................................

១៥.តើលោក លោកស្រីបានរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនយ៉ាងណាដែរ?

- □ ក.ចុះប្រចាំសប្តាហ៍
- □ ខ.ចុះ២សប្តាហ៍ម្តង
- □ គ.ចុះ១ខែម្តង
- □ ង.ចុះម្តងម្កាល
- □ ច.មិនបានចុះទាល់តែសោះ

១៥.១.បើមិនបានរៀបចំចុះទាល់តែសោះសូមបញ្ជាក់អំណះអំណាងបន្ថែមផង ហើយបើបានរៀបចំគ្រាន់តែដាក់ថា បានអនុវត្ត

..........................................................................................................................................

១៦.តើលោក លោកស្រី បានចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនយ៉ាងដូចម្តេចដែរ?

- □ ក.បានចុះតាមផែនការ
- □ ខ.បានចុះដែរតែមិនបានតាមផែនការ
- □ គ.មិនបានចុះទាល់សោះ

១៦.១.បើ *មិនមិនបានចុះទាល់តែសោះ ឬបានចុះតែមិនបានតាមផែនការ* សូមបញ្ជាក់មូលហេតុបន្ថែមផង ហើយបើ**បានចុះតាមផែនការ** គ្រាន់តែដាក់ថា « *បានអនុវត្តតាមផែនការ* »

..............................................................................................................................

១៧.តើលោក លោកស្រីបានកែលម្អបរិស្ថានសាលារៀនស្របតាមអនុសាសន៍អធិការកិច្ចបានកម្រិតណាដែរ ?

- □ ក.បានលើស១០០%
- □ ខ.បាន១០០%
- □ គ.បាន៨០ទៅ៩០%
- □ ឃ.បាន ៦០ទៅ៧០%
- □ ង.បាន៥០%
- □ ច.បានតិចជាង៥០%
- □ ឆ.មិនបានកែលម្អទាល់តែសោះ

១៧.១.បើ *មិនបានកែលម្អទាល់តែសោះ ឬ បានតិចជាង៥០%* សូមបញ្ជាក់មូលហេតុបន្ថែមផង ហើយបើ **បានអនុវត្តលើ៥០%** សូមបញ្ជាក់ចំណុចគោលៗដែលបានធ្វើផង

.........................................................................................................................................

១៨.តើ គ្រូបង្រៀនបានធ្វើកិច្ចតែងការ និងយកមកឱ្យលោក លោកស្រី ត្រួតពិនិត្យ ដោយចុះហត្ថលេខាគ្រប់គ្រាន់មុននឹងបង្រៀនបានកម្រិតណាដែរ ?

- □ ក.បាន១០០%នៃគ្រូទាំងអស់
- □ ខ.បាន៨០%ទៅ៩០%នៃគ្រូទាំងអស់
- □ គ.បាន៦០%ទៅ៧០%នៃគ្រូទាំងអស់
- □ ឃ.បាន៥០%នៃគ្រូទាំងអស់
- □ ង.បានតិតជាង៥០%នៃគ្រូទាំងអស់
- □ ច.មិនបានអនុវត្តទាល់តែសោះ

១៨.១.បើ ***មិឋនបានអនុវត្តទាល់តែសោះ ឬ បានតិតជាង៥០%នៃគ្រូទាំងអស់*** សូមបញ្ជាក់មូលហេតុបន្ថែមផង ហើយបើ **បានអនុវត្តលើសពី៥០%** សូមបញ្ជាក់ចំណុចគោលៗនៃការអនុវត្តល្អបន្ថែមផងដែរៈ

.........................................................................................................................................

១៩.តើគ្រូបង្រៀន តុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់បានកម្រិតណាដែរ ?

- □ ក.បាន១០០%
- □ ខ.បាន៨០%ទៅ៩០%
- □ គ.បាន៦០%ទៅ៧០%
- □ ឃ.បាន៥០%
- □ ង.បានតិតជាង៥០%

□ ចQ.មិនបានអនុវត្តទាល់តែសោះ

១៩.១.Qបើ ***បានតិតជាង៥០% ឬ មិនបានអនុវត្តទាល់តែសោះ*** សូមបញ្ជាក់មូលហេតុបន្ថែមផង ហើយបើ **បានអនុវត្តលើសពី៥០%** សូមបញ្ជាក់ចំណុចគោលៗនៃការអនុវត្តល្អបន្ថែមផងដែរៈ

..........................................................................................................................................................

២០.តើគ្រូបង្រៀន បានរៀបចំឱ្យមានសៀវភៅនានាតាមបែបបទរដ្ឋបាលគ្រូបានកម្រិតណាដែរ?

- □ ក.បាន១០០%
- □ ខ.បាន៨០%ទៅ៩០%
- □ គ.បាន៦០%ទៅ៧០%
- □ ឃ.បាន៥០%
- □ ង.បានតិតជាង៥០%
- □ ច.មិនបានអនុវត្តទាល់តែសោះ

២០.១.បើ ***បានតិតជាង៥០% ឬ មិនបានអនុវត្តទាល់តែសោះ*** សូមបញ្ជាក់មូលហេតុបន្ថែមផង ហើយបើ **បានអនុវត្តលើសពី៥០%** សូមបញ្ជាក់ចំណុចគោលៗនៃការអនុវត្តល្អ ៖

..........................................................................................................................................................

២១.តើគុណភាពនិងលទ្ធផលសិក្សារបស់សិស្សមានការកើនឡើងជាបន្តបន្ទាប់យ៉ាងណាដែរពីមួយឆ្នាំទៅមួយឆ្នាំ?

- □ ក.កើនដល់១០០%
- □ ខ.កើន ៨០%ទៅ៩០%
- □ គ.កើន៦០%ទៅ៧០%
- □ ឃ.កើន៥០%
- □ ង.កើនតិចជាង៥០%
- □ ច.មិនកើនទាល់តែសោះ

២១.១.បើ ***មិនកើនទាល់តែសោះឬ កើនតិចជាង៥០%*** សូមបញ្ជាក់មូលហេតុបន្ថែមផង ហើយបើ **កើនលើសពី៥០%** សូមបញ្ជាក់ចំណុចគោលៗដូចជានិទ្ទេស A= ប៉ុន្មាន%? B= ប៉ុន្មាន%? C= ប៉ុន្មាន%? D= ប៉ុន្មាន%? E= ប៉ុន្មាន%? F= ប៉ុន្មាន%? នៃការអនុវត្តល្អបន្ថែមផង ៖

..........................................................................................................................................................

២២.តើសាលារៀន លោក លោកស្រី មានការចូលរួមគាំទ្រពីសហគមន៍ ឬសាធារណៈជនកម្រិតណាដែរ?

- □ ក.ល្អណាស់
- □ ខ.ល្អ
- □ គ.ល្អបង្គួរ
- □ ឃ.មធ្យម
- □ ង.ក្រោមមធ្យម
- □ ច.ខ្សោយ

២២.១.បើ ***ខ្សោយ ឬ ក្រោមមធ្យម*** សូមបញ្ជាក់មូលហេតុបន្ថែមផង ហើយបើ **ចាប់ពីមធ្យមឡើង** សូមបញ្ជាក់ចំណុចគោលៗនៃការចូលរួមផង ៖

..................................................................................................................................................

២៣.តើបន្ទាប់ពីក្រុមការងារអធិការកិច្ចបានចុះធ្វើអធិការកិច្ចនៅសាលារៀនលោក លោកស្រី រួចមកមានការអភិវឌ្ឍរីកចម្រើនជាងមុនកម្រិតណា?

- □ ក.បានអនុវត្ត ១០០%
- □ ខ.បានអនុវត្ត ពី៨០-៩៩%
- □ គ.បានអនុវត្ត ពី៦០-ទៅ៧៩%
